# ដំណឹងល្អតាមលោកម៉ាកុស

# ពាក្យលំនាំ

គម្ពីរទាំងបួនកណ្ឌសុទ្ធតែជាសំណេរអនាមិក គឺគ្មានកត់ត្រាឈ្មោះអ្នកនិពន្ធទុកទេ។ ប៉ុន្តែ តាំងពីដើមរៀងមក ព្រះសហគមន៍សន្មតថា លោកម៉ាកុសជាអ្នកនិពន្ធគម្ពីរដំណឹងល្អទីបីនេះ។

លោកម៉ាកុសពុំមែនជាគ្រីស្តទូតទេ។ ប្រហែលលោកជាយុវជនដែលតាមមើលព្រះយេស៊ូក្នុងសួនឧទ្យានកេសេម៉ានី ហើយរត់គេចទាំងខ្លួនទទេ (មក ១៤,៥១-៥២)។ លោកឈ្មោះយ៉ូហាន-ម៉ាកុស ម្ដាយឈ្មោះម៉ារីគ្រីស្តបរិស័ទក្រុងយេរូសាឡឹមតែងតែជួបជុំគ្នានៅផ្ទះគាត់ (កក ១២,១២) លោកធ្វើដំណើរប្រកាសដំណឹងល្អជាមួយគ្រីស្តទូតប៉ូល រួចរត់ទៅផ្ទះវិញ (១៣,៥-១៣) បណ្តាលឲ្យគ្រីស្តទូតប៉ូលនិងបារណាបាទាស់ទែងគ្នា (កក ១៥,៣៦) រួចលោករស់នៅជាមួយគ្រីស្តទូតប៉ូល នៅក្រុងអេភេសូ (កូឡ ៤,១០) ហើយនៅជាមួយគ្រីស្តទូតសិលានៅ "ក្រុងបាប៊ីឡូន" គឺនៅក្រុងរ៉ូម (១ សល ៥,១៣)។

នៅគ,ស ១២៥ លោកប៉ាពីយ៉ា ជាអភិបាលព្រះសហគមន៍ក្រុងយេរូប៉ូលិស សរសេរថា លោកម៉ាកុសជាអ្នកបកស្រាយសេចក្តីបង្រៀនរបស់គ្រីស្តទូតសិលា។ នេះជារបៀបព្រះសហគមន៍ដើមដំបូងបញ្ជាក់ថា សេចក្ដីដែលមានចែងក្នុងគម្ពីរទីបីនេះ ពិតជាស្របតាមជំនឿរបស់ក្រុមគ្រីស្តទូតមែន។

លោកម៉ាកុសនិពន្ធគម្ពីរដំណឹងល្អនេះមុនគេ គឺប្រហែលជានៅចន្លោះគ.ស.៦៥-៧០ គឺប្រមាណជាសាមសិបឆ្នាំ ក្រោយព្រះយេស៊ូសោយទិវង្គត។

## គោលបំណងលោកម៉ាកុស

លោកម៉ាកុសនិពន្ធសៀវភៅក្រោមចំណងជើង "*ដំណឹងល្អ*" នេះ ដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទនៅក្រុងរ៉ូម ដែលព្រះចៅអធិរាជណេរ៉ុងបៀតបៀនធ្វើបាបយ៉ាងឃោឃៅបំផុត។ ពួកគេនាំគ្នាសង្ស័យអំពីជំនឿរបស់ខ្លួនថា ព្រះយេស៊ូពិតជាព្រះគ្រីស្តមែនឬអត់?។ ដូច្នេះ លោកមានបំណងពន្យល់ថា ព្រះយេស៊ូពិតជាព្រះគ្រីស្តដែលជនជាតិយូដាទន្ទឹងរង់ចាំឲ្យយាងមករំដោះពួកគេ តែជាព្រះគ្រីស្តត្រូវរងទុក្ខលំបាកមុនចូលសិរីរុងរឿងរបស់ព្រះអង្គ។ ព្រះអង្គប្រោសអ្នកជំងឺឲ្យជាសះស្បើយ ដេញខ្មោចចេញពីមនុស្ស និងប្រៀនប្រដៅអ្នកស្រុក ក្នុងឋានៈជាអ្នកមានអំណាច ទុកជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ គឺព្រះអង្គហៀបនឹងត្រួតត្រាមនុស្សលោក និងសង្គ្រោះគេ។ ព្រះអង្គតែងមានព្រះបន្ទូលហាមប្រាមអស់អ្នកដែលស្គាល់ឋានៈរបស់ព្រះអង្គ មិនឲ្យប្រាប់នរណាដឹងឡើយ។ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យប្រជាជនស្គាល់ឋានៈរបស់ព្រះអង្គភ្លាមៗទេ ក្រែងពួកគេយល់ច្រឡំថា ព្រះអង្គជាព្រះគ្រីស្តដែលមានអំណាចតាមរបៀបស្ដេចក្នុងលោកនេះ។

លោកម៉ាកូសធ្វើឲ្យអ្នកអានក័ណ្ឌគម្ពីរនេះនឹកឆ្ងល់ក្នុងចិត្តថា៖ «តើលោកយេស៊ូមានឋានៈអ្វី បានជាលោកធ្វើការអស្ចារ្យទាំងនោះកើត?»។ ពេលយើងអានក័ណ្ឌគម្ពីរនេះចប់សព្វគ្រប់ហើយ យើងមុខជានឹងយល់ឃើញដូចនាយទាហានរ៉ូម៉ាំងថា៖ «លោកយេស៊ូពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន!» (មក ១៥,៣៩)។

## ម្លប់គម្ពីរម៉ាកូស៖

- សេចក្តីផ្តើម៖ ឋានៈដ៏លាក់កំបាំងរបស់ព្រះយេស៊ូ (១, ១-១៣)

- ព្រះយេស៊ូជាព្រះគ្រីស្ត (១, ១៤-៨, ៣០)

- ព្រះយេស៊ូជាព្រះបុត្រាដែលបូជាព្រះជន្ម (៨, ៣១-១៥,៤៧)

- ពាក្យបញ្ចប់៖ ព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿងគង់នៅជាមួយយើង (១៦, ១ - ៨)

# ដំណឹងល្អតាមលោកម៉ាកុស

## ព្រះយេស៊ូជាលោកម៉ូសេថ្មី ជាព្រះគ្រីស្ត និងជាព្រះអម្ចាស់

(ម៉ាថាយ៣, ១-៦,១១-១២; លូកា៣, ១-១៨)

១ ១ដើមដំបូង នៃដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ២ក្នុងគម្ពីរព្យាការីអេសាយ មានចែងទុកមកថា៖

*«យើងចាត់ទូតយើង ឲ្យទៅមុខលោក ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គ»។*

៣ មានសំឡេងបុរសម្នាក់ ស្រែកនៅវាលរហោស្ថានថា៖ *"ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ"»*[ក]។

៤លោកយ៉ូហានជាអ្នកធ្វើពិធីជ្រមុជទឹក មកដល់វាលរហោស្ថាន ស្របតាមបទគម្ពីរនេះមែន។ លោកប្រកាស ឲ្យមនុស្សម្នាទទួលពិធីជ្រមុជទឹកបញ្ជាក់ថា គេប្រែចិត្តគំនិត ដើម្បីព្រះជាម្ចាស់លើកលែងទោសឲ្យរួចពីបាប។ ៥អ្នកស្រុកយូដាទាំងអស់ និងអ្នកក្រុងយេរូសាឡឹមទាំងមូល នាំគ្នាចេញទៅរកលោក។ គេទទួលសារភាពអំពើបាបរបស់ខ្លួន ហើយទទួលពិធីជ្រមុជទឹកពីលោក ក្នុងទន្លេយ័រដាន់។ ៦លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ ពាក់ខ្សែក្រវាត់ធ្វើពីស្បែក ហើយបរិភោគកណ្ដូប និងទឹកឃ្មុំ។ ៧លោកប្រកាសថា៖ «លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ នឹងមកតាមក្រោយខ្ញុំ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែឱនស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង។ ៨ខ្ញុំបានធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹងជ្រមុជអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ»។

## ពិធីអភិសេកព្រះយេស៊ូ ជាព្រះគ្រីស្ត

(ម៉ាថាយ ៣,១៣-១៧; ៤,១-១១ លូកា ៣,២១-២២; ៤,១-២)

៩នៅគ្រានោះ ព្រះយេស៊ូយាងមកពីភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ហើយទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន ក្នុងទន្លេយ័រដាន់។ ១០ពេលព្រះអង្គយាងឡើងពីទឹកភ្លាម ទ្រង់ទតឃើញផ្ទៃមេឃរហែក ហើយព្រះវិញ្ញាណយាងចុះដូចសត្វព្រាប មកលើព្រះអង្គ។ ១១មានឮព្រះសូរសៀងពីលើមេឃមកថា៖ «លោកជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងលោកណាស់!»។

១២រំពេចនោះ ព្រះវិញ្ញាណក៏ជម្រុញព្រះយេស៊ូឆ្ពោះទៅវាលរហោស្ថាន។ ១៣ព្រះអង្គគង់នៅវាលរហោស្ថាន ត្រូវមារសាតាំងល្បួងអស់រយៈពេលសែសិបថ្ងៃ។ ព្រះអង្គគង់នៅជាមួយសត្វព្រៃ ហើយមានពពួកទេវទូតបម្រើព្រះអង្គ។

## ព្រះយេស៊ូរួមជាមួយព្រះសហគមន៍

(ម៉ាថាយ ៤,១២-២២ លូកា ៤,១៤-១៥; ៥,១-១១)

១៤ក្រោយលោកយ៉ូហានត្រូវគេចាប់បញ្ជូនទៅឃុំឃាំង ព្រះយេស៊ូយាងទៅស្រុកកាលីឡេ ហើយប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ ១៥ព្រះអង្គមានព្រះបន្ទូលថា៖ «ពេលកំណត់មកដល់ គឺព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់កើតរូបរាងហើយ។ ព្រះជាម្ចាស់ក៏ហៀបនឹងគ្រងរាជ្យដែរ។ ចូរនាំគ្នាប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អចុះ!»។

១៦ព្រះ យេស៊ូ យាង តាម ឆ្នេរ សមុទ្រ កាលីឡេ ព្រះអង្គទតឃើញលោកស៊ីម៉ូន និងលោកអន់ដ្រេ

ជាប្អូន កំពុងតែបង់សំណាញ់ក្នុងសមុទ្រ ព្រោះអ្នក
ទាំងពីរជាអ្នកនេសាទត្រី។ ១៧ព្រះអង្គមានព្រះបន្ទូល
ទៅគេថា៖ «សុំអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងឲ្យអ្នកទៅជា
អ្នកនេសាទមនុស្សវិញ»។ ១៨អ្នកទាំងពីរក៏ទុក
សំណាញ់ភ្លាម ហើយដើរតាមព្រះអង្គទៅ។
១៩ព្រះយេស៊ូយាងទៅមុខបន្តិច ព្រះអង្គទត
ឃើញលោកយ៉ាកុប និងលោកយ៉ូហានជាប្អូនកំពុង
តែរៀបចំអួននៅក្នុងទូក អ្នកទាំងពីរជាកូនលោកសេ
បេដេ។ ២០ព្រះអង្គត្រាស់ហៅអ្នកទាំងពីរភ្លាម គេក៏
ទុកឪពុកឲ្យនៅក្នុងទូក ជាមួយពួកកូនឈ្នួល ហើយ
ដើរតាមព្រះយេស៊ូទៅ។

## ព្រះយេស៊ូប្រកបដោយអំណាចខាងសាសនា

(លូកា ៤, ៣១-៣៧)

២១ព្រះយេស៊ូយាងចូលក្រុងកាផានុម ជាមួយ
ក្រុមសាវ័ក*។ នៅថ្ងៃសប្ប័ទ ព្រះយេស៊ូយាងចូលក្នុង
ធម្មសាលាភ្លាម ហើយបង្រៀនគេ។ ២២គេងឿងឆ្ងល់
យ៉ាងខ្លាំង អំពីបែបបទដែលព្រះអង្គបង្រៀន ព្រោះ
ព្រះអង្គបង្រៀនគេដូចអ្នកមានអំណាច មិនមែនដូច
ពួកធម្មាចារ្យទេ។ ២៣ពេលនោះ ក្នុងធម្មសាលាមាន
បុរសខ្មោចចូលម្នាក់ ស្រែកឡើងថា៖ ២៤«ព្រះយេស៊ូ
ជាអ្នកភូមិណាសារ៉ែតអើយ! តើព្រះអង្គចង់ធ្វើអ្វី
យើង? ព្រះអង្គមកបំផ្លាញយើងឬ! ខ្ញុំស្គាល់ព្រះអង្គ
ហើយ គឺព្រះអង្គជាអ្នកដ៏វិសុទ្ធរបស់ព្រះជាម្ចាស់»។
២៥ព្រះយេស៊ូគំរាមខ្មោចនោះថា៖ «ស្ងៀម! ចេញពី
អ្នកនេះភ្លាម!»។ ២៦ខ្មោចក៏ធ្វើឲ្យបុរសនោះដួល
ប្រកាច់ប្រកិន ហើយវាចេញទៅទាំងស្រែកយ៉ាងខ្លាំង
ផង។ ២៧មនុស្សម្នាទាំងអស់ភ័យស្រឡាំងកាំង គេ
និយាយគ្នាទៅវិញទៅមកថា៖ «ម្ដេចក៏អស្ចារ្យម្ល៉េះ!
លោកបង្រៀនតាមរបៀបថ្មី ប្រកបដោយអំណាច។
លោកបញ្ជាទៅខ្មោច ហើយខ្មោចស្ដាប់បង្គាប់
លោក»។ ២៨ព្រះកិត្តិនាមរបស់ព្រះយេស៊ូល្បីខ្ចរ
ខ្ចាយ ពាសពេញតំបន់កាលីឡេទាំងមូល។

## ព្រះយេស៊ូនៅផ្ទះនិងនៅទីផ្សារ

(ម៉ាថាយ ៨,១៤-១៥ លូកា ៤, ៣៨-៤១)

២៩ព្រះយេស៊ូនិងក្រុមសាវ័ក នាំគ្នាចេញពីធម្ម
សាលាភ្លាម ទៅផ្ទះលោកស៊ីម៉ូននិងលោកអន់ដ្រេ
ដោយមានលោកយ៉ាកុប និង លោកយ៉ូហាន ទៅ
ជាមួយដែរ។ ៣០ម្ដាយក្មេករបស់លោកស៊ីម៉ូនកំពុងតែ
គ្រុន សម្រាន្តនៅលើគ្រែ។ គេទូលព្រះយេស៊ូ អំពី
គាត់ភ្លាម។ ៣១ព្រះអង្គយាងចូលទៅជិត ចាប់ដៃគាត់
ឲ្យក្រោកឡើង គាត់ក៏បាត់គ្រុន ហើយបម្រើភ្ញៀវ។
៣២លុះដល់ល្ងាច ក្រោយពេលថ្ងៃលិច គេនាំ
អ្នកជំងឺ និងមនុស្សខ្មោចចូលទាំងអស់ មកគាល់ព្រះ
យេស៊ូ។ ៣៣អ្នកក្រុងទាំងប៉ុន្មានមកផ្ដុំគ្នានៅមាត់ទ្វារ
ក្រុង។ ៣៤ព្រះយេស៊ូប្រោសមនុស្សជាច្រើននាក់
ដែលមានជំងឺផ្សេងៗ ឲ្យបានជាសះស្បើយ ហើយ
ព្រះអង្គដេញខ្មោចជាច្រើន ចេញពីមនុស្សផង។ ព្រះ
អង្គមិនបណ្ដោយឲ្យខ្មោចនិយាយជាដាច់ខាត ពី
ព្រោះពួកវាដឹងឋានៈរបស់ព្រះអង្គ។

## បេសកកម្មរបស់ព្រះយេស៊ូ

(ម៉ាថាយ ៤, ២៣ លូកា ៤, ៤១-៤៤)

៣៥ព្រឹកឡើង យប់ជ្រៅនៅឡើយ ព្រះយេស៊ូ
តើនឡើង យាងចេញពីផ្ទះ ទៅកន្លែងមួយស្ងាត់
ហើយអធិស្ឋាននៅទីនោះ។ ៣៦លោកស៊ីម៉ូន និងអ្នក
ដែលនៅជាមួយគាត់ នាំគ្នាតាមរកព្រះអង្គ។ ៣៧លុះ
ជួបហើយ គេទូលថា៖ «គេខំស្វែងរកលោកគ្រប់ៗ
គ្នា»។ ៣៨ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «
យើងនាំគ្នាទៅកន្លែងផ្សេងៗ គឺទៅភូមិឯទៀតៗដែល
នៅជិតនេះ ដើម្បីឲ្យខ្ញុំប្រកាសដំណឹងល្អនៅទីនោះ
ដែរ ដ្បិតខ្ញុំចេញមក ដើម្បីបំពេញការនេះឯង»។
៣៩ព្រះអង្គយាងទៅគ្រប់ទីកន្លែង ក្នុងស្រុកកា

លីទ្បេ ហើយប្រកាសដំណឹងល្អនៅតាមធម្មសាលាទាំងឡាយរបស់គេ ព្រមទាំងដេញខ្មោចចេញពីមនុស្សផង។

## ព្រះយេស៊ូនិងអ្នករស់ក្រៅសង្គម

(ម៉ាថាយ៨, ១-៤លូកា៥, ១២-១៦)

៤០មនុស្សឃ្លង់ម្នាក់ ចូលមករកព្រះយេស៊ូ។ គាត់លុតជង្គង់ទូលអង្វរព្រះអង្គថា៖ «ប្រសិនបើលោកចង់[ក] លោកអាចប្រោសខ្ញុំប្របាទឲ្យបានជាស្អាតបរិសុទ្ធ»។ ៤១ព្រះយេស៊ូមានព្រះហឫទ័យអាណិតមេត្តាដល់គាត់[ខ] ព្រះអង្គក៏លូកព្រះហស្តទៅពាល់គាត់ ទាំងមានព្រះបន្ទូលមកគាត់ថា៖ «ខ្ញុំចង់ ចូរឲ្យបានជាស្អាតបរិសុទ្ធចុះ!»។ ៤២ជំងឺឃ្លង់ក៏បាត់ពីគាត់ ហើយគាត់បានជាស្អាតបរិសុទ្ធភ្លាម។ ៤៣បន្ទាប់មក ព្រះយេស៊ូដេញគាត់ឲ្យចេញទៅភ្លាម ទាំងមានព្រះបន្ទូលយ៉ាងតឹងរ៉ឹងថា៖ ៤៤«ចូរប្រយ័ត្ន កុំនិយាយប្រាប់ឲ្យនរណាដឹងឡើយ! ផ្ទុយទៅវិញ ចូរទៅបង្ហាញខ្លួនដល់លោកបូជាចារ្យ និងថ្វាយតង្វាយដូចលោកម៉ូសេបានបង្គាប់ទុក ព្រោះអ្នកបានជាស្អាតបរិសុទ្ធមែន ដើម្បីទៅជាសក្ខីភាពដល់អស់លោក»។ ៤៥ប៉ុន្តែ បុរសនោះចេញទៅចាប់ផ្តើមប្រកាសដំណឹងល្អយ៉ាងខ្លាំង និងផ្សព្វផ្សាយរឿងនេះ។ ហេតុនេះហើយបានជាព្រះយេស៊ូមិនអាចយាងចូលទីក្រុងឲ្យគេឃើញឡើយ គឺព្រះអង្គគង់នៅតែកន្លែងស្ងាត់ៗ ហើយមានមនុស្សពីគ្រប់ទិសទី នាំគ្នាមកគាល់ព្រះអង្គ។

## ព្រះយេស៊ូប្រោសអ្នកបាបឲ្យក្រោកឈរឡើង

(ម៉ាថាយ ៩, ១-៨ លូកា ៥,១៧-២៦)

២ ១ប៉ុន្មានថ្ងៃក្រោយមក ព្រះយេស៊ូយាងត្រឡប់មកក្រុងកាផានុមវិញ ហើយអ្នកស្រុកឮដំណឹងថា ព្រះអង្គគង់នៅក្នុងផ្ទះ។ ២មានមនុស្សយ៉ាងច្រើន មកមូលផ្តុំគ្នាកកកុញ គ្មានសល់កន្លែងណាសោះឡើយ សូម្បីតែនៅមាត់ទ្វារផ្ទះក៏គ្មានសល់ដែរ។ ព្រះយេស៊ូថ្លែងព្រះបន្ទូល ឲ្យគេស្តាប់។ ៣មានបុរសបួននាក់សែងមនុស្សខ្វិនម្នាក់ មករកព្រះអង្គ។ ៤ប៉ុន្តែដោយមានមនុស្សច្រើនពេក គេពុំអាចនាំមនុស្សខ្វិននោះទៅជិតព្រះអង្គបានឡើយ។ ដូច្នេះគេក៏ចោះដំបូលផ្ទះចំពីលើកន្លែងដែលព្រះអង្គគង់ ហើយសម្រូតមនុស្សខ្វិននៅលើគ្រែស្នែង ចុះតាមប្រឡោះមក។ ៥កាលព្រះយេស៊ូឃើញជំនឿរបស់អ្នកទាំងនោះ ព្រះអង្គមានព្រះបន្ទូលទៅកាន់មនុស្សខ្វិនថា៖ «កូនអើយ! ព្រះជាម្ចាស់លើកលែងទោស ឲ្យអ្នកបានរួចពីបាបហើយ»។ ៦ពួកធម្មាចារ្យខ្លះដែលអង្គុយនៅទីនោះ រិះគិតក្នុងចិត្តថា៖ ៧«ហេតុដូចម្តេច បានជាអ្នកនេះនិយាយដូច្នេះ? គាត់ប្រមាថព្រះជាម្ចាស់ ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ តើនរណាអាចអត់ទោសមនុស្សឲ្យរួចពីបាបបាន!»។ ៨ព្រះយេស៊ូឈ្វេងយល់ចិត្តគំនិតរបស់គេភ្លាម ទ្រង់មានព្រះបន្ទូលទៅគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារិះគិតដូច្នេះ? ៩បើខ្ញុំប្រាប់អ្នកពិការនេះថា "ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាបហើយ"ឬថា "ចូរក្រោកឡើងយកគ្រែស្នែងរបស់អ្នកដើរទៅចុះ" តើឃ្លាមួយណាស្រួលនិយាយជាង? ១០ប៉ុន្តែខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថាបុត្រមនុស្សមានអំណាចនឹងអត់ទោសឲ្យមនុស្ស នៅលើផែនដីនេះរួចពីបាបបាន»។ ព្រះអង្គងាកទៅរកអ្នកខ្វិន ហើយមានព្រះបន្ទូលថា៖ ១១«ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នក ដើរទៅផ្ទះវិញទៅ!»។ ១២មនុស្សខ្វិនក៏ក្រោកឈរឡើងភ្លាម យកគ្រែស្នែងរបស់ខ្លួន ដើរកាត់មុខមនុស្សទាំងអស់ចេញទៅធ្វើឲ្យគេគ្រប់គ្នាស្ញប់ស្ញែងយ៉ាងខ្លាំង ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ទាំងពោលថា៖ «យើងមិនដែលបានឃើញការអស្ចារ្យណាមួយ ដូចពេលនេះឡើយ!»។

## លោកយ៉ូហានបាទីស្ដប្រៀនប្រដៅបណ្ដាជន

(ម៉ាថាយ ៣, ១-៦,១១-១២; លូកា៣, ១-១៨)

១[១]ដំណឹងល្អ*អំពីព្រះយេស៊ូគ្រីស្ដ* ជាព្រះបុត្រារបស់
ព្រះជាម្ចាស់ ចាប់ផ្ដើមដូចតទៅ៖ [២]ក្នុងគម្ពីរព្យាការីអេ
សាយ មានចែងទុកមកថា៖

*«យើងចាត់ទូតយើងឲ្យទៅមុនព្រះអង្គ*
*ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គ»។*
៣ *មានសំឡេងបុរសម្នាក់ស្រែកនៅវាលរហោ*
*ស្ថានថា:"ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់*
*ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ"»។*

[៤]ពេលនោះ លោកយ៉ូហានមកដល់ស្របតាម
បទគម្ពីរនេះមែន ហើយធ្វើពិធីជ្រមុជទឹក*នៅវាល
រហោស្ថាន។ លោកប្រកាសឲ្យមនុស្សម្នាប្រែចិត្ត
គំនិតដោយទទួលពិធីជ្រមុជទឹក ដើម្បីព្រះជាម្ចាស់
លើកលែងទោសឲ្យរួចពីបាប។ [៥]អ្នកស្រុកយូដាទាំង
អស់ និងអ្នកក្រុងយេរូសាឡឹមទាំងមូល នាំគ្នាចេញ
ទៅរកលោក។ គេទទួលសារភាពអំពើបាបរបស់ខ្លួន
ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងទន្លេយ័រដា
ន់។ [៦]លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើពីរោមអូ
ដ្ឋ ពាក់ខ្សែក្រវាត់ធ្វើពីស្បែក ហើយបរិភោគក
ណ្ដូប និងទឹកឃ្មុំ។ [៧]លោកប្រកាសប្រាប់បណ្ដាជន
ថា៖ «លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ នឹងមកតាម
ក្រោយខ្ញុំ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែអោន
ស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈ
ដ៏ខ្ពង់ខ្ពស់របស់លោកផង។ [៨]ខ្ញុំបានធ្វើពិធីជ្រមុជឲ្យ
អ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹងធ្វើពិធី
ជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ*»។

## ព្រះយេស៊ូទទួលពិធីជ្រមុជទឹក ព្រះអង្គឈ្នះការល្បួង

(ម៉ាថាយ ៣,១៣-១៧;៤,១-១១ លូកា ៣,២១-២២;៤,១-២)

[៩]នៅគ្រានោះ ព្រះយេស៊ូយាងមកពីភូមិណាសា
រ៉ែតក្នុងស្រុកកាលីឡេ។ ព្រះអង្គបានទទួលពិធីជ្រមុជ
ទឹក*ពីលោកយ៉ូហាន ក្នុងទន្លេយ័រដាន់។ [១០]ពេលព្រះ
អង្គយាងឡើងពីទឹកមកភ្លាម ទ្រង់ទតឃើញផ្ទៃមេឃ
របើកជាពីរ ហើយព្រះវិញ្ញាណយាងចុះដូចសត្វ
ព្រាប មកសណ្ឋិតលើព្រះអង្គ។ [១១]មានឮព្រះសូរ
សៀងពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទី
ស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គ
ណាស់!»។

[១២]រំពេចនោះ ព្រះវិញ្ញាណក៏នាំព្រះយេស៊ូឆ្ពោះ
ទៅវាលរហោស្ថាន។ [១៣]ព្រះអង្គគង់នៅវាលរហោ
ស្ថានអស់រយៈពេលសែសិបថ្ងៃ ត្រូវមារ*សាតាំងល្បួ
ង។ ព្រះអង្គគង់នៅជាមួយសត្វព្រៃ ហើយមានពួក
ទេវទូត*បម្រើព្រះអង្គផង។

## ព្រះយេស៊ូត្រាស់ហៅសាវ័កបួនរូប

(ម៉ាថាយ ៤, ១២-២២ លូកា ៤, ១៤-១៥; ៥,១-១១)

[១៤]ក្រោយគេចាប់លោកយ៉ូហានយកទៅឃុំ
ឃាំងព្រះយេស៊ូយាងទៅស្រុកកាលីឡេ ហើយ
ប្រកាសដំណឹងល្អ*របស់ព្រះជាម្ចាស់។ [១៥]ព្រះអង្គ
មានព្រះបន្ទូលថា៖ «ពេលកំណត់មកដល់ហើយ រីឯ
ព្រះរាជ្យ*របស់ព្រះជាម្ចាស់ក៏មកជិតបង្កើយដែរ។ ចូរ
នាំគ្នាប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ!»។
[១៦]កាល ព្រះយេស៊ូយាងតាមឆ្នេរសមុទ្រកាលី

ឡេ ព្រះអង្គទតឃើញលោកស៊ីម៉ូននិងលោកអន់ដ្រេ
ជាប្អូនរបស់គាត់ កំពុងតែបង់សំណាញ់ ព្រោះអ្នក
ទាំងពីរជាអ្នកនេសាទត្រី។ ១៧ព្រះអង្គមានព្រះបន្ទូល
ទៅគេថា៖ «សុំអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យ
នេសាទមនុស្សវិញ»។ ១៨អ្នកទាំងពីរក៏ទុកសំណាញ់
នៅទីនោះភ្លាម រួចដើរតាមព្រះអង្គទៅ។

១៩កាលព្រះយេស៊ូយាងទៅមុខបន្តិច ព្រះអង្គ
ទតឃើញលោកយ៉ាកុប និងលោកយ៉ូហានជាប្អូន
កំពុងតែរៀបចំអួននៅក្នុងទូកមួយ អ្នកទាំងពីរជាកូន
លោកសេបេដេ។ ២០ព្រះអង្គត្រាស់ហៅអ្នកទាំងពីរ
ភ្លាម គេក៏ដើរតាមព្រះយេស៊ូទៅទុកឪពុកឲ្យនៅក្នុង
ទូកជាមួយពួកកូនឈ្នួល។

## ព្រះយេស៊ូប្រោសបុរសម្នាក់ដែលមានខ្មោចចូល

(លូកា ៤, ៣១-៣៧)

២១ព្រះយេស៊ូយាងចូលក្រុងកាផានុម ជាមួយ
ពួកសាវ័ក*។ នៅថ្ងៃសប្ប័ទ*ព្រះយេស៊ូយាងចូលក្នុង
ធម្មសាលា* ហើយព្រះអង្គបង្រៀនអ្នកស្រុក។ ២២
អ្នកដែលបានស្ដាប់ព្រះអង្គ ងឿងឆ្ងល់យ៉ាងខ្លាំងអំពី
បែបបទដែលព្រះអង្គបង្រៀន ព្រោះព្រះអង្គមានព្រះ
បន្ទូល ប្រកបដោយអំណាចខុសប្លែកពីពួកធម្មាចារ្យ*
។ ២៣នៅពេលនោះ ក្នុងធម្មសាលា*មានបុរសម្នាក់
ដែលខ្មោចចូលស្រែកឡើងថា៖ ២៤«ព្រះយេស៊ូជា
អ្នកភូមិណាសារ៉ែតអើយ! តើព្រះអង្គចង់ធ្វើអ្វីយើង?
ព្រះអង្គមកបំផ្លាញយើង! ខ្ញុំស្គាល់ព្រះអង្គហើយ ព្រះ
អង្គជាព្រះដ៏វិសុទ្ធដែលមកពីព្រះជាម្ចាស់»។ ២៥ព្រះ
យេស៊ូគំរាមខ្មោចនោះថា៖ «ស្ងៀម! ចេញពីអ្នកនេះ
ភ្លាម!»។ ២៦ខ្មោចក៏ធ្វើឲ្យបុរសនោះដួលប្រកាច់ប្រ
កិន ហើយវាចេញទៅទាំងស្រែកយ៉ាងខ្លាំងផង។ ២៧
មនុស្សម្នាទាំងអស់ភ័យស្រឡាំងកាំង គេនិយាយគ្នា
ទៅវិញទៅមកថា៖ «ម្ដេចក៏អស្ចារ្យម្ល៉េះ! លោក
បង្រៀនតាមរបៀបថ្មីប្រកបដោយអំណាច។ លោក
បញ្ជាទៅខ្មោច ហើយខ្មោចក៏ស្ដាប់បង្គាប់លោក»។
២៨ព្រះកិត្តិនាមរបស់ព្រះយេស៊ូល្បីខ្ចរខ្ចាយ ពាស
ពេញតំបន់កាលីឡេទាំងមូល។

## ព្រះយេស៊ូប្រោសអ្នកជំងឺជាច្រើនឲ្យបានជា

(ម៉ាថាយ ៨,១៤-១៥ លូកា ៤, ៣៨-៤១)

២៩ព្រះយេស៊ូនិងសាវ័ក*នាំគ្នាចេញពីធម្ម
សាលាទៅផ្ទះលោកស៊ីម៉ូននិងលោកអន់ដ្រេ លោក
យ៉ាកុបនិងលោកយ៉ូហាន ក៏ទៅជាមួយដែរ។ ៣០ម្ដា
យក្មេករបស់លោកស៊ីម៉ូនកំពុងតែគ្រុន សំរាន្តនៅលើ
គ្រែ។ ពេលព្រះយេស៊ូយាងទៅដល់ គេទូលព្រះអង្គ
ភ្លាមថា គាត់ឈឺ។ ៣១ព្រះអង្គយាងចូលទៅជិតចាប់
ដៃគាត់ ឲ្យក្រោកឡើង គាត់ក៏បាត់គ្រុន ហើយបម្រើ
ភ្ញៀវ។

៣២លុះដល់ល្ងាច ក្រោយពេលថ្ងៃលិច គេនាំ
អ្នកជំងឺនិងមនុស្សខ្មោចចូលទាំងអស់ មករកព្រះយេ
ស៊ូ។ ៣៣អ្នកក្រុងទាំងប៉ុន្មានមកផ្ដុំគ្នានៅមាត់ទ្វារក្រុ
ង។ ៣៤ព្រះយេស៊ូប្រោសមនុស្សជាច្រើននាក់ដែល
មានជំងឺផ្សេងៗ ឲ្យបានជាសះស្បើយ ហើយព្រះអង្គ
ដេញខ្មោចជាច្រើន ចេញពីមនុស្សផងព្រះអង្គមិន
អនុញ្ញាតឲ្យខ្មោចនិយាយ ជាដាច់ខាត ពីព្រោះពួកវា
ដឹងឋានៈរបស់ព្រះអង្គ។

## ព្រះយេស៊ូយាងចាកចេញពីក្រុងកាផានុម

(ម៉ាថាយ ៤, ២៣ លូកា ៤, ៤១-៤៤)

៣៥ព្រឹកឡើង កាលងងឹតនៅឡើយ ព្រះយេស៊ូ
តើនឡើង ទ្រង់យាងចេញពីផ្ទះ ទៅកន្លែងមួយស្ងាត់
ហើយអធិស្ឋាន*នៅទីនោះ។ ៣៦លោកស៊ីម៉ូន និង
អ្នកដែលនៅជាមួយគាត់ នាំគ្នាតាមរកព្រះអង្គ។ ៣៧
លុះបានជួបហើយ គេទូលថា៖ «គេខំស្វែងរកលោក
គ្រប់ៗគ្នា»។ ៣៨ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេ

ថា៖ «យើងត្រូវនាំគ្នាទៅភូមិឯទៀតៗដែលនៅជិត
នេះ ខ្ញុំត្រូវប្រកាសដំណឹងល្អ*នៅទីនោះដែរ ដ្បិតខ្ញុំ
ចេញមក ដើម្បីបំពេញការនេះឯង»។
[៣៩]ព្រះអង្គយាងទៅគ្រប់ទីកន្លែង ក្នុងស្រុកកា
លីឡេ ហើយប្រកាសដំណឹងល្អ* នៅតាមធម្ម
សាលា*ទាំងឡាយ ព្រមទាំងដេញខ្មោចចេញពី
មនុស្សផង។

## ព្រះយេស៊ូប្រោសមនុស្សឃ្លង់ម្នាក់ឲ្យជា

(ម៉ាថាយ ៨, ១-៤ លូកា ៥, ១២-១៦)

[៤០]មានមនុស្សឃ្លង់ម្នាក់ ចូលមករកព្រះយេស៊ូ
គាត់លុតជង្គង់ទូលអង្វរព្រះអង្គថា៖ «ប្រសិនបើ
លោកមិនយល់ទាស់ទេ សូមប្រោសខ្ញុំប្របាទឲ្យបាន
ជាស្អាតបរិសុទ្ធ*ផង»។ [៤១]ព្រះ យេស៊ូមានព្រះហឫ
ទ័យអាណិតអាសូរគាត់[ឃ] ពន់ពេកណាស់ព្រះអង្គក៏
លូកព្រះហស្ដទៅពាល់គាត់ ទាំងមានព្រះបន្ទូលថា៖
«ខ្ញុំយល់ព្រមហើយ ចូរឲ្យបានជាស្អាតបរិសុទ្ធចុះ!»
។ [៤២]មនុស្សឃ្លង់ក៏បានជាស្អាតបរិសុទ្ធភ្លាម។ [៤៣]
បន្ទាប់មក ព្រះយេស៊ូដេញគាត់ឲ្យចេញទៅភ្លាម ទាំង
មានព្រះបន្ទូលយ៉ាងតឹងរឹងថា៖ [៤៤]«ចូរប្រយ័ត្នឲ្យ
មែនទែនកុំនិយាយហេតុការណ៍នេះប្រាប់ឲ្យនរណា
ដឹងឡើយ! ផ្ទុយទៅវិញត្រូវទៅបង្ហាញខ្លួនដល់លោក
បូជាចារ្យ*រួចថ្វាយតង្វាយ ដូចលោកម៉ូសេ*បាន
បង្គាប់ទុក ដើម្បីជាសក្ខីភាពបញ្ជាក់ថា អ្នកបានជា
ស្អាតបរិសុទ្ធមែន»។ [៤៥]ប៉ុន្តែបុរសនោះចេញទៅ
ប្រកាស និងផ្សព្វផ្សាយរឿងនេះនៅគ្រប់កន្លែងឲ្យគេ
ដឹង។ ហេតុនេះហើយបានជាព្រះយេស៊ូមិនអាច
យាងចូលទីក្រុង ដូចពីមុនបានទៀតឡើយគឺព្រះអង្គ
គង់នៅតែខាងក្រៅទីក្រុង ត្រង់កន្លែងស្ងាត់ៗហើយ
មានមនុស្សពីគ្រប់ទិសទី នាំគ្នាមកគាល់ព្រះអង្គ។

## ព្រះយេស៊ូប្រោស មនុស្សខ្វិនម្នាក់ឲ្យបាន ជា

(ម៉ាថាយ ៩, ១-៨ លូកា ៥, ១៧-២៦)

២ [១]ប៉ុន្មានថ្ងៃក្រោយមក ព្រះយេស៊ូយាងត្រឡប់មក
ក្រុងកាផានុមវិញ ហើយអ្នកស្រុកឮដំណឹងថាព្រះអង្គ
គង់នៅក្នុងផ្ទះ។ [២]មានមនុស្សយ៉ាងច្រើនមកមូលផ្ដុំ
គ្នាកកកុញ គ្មានសល់កន្លែងណាសោះឡើយ សូម្បី
តែនៅមាត់ទ្វារផ្ទះក៏គ្មានសល់ដែរ។ ព្រះយេស៊ូថ្លែង
ព្រះបន្ទូល ឲ្យគេស្ដាប់។ [៣]មានបុរសបួននាក់សែង
មនុស្សខ្វិនដៃ ខ្វិនជើងម្នាក់មករកព្រះអង្គ។ [៤]ប៉ុន្តែ
ដោយមានមនុស្សច្រើនពេក គេពុំអាចនាំមនុស្សខ្វិន
នោះទៅជិតព្រះយេស៊ូបានឡើយ។ ដូច្នេះគេក៏ចោះ
ដំបូលផ្ទះ ចំពីលើកន្លែងដែលព្រះអង្គគង់ ហើយ
សម្រូតមនុស្សខ្វិននៅលើគ្រែស្នែង ចុះតាមប្រឡោះ
មក។ [៥]កាលព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នក
ទាំងនោះ ព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកពិការ
ថា៖ «កូនអើយ! ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាប
ហើយ»។ [៦]ពួកធម្មាចារ្យខ្លះដែលអង្គុយនៅទីនោះ រិះ
គិតក្នុងចិត្តថា៖ [៧]«ហេតុដូចម្ដេច បានជាអ្នកនេះ
ហ៊ានប្រមាថព្រះជាម្ចាស់ ដោយពោលពាក្យស្មើនឹង
ព្រះអង្គបែបនេះ?ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ តើ
នរណាអាចអត់ទោសមនុស្ស ឲ្យរួចពីបាបបាន!»។ [៨]
ព្រះយេស៊ូឈ្វេងយល់ចិត្តគំនិតរបស់គេភ្លាម ទ្រង់
មានព្រះបន្ទូលទៅគេថា៖ «ហេតុអ្វីបានជាអ្នករាល់
គ្នារិះគិតដូច្នេះ? [៩]បើខ្ញុំប្រាប់អ្នកពិការនេះថា "ខ្ញុំអត់
ទោសឲ្យអ្នកបានរួចពីបាបហើយ"ឬថា "ចូរក្រោក
ឡើងយកគ្រែស្នែងរបស់អ្នកដើរទៅចុះ" តើឃ្លាមួយ
ណាស្រួលនិយាយជាង? [១០]ប៉ុន្តែខ្ញុំចង់ឲ្យអ្នករាល់គ្នា
ដឹងថាបុត្រមនុស្សមានអំណាចនឹងអត់ទោសឲ្យ
មនុស្ស នៅលើផែនដីនេះរួចពីបាបបាន»។ ព្រះអង្គ
ងាកទៅរកអ្នកខ្វិន ហើយមានព្រះបន្ទូលថា៖ [១១]«ចូរ
ក្រោកឡើង យកគ្រែស្នែងរបស់អ្នក ដើរទៅផ្ទះវិញ

ទៅ!»។ ១២មនុស្សខ្វិនក៏ក្រោកឈរឡើងភ្លាម យក
គ្រែស្នែងរបស់ខ្លួន ដើរកាត់មុខមនុស្សទាំងអស់ចេញ
ទៅធ្វើឲ្យគេគ្រប់គ្នាស្ងប់ស្ងែងយ៉ាងខ្លាំង ហើយលើក
តម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ទាំងពោលថា៖
«យើងមិនដែលបានឃើញការអស្ចារ្យណាមួយ ដូច
ពេលនេះឡើយ!»។

## ព្រះយេស៊ូត្រាស់ហៅលោកលេវី

(ម៉ាថាយ ៩,៩-១៣ លូកា ៥,២៧-៣២)

១៣ព្រះយេស៊ូយាងតាមឆ្នេរសមុទ្រ កាលីឡេ
ម្ដងទៀត។ បណ្ដាជនទាំងមូលនាំគ្នាមករកព្រះអង្គ
ព្រះអង្គក៏បង្រៀនពួកគេ។ ១៤កាលព្រះអង្គយាងកាត់
តាមនោះ ទ្រង់ទតឃើញលោកលេវីជាកូនរបស់
លោកអាល់ផាយ អង្គុយនៅកន្លែងយកពន្ធ។ ព្រះ
យេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញមក
តាមខ្ញុំ»។ លោកលេវីក៏ក្រោកឡើង ដើរតាមព្រះអង្គ
ទៅ។

១៥បន្ទាប់មក ព្រះយេស៊ូសោយព្រះស្ងោយនៅ
ផ្ទះលោកលេវី។ មានអ្នកទារពន្ធ* ព្រមទាំងមនុស្ស
បាបជាច្រើន មករួមតុជាមួយព្រះអង្គ និងពួកសាវ័ក*
។ មានមនុស្សប្រភេទនោះច្រើននាក់បានមកតាម
ព្រះអង្គ។ ១៦ពួកធម្មាចារ្យពីគណៈផារីស៊ី*ឃើញព្រះ
យេស៊ូសោយព្រះស្ងោយ ជាមួយអ្នកទាំងនោះ គេ
និយាយទៅកាន់ពួកសាវ័កថា៖ «ហេតុអ្វីបានជា
លោកបរិភោគជាមួយអ្នកទារពន្ធ និងជាមួយមនុស្ស
បាប?»។ ១៧ព្រះយេស៊ូបានឮគេនិយាយដូច្នេះក៏
មានព្រះបន្ទូលថា៖ «មនុស្សមានសុខភាពល្អមិនត្រូវ
ការគ្រូពេទ្យឡើយ មានតែអ្នកជំងឺប៉ុណ្ណោះដែលត្រូវ
ការ។ ខ្ញុំមិនមែនមករកមនុស្សសុចរិតទេគឺខ្ញុំមករក
មនុស្សបាបវិញ»។

## អំពីការតមអាហារ

(ម៉ាថាយ ៩, ១៤-១៧ លូកា ៥,៣៣-៣៨)

១៨ថ្ងៃមួយ ពួកសិស្សរបស់លោកយ៉ូហានបាទី
ស្ដនិងពួកសិស្សខាងគណៈផារីស៊ី នាំគ្នាតមអាហារ។
ពួកគេមកទូលសួរព្រះយេស៊ូថា៖ «សិស្សរបស់
លោកយ៉ូហាន និងសិស្សខាងគណៈផារីស៊ី*តម
អាហារ ចុះហេតុដូចម្ដេចបានជាសិស្សរបស់លោក
មិនតមដូច្នេះ?»។ ១៩ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ក្នុងពិធីមង្គលការនៅពេលកូនកំឡោះនៅ
ជាមួយ តើភ្ញៀវអាចតមអាហារកើតឬ?។ ទេ!ដរាប
ណាកូនកំឡោះនៅជាមួយ គេមិនអាចតមអាហារ
បានឡើយ។ ២០ថ្ងៃក្រោយពេលគេចាប់ស្វាមីយកទៅ
ទើបភ្ញៀវទាំងនោះតមអាហារ។ ២១ពុំដែលមាន
នរណាយកក្រណាត់ថ្មី មកប៉ះសម្លៀកបំពាក់ចាស់
ឡើយ បើធ្វើដូច្នេះក្រណាត់ថ្មីនឹងបណ្ដាលឲ្យសម្លៀក
បំពាក់ចាស់ រហែកលើសដើមទៅទៀត។ ២២ពុំដែល
មាននរណាច្រកស្រាទំពាំងបាយជូរថ្មី ទៅក្នុងថង់
ស្បែកចាស់ឡើយ បើធ្វើដូច្នោះស្រានឹងធ្វើឲ្យថង់
ស្បែកនោះធ្លាយ បណ្ដាលឲ្យខូចទាំងស្រាទាំងថង់
ស្បែកជាមិនខាន។ ត្រូវច្រកស្រាថ្មីទៅក្នុងថង់ស្បែក
ថ្មី។

## ព្រះយេស៊ូមានអំណាចលើថ្ងៃសប្ប័ទ

(ម៉ាថាយ ១២, ១-៨ លូកា ៦, ១-៥)

២៣មានថ្ងៃមួយជាថ្ងៃសប្ប័ទ* ព្រះយេស៊ូយាង
កាត់វាលស្រែសាវ័ក*របស់ព្រះអង្គ នាំគ្នាដើរបណ្ដើរ
បូតកួរស្រូវបណ្ដើរ។ ២៤ពួកខាងគណៈផារីស៊ី*ទូល
ព្រះយេស៊ូថា៖ «សូមលោកមើលចុះ ហេតុអ្វីបានជា
សិស្សរបស់លោកធ្វើការ ដែលបញ្ញត្តិហាមមិនឲ្យធ្វើ
នៅថ្ងៃសប្ប័ទដូច្នេះ?»។ ២៥ព្រះយេស៊ូតបទៅគេវិញ
ថា៖ «ក្នុងគម្ពីរមានអត្ថបទមួយស្ដីអំពីការដែលព្រះ
បាទដាវីឌ និងបរិវារបានប្រព្រឹត្ត នៅពេលឃ្លាន
ហើយត្រូវការអាហារបរិភោគ។ ២៦នៅសម័យនោះ
លោកអបៀយ៉ាថារធ្វើជាមហាបូជាចារ្យ*។ ព្រះបាទដា
វីឌបានចូល ទៅក្នុងដំណាក់របស់ព្រះជាម្ចាស់យកនំ

ប៉័ងដែលគេតាំងថ្វាយព្រះជាម្ចាស់ មកសោយ ព្រម
ទាំងចែកឲ្យពួកបរិពារបរិភោគទៀតផង។ តាមវិន័យ*
មានតែពួកបូជាចារ្យ*ប៉ុណ្ណោះ ដែលមានសិទ្ធិបរិភោគ
នំប៉័ងនោះ។ តើអ្នករាល់គ្នាមិនដែលអានអត្ថបទនោះ
ទេឬ!»។ ២៧ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា
៖ «ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្ប័ទ ដើម្បីជា
ប្រយោជន៍ដល់មនុស្ស ព្រះអង្គមិនបានបង្កើតមនុស្ស
ដើម្បីឲ្យបម្រើថ្ងៃសប្ប័ទឡើយ។ ២៨ហេតុនេះហើយ
បានជាបុត្រមនុស្ស* ជាម្ចាស់លើថ្ងៃសប្ប័ទ»។

## ព្រះយេស៊ូប្រោសមនុស្សស្វិតដៃម្នាក់ឲ្យបានជា

(ម៉ាថាយ ១២, ៩-១៤ លូកា ៦, ៦-១១)

៣ ១ព្រះយេស៊ូយាងចូល ទៅធម្មសាលា*ម្ដងទៀត
នៅទីនោះមានបុរសម្នាក់ស្វិតដៃម្ខាង។ ២ពួកគេតាម
មើលព្រះយេស៊ូ ក្រែងលោព្រះអង្គប្រោសបុរសនេះ
ឲ្យជា នៅថ្ងៃសប្ប័ទ*ក្នុងគោលបំណងចោទប្រកាន់
ព្រះអង្គ។ ៣ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បុរស
ស្វិតដៃនោះថា៖ «ចូរក្រោកឡើង មកឈរនៅកណ្ដា
លគេឯណេះ!»។ ៤បន្ទាប់មក ព្រះអង្គមានព្រះបន្ទូល
សួរទៅគេថា៖ «នៅថ្ងៃសប្ប័ទ តើវិន័យអនុញ្ញាត
ឲ្យធ្វើអំពើល្អ ឬធ្វើអំពើអាក្រក់? តើត្រូវសង្គ្រោះ
មនុស្ស ឬប្រហារជីវិតចោល?»។ ពួកគេនៅស្ងៀម
ទាំងអស់គ្នា។ ៥ព្រះយេស៊ូបែរព្រះភ័ក្ត្រទតមើល ទៅ
អ្នកដែលនៅជុំវិញទាំងព្រះពិរោធ ហើយព្រះអង្គ
ព្រួយព្រះហឫទ័យ ព្រោះគេមានចិត្តរឹងរូស។ ព្រះអង្គ
មានព្រះបន្ទូលទៅកាន់បុរសស្វិតដៃនោះថា៖ «ចូរ
លាតដៃមើល៍!»។ បុរសនោះលាតដៃ ហើយដៃរបស់
គាត់ក៏បានជាដូចដើមវិញ។ ៦ពួកខាងគណៈផារីស៊ី*
ចេញពីធម្មសាលា* ហើយទៅពិគ្រោះជាមួយបក្សពួក
ស្ដេចហេរ៉ូដភ្លាម ដើម្បីរកមធ្យោបាយធ្វើគុតព្រះយេ
ស៊ូ។

## មហាជនមកតាមព្រះយេស៊ូ

៧ព្រះយេស៊ូយាងចេញ ទៅតាមឆ្នេរសមុទ្រកា
លីឡេជាមួយពួកសាវ័ក*។ មានបណ្ដាជនជាច្រើននាំ
គ្នាទៅតាមព្រះអង្គ អ្នកទាំងនោះមកពីស្រុកកាលីឡេ
ស្រុកយូដា ៨ក្រុងយេរូសាឡឹម ស្រុកអ៊ីឌុំមេ តំបន់
ត្រើយខាងនាយទន្លេយ័រដាន់ព្រមទាំងតំបន់ជុំវិញ
ក្រុងទីរ៉ូស និងក្រុងស៊ីដូន។ បណ្ដាជនមកតាមព្រះ
យេស៊ូច្រើនយ៉ាងនេះ ព្រោះបានឮគេនិយាយអំពីកិច្ច
ការទាំងប៉ុន្មាន ដែលព្រះអង្គធ្វើ។ ៩ព្រះយេស៊ូប្រាប់
ពួកសាវ័ក* ឲ្យរៀបចំទូកមួយថ្វាយព្រះអង្គក្រែងប
ណ្ដាជនប្រជ្រៀតគ្នា ចោមរោមព្រះអង្គ ១០ដ្បិតមាន
អ្នកជំងឺជាច្រើនខំប្រឹងសំរុកចូលមកជិត ដើម្បីពាល់
ព្រះអង្គ ព្រោះព្រះអង្គបានប្រោសមនុស្សជាច្រើន ឲ្យ
បានជា។ ១១ម្យ៉ាងទៀតពេលខ្មោចឃើញព្រះអង្គ វា
ក្រាបចុះនៅទៀបព្រះបាទា ហើយស្រែកឡើងថា៖«
ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់»។ ១២ប៉ុន្ដែ
ព្រះយេស៊ូបានគំរាមកំហែងវាយ៉ាងម៉ឺងម៉ាត់ មិនឲ្យ
និយាយប្រាប់គេថាព្រះអង្គជានរណាឡើយ។

## ព្រះយេស៊ូតែងតាំងគ្រីស្ដទូត ១២ រូប

(ម៉ាថាយ ១០, ១-៤ លូកា ៦, ១២-១៦)

១៣បន្ទាប់មក ព្រះយេស៊ូយាងឡើងទៅលើភ្នំ។
ព្រះអង្គបានត្រាស់ហៅអស់អ្នក ដែលព្រះអង្គសព្វ
ព្រះហឫទ័យជ្រើសរើស ហើយអ្នកទាំងនោះក៏ចូល
មកគាល់ព្រះអង្គ។ ១៤ព្រះអង្គតែងតាំងសាវ័កដប់ពីរ
រូបឲ្យគេនៅជាមួយព្រះអង្គ និងដើម្បីចាត់គេឲ្យទៅ
ប្រកាសដំណឹងល្អ ១៥ទាំងឲ្យគេមានអំណាចដេញ
អារក្សថែមទៀតផង។ ១៦ព្រះអង្គបានតែងតាំងអ្នក
ដប់ពីររូបនេះ គឺស៊ីម៉ូនដែលទ្រង់ដាក់ឈ្មោះថាសិលា
១៧យ៉ាកុបជាកូនរបស់លោកសេបេដេនិងយ៉ូហានជា
ប្អូនរបស់គាត់ដែលព្រះយេស៊ូដាក់ឈ្មោះថា "បោ
ណើរកែស" ប្រែថា"អ្នកដែលមានចិត្តខ្លាំងដូច ផ្គរ

លាន់" ១៨អន់ទ្រេ ភីលីព បាថូឡូមេ ម៉ាថាយថូម៉ាស
យ៉ាកុបជាកូនអាល់ផាយ ថាដេស៊ីម៉ូនជាអ្នកជាតិ
និយម ១៩និងយូដាអ៊ីស្ការីយ៉ុត ជាអ្នកក្បត់ព្រះអង្គ។

## ព្រះញាតិវង្សរបស់ព្រះយេស៊ូមកនាំព្រះអង្គយកទៅវិញ

២០កាលព្រះយេស៊ូយាងត្រឡប់ មកផ្ទះវិញប
ណ្តាជនជួបជុំគ្នាសាជាថ្មី ជាហេតុនាំឲ្យព្រះអង្គនិង
ពួកសាវ័ក* រកពេលបរិភោគមិនបានសោះ។ ២១ព្រះ
ញាតិវង្សរបស់ព្រះអង្គឮដំណឹងនេះ ក៏នាំគ្នាធ្វើ
ដំណើរមក ដើម្បីចាប់ព្រះអង្គទៅវិញ ព្រោះគេថាព្រះ
អង្គវង្វេងស្មារតីហើយ។

## ព្រះយេស៊ូឆ្លើយតបនឹងពួកអ្នកចោទប្រកាន់ព្រះអង្គ

(ម៉ាថាយ ១២, ២២-៣២ លូកា ១១, ១៤-២៣; ១២, ១០)

២២ពួកធម្មាចារ្យ*ដែលចុះមកពីក្រុងយេរូសា
ឡឹមនិយាយថា៖ «អ្នកនេះមានបេលសេប៊ូលជាស្តេ
ចខ្មោចនៅក្នុងខ្លួន គាត់អាចដេញខ្មោចដូច្នេះ ព្រោះ
ស្តេចខ្មោចប្រគល់អំណាចឲ្យ»។ ២៣ព្រះយេស៊ូ
ត្រាស់ហៅគេមក រួចមានព្រះបន្ទូលជាប្រស្នាថា៖«
តើមារ*សាតាំងអាចដេញមារសាតាំង ដូចម្តេចកើត?
២៤ប្រសិនបើពលរដ្ឋក្នុងនគរណាមួយបែកបាក់ទាស់
ទែងគ្នាឯង នគរនោះពុំអាចស្ថិតស្ថេរគង់វង្សតទៅមុខ
បានឡើយ។ ២៥ប្រសិនបើមានក្រុមគ្រួសារមួយបែក
បាក់ទាស់ទែងគ្នា ក្រុមគ្រួសារនោះក៏ពុំអាចនៅស្ថិត
ស្ថេរគង់វង្សបានដែរ។ ២៦ដូច្នេះប្រសិនបើមារសាតាំង
ក្រោកឡើងប្រឆាំងនឹងខ្លួនឯង បែកបាក់ទាស់ទែង
នឹងខ្លួនឯង វាមិនអាចនៅស្ថិតស្ថេរគង់វង្សបានឡើយ
គឺវាមុខជាត្រូវវិនាសមិនខាន។ ២៧គ្មាននរណាអាច
ចូលទៅក្នុងផ្ទះមនុស្សខ្លាំងពូកែ ហើយប្លន់យកទ្រព្យ
សម្បត្តិរបស់គាត់បានឡើយ គឺត្រូវតែចងមនុស្សខ្លាំង
ពូកែនោះជាមុនសិន ទើបអាចប្លន់យកទ្រព្យសម្បត្តិ
ក្នុងផ្ទះគាត់បាន។ ២៨ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថាបើមនុស្សលោកធ្វើអំពើបាប និងពោល
ពាក្យប្រមាថព្រះជាម្ចាស់ ព្រះអង្គនឹងលើកលែង
ទោសទាំងអស់។ ២៩រីឯអ្នកដែលពោលពាក្យប្រមាថ
ព្រះវិញ្ញាណដ៏វិសុទ្ធវិញ ព្រះអង្គមិនលើកលែងទោស
សោះឡើយ ដ្បិតអ្នកនោះមានទោសអស់កល្បជា
និច្ច»។

៣០ព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ ព្រោះគេ
និយាយថា ព្រះអង្គមានខ្មោចនៅក្នុងខ្លួន។

## ព្រះញាតិវង្សដ៏ពិតប្រាកដរបស់ព្រះយេស៊ូ

(ម៉ាថាយ ១២, ៤៦-៥០ លូកា ៨, ១៩-២១)

៣១ពេលនោះ មាតានិងបងប្អូនរបស់ព្រះយេស៊ូ
មកដល់ ឈរនៅខាងក្រៅផ្ទះ ហើយចាត់គេឲ្យចូល
មកហៅព្រះអង្គ។ ៣២បណ្តាជនដែលអង្គុយនៅជុំវិញ
ព្រះយេស៊ូទូលព្រះអង្គថា៖ «លោកគ្រូ ម្តាយនិងបង
ប្អូនលោកមករកលោក នៅខាងក្រៅ!»។៣៣ព្រះ
យេស៊ូមានព្រះបន្ទូលតបថា៖ «តើនរណាជាម្តាយ
ខ្ញុំ? នរណាជាបងប្អូនខ្ញុំ?»។ ៣៤ព្រះអង្គទតមើលទៅ
មនុស្សដែលនៅជុំវិញព្រះអង្គ រួចមានព្រះបន្ទូលថា៖
«អ្នកទាំងនេះហើយជាមាតានិងជាបងប្អូនរបស់ខ្ញុំ ៣៥
ដ្បិតអ្នកណាប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់
អ្នកនោះជាបងប្អូនប្រុសស្រី និង ជាម្តាយរបស់ខ្ញុំ»។

## ប្រស្នាអំពីពូជស្រូវ

(ម៉ាថាយ ១៣, ១-៩ លូកា ៨, ៤-៨)

៤ ១ព្រះយេស៊ូចាប់ផ្តើមបង្រៀនបណ្តាជននៅតាមឆ្នេរ
សមុទ្រម្តងទៀត។ មានបណ្តាជនច្រើនកុះករនាំគ្នា
មករកព្រះអង្គ ព្រះអង្គក៏យាងចុះទៅគង់ក្នុងទូកមួយ
នៅក្បែរមាត់ច្រាំង រីឯបណ្តាជនអង្គុយនៅលើគោក
តាមឆ្នេរសមុទ្រ។ ២ព្រះអង្គប្រើពាក្យប្រស្នាបង្រៀន
គេ អំពីសេចក្តីជាច្រើន។ ព្រះអង្គបង្រៀនគេថា៖ ៣«
ចូរស្តាប់មានបុរសម្នាក់ចេញទៅព្រោះស្រូវ។ ៤ពេល

គាត់ព្រោះមានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ ហើយ
សត្វមកចឹកស៊ីអស់ទៅ។ ៥មានគ្រាប់ពូជខ្លះទៀត
ធ្លាក់ទៅលើកន្លែងមានថ្មពុំសូវមានដី គ្រាប់ពូជក៏ដុះ
ឡើងភ្លាមព្រោះដីមិនជ្រៅ។ ៦លុះដល់ថ្ងៃក្ដៅពន្លក
ដែលដុះឡើងនោះក៏ក្រៀមស្វិតអស់ទៅ ព្រោះឫស
ចាក់មិនបានជ្រៅ។ ៧មានគ្រាប់ពូជខ្លះទៀត ធ្លាក់ទៅ
លើដីដែលមានបន្លា។ បន្លាក៏ដុះឡើងរួបរឹតស្រូវមិន
ឲ្យបង្កើតផលបានឡើយ។ ៨គ្រាប់ពូជឯទៀតៗធ្លាក់
ទៅលើដីមានជីជាតិល្អ គ្រាប់ពូជក៏ដុះឡើង ហើយ
លូតលាស់បង្កើតផល ខ្លះឲ្យផលមួយជាសាមសិប
ខ្លះទៀតឲ្យមួយជាហុកសិប និងខ្លះទៀតមួយជាមួយ
រយ»។ ៩បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលថា៖ «
អស់អ្នកដែលឮពាក្យនេះ សូមយកទៅពិចារណា
ចុះ!»។

១០កាលព្រះយេស៊ូគង់នៅដាច់ឡែកពីបណ្ដា
ជន អស់អ្នកដែលនៅជាមួយព្រះអង្គ និងសាវ័កទាំង
ដប់ពីររូបទូលសួរព្រះអង្គអំពីពាក្យប្រស្នាទាំងនោះ។
១១ព្រះអង្គមានព្រះបន្ទូលតបថា៖ «ព្រះជាម្ចាស់បាន
ប្រោសប្រទានឲ្យអ្នករាល់គ្នា យល់គំរោងការដ៏លាក់
កំបាំងនៃព្រះរាជ្យ*របស់ព្រះអង្គ។ រីឯអ្នកដទៃ គេឮ
សេចក្ដីទាំងអស់ជាពាក្យប្រស្នាវិញ។ ១២ដូច្នេះ ទោះ
បីគេខំប្រឹងមើល ក៏ពុំឃើញ គេខំប្រឹងស្ដាប់ក៏ពុំយល់
ដែរ ក្រែងលោគេប្រែចិត្តគំនិត ហើយព្រះជាម្ចាស់នឹង
អត់ទោសឲ្យគេ»។

១៣ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «បើអ្នក
រាល់គ្នាមិនយល់ប្រស្នានេះផង ធ្វើម្ដេចឲ្យអ្នករាល់គ្នា
យល់ប្រស្នាឯទៀតៗបាន! ១៤អ្នកព្រោះស្រូវសាប
ព្រោះព្រះបន្ទូល ១៥មនុស្សខ្លះប្រៀបបីដូចជាផ្លូវដែល
ព្រះបន្ទូលបានធ្លាក់ទៅលើ កាលបានស្ដាប់ព្រះ
បន្ទូល ហើយមារសាតាំង*ក៏មកឆក់យកព្រះបន្ទូល
ដែលបានព្រោះក្នុងចិត្តគេ ទៅភ្លាម។ ១៦មនុស្សដែល
បានទទួលគ្រាប់ពូជ នៅលើដីមានថ្ម ក៏ដូច្នោះដែរ
កាលបានស្ដាប់ព្រះបន្ទូលហើយ គេទទួលយកភ្លាម
ដោយអំណរ ១៧ប៉ុន្តែគេពុំទុកឲ្យព្រះបន្ទូលចាក់ឫស
នៅក្នុងខ្លួនគេឡើយ គឺគេជាប់ចិត្តតែមួយភ្លែត។ លុះ
ដល់មានទុក្ខវេទនាឬត្រូវគេបៀតបៀនព្រោះតែព្រះ
បន្ទូល គេក៏បោះបង់ចោលជំនឿភ្លាម។ ១៨មនុស្សខ្លះ
ទទួលគ្រាប់ពូជនៅលើដីដែលមានបន្លា គេបានស្ដាប់
ព្រះបន្ទូលដែរ ១៩ប៉ុន្តែការខ្វល់ខ្វាយអំពីជីវិតរស់នៅ
ក្នុងលោកីយ៍ ចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ
និងចិត្តប៉ងប្រាថ្នាផ្សេងៗ រឹបរួតព្រះបន្ទូលមិនឲ្យ
បង្កើតផលបានឡើយ។ ២០រីឯអ្នកដែលបានទទួល
គ្រាប់ពូជនៅលើដីមានជីជាតិល្អ កាលបានស្ដាប់ព្រះ
បន្ទូលហើយ ក៏ទទួលយកបង្កបង្កើតផល អ្នកខ្លះបាន
មួយជាសាមសិបអ្នកខ្លះបានមួយជាហុកសិប អ្នកខ្លះ
ទៀតបានមួយជាមួយរយ»។

## ប្រស្នាអំពីចង្កៀង

(ម៉ាថាយ ៥,១៥លូកា ៨, ១៦-១៨)

២១បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅគេថា៖
«គេមិនដែលអុជចង្កៀង ហើយយកធុងគ្របពីលើ ឬ
យកទៅដាក់ក្រោមគ្រែឡើយ។ គេតែងយកចង្កៀង
ទៅដាក់លើជើងចង្កៀងវិញ។ ២២គ្រប់ការលាក់កំបាំង
នឹងត្រូវបើកឲ្យគេដឹង ហើយគ្រប់អាថ៌កំបាំងក៏នឹងត្រូវ
លេចមក ឲ្យមនុស្សគ្រប់គ្នាឃើញច្បាស់ដែរ។ ២៣អ្នក
ណាឮពាក្យនេះ សូមយកទៅពិចារណាចុះ!»។ ២៤
ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ចូរអ្នករាល់គ្នា
ប្រុងប្រយ័ត្ននឹងសេចក្ដី ដែលអ្នករាល់គ្នាស្ដាប់នេះឲ្យ
មែនទែន។ ព្រះជាម្ចាស់នឹងវាល់ឲ្យអ្នករាល់គ្នា តាមរ
ង្វាល់ដែលអ្នករាល់គ្នាវាល់ឲ្យអ្នកដទៃ ហើយព្រះអង្គ
នឹងបន្ថែមឲ្យអ្នករាល់គ្នា ២៥ព្រោះអ្នកណាមានហើយ
ព្រះជាម្ចាស់នឹងប្រទានឲ្យថែមទៀត តែអ្នកណាដែល
គ្មាន ព្រះអង្គនឹងហូតយកអ្វីៗ ដែលអ្នកនោះមាន
ផង»។

## ប្រស្នាអំពីគ្រាប់ពូជដុះ

២៦ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះ
រាជ្យ*របស់ព្រះជាម្ចាស់ ប្រៀបបីដូចជាបុរសម្នាក់
ព្រោះស្រូវនៅក្នុងស្រែរបស់ខ្លួន។ ២៧ទោះបីគាត់ដេក
ក្ដី ក្រោកក្ដី យប់ក្ដី ថ្ងៃក្ដី គ្រាប់ពូជនៅតែមានពន្លកដុះ
ឡើងដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះ
របៀបណាឡើយ ២៨ដ្បិតដីធ្វើឲ្យពូជបង្កើតផល
ដោយខ្លួនឯង ដំបូងមានពន្លកលេចឡើងបន្ទាប់មក
ក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ។ ២៩លុះស្រូវទុំ
គេយកកណ្ដៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ»
។

## ប្រស្នាអំពីគ្រាប់ពូជល្អិត

(ម៉ាថាយ ១៣, ៣១-៣២, ៣៤ លូកា ១៣, ១៨-១៩)

៣០ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «តើយើង
ប្រដូចព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅនឹងអ្វី? តើយើង
យកប្រស្នាណាមកប្រដូចនឹងព្រះរាជ្យរបស់ព្រះអង្គ?
៣១ព្រះរាជ្យរបស់ព្រះជាម្ចាស់ ប្រៀបបីដូចជាគ្រាប់
ពូជម៉្យាង កាលគេព្រោះលើដីគ្រាប់ពូជនោះល្អិតជាង
គេទាំងអស់ក្នុងលោក។ ៣២លុះព្រោះរួចហើយគ្រាប់
ពូជនោះក៏ដុះឡើងធំជាងដំណាំឯទៀតៗ ព្រមទាំង
បែកមែកសាខាមានម្លប់ ឲ្យបក្សាបក្សីមកធ្វើសំបុក
ជ្រកអាស្រ័យ»។

៣៣ព្រះយេស៊ូតែងប្រកាសព្រះបន្ទូល ដោយប្រើ
ជាពាក្យប្រស្នារបៀបនេះ តាមតែគេអាចយល់បាន។
៣៤ព្រះអង្គតែងមានព្រះបន្ទូលទៅគេ សុទ្ធតែជាពាក្យ
ប្រស្នា ប៉ុន្តែពេលនៅដាច់ឡែកពីបណ្ដាជន ព្រះអង្គ
បកស្រាយទាំងអស់ ប្រាប់ពួកសាវ័ក*។

## ព្រះយេស៊ូធ្វើឲ្យរលកស្ងប់

(ម៉ាថាយ ៨, ២៣-២៧ លូកា ៨, ២២-២៥)

៣៥នៅល្ងាចថ្ងៃដដែលនោះ ព្រះយេស៊ូមានព្រះ
បន្ទូលទៅពួកសាវ័ក*ថា៖ «យើងនាំគ្នាឆ្លងទៅត្រើយ
ម្ខាង»។ ៣៦ពួកសាវ័កក៏ចេញពីបណ្ដាជន ហើយ
អុំទូកដែលមានព្រះយេស៊ូ គង់នៅក្នុងនោះ ដោយ
មានទូកឯទៀតៗទៅជាមួយដែរ។ ៣៧ស្រាប់តែមាន
ខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង ហើយរលកក៏បោក
ប៉ះនឹងទូក បណ្ដាលឲ្យទឹកចូលស្ទើរពេញ។ ៣៨រីឯ
ព្រះយេស៊ូវិញ ព្រះអង្គផ្ទំលក់លើខ្នើយ នៅកន្សៃទូ
ក។ ពួកសាវ័កដាស់ព្រះអង្គថា៖ «លោកគ្រូ យើង
ស្លាប់ឥឡូវហើយ! លោកមិនអើពើទេឬ?»។ ៣៩ព្រះ
យេស៊ូតើនឡើង មានព្រះបន្ទូលគំរាមខ្យល់ព្យុះ និង
បញ្ជាសមុទ្រថា៖ «ស្ងប់ស្ងៀមទៅ!»។ ពេលនោះ
ខ្យល់ព្យុះក៏ស្ងប់ហើយផ្ទៃទឹកក៏រាបស្មើដែរ។

៤០បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅពួក
សាវ័កថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យ
ដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?»។ ៤១
ពួកគេកោតស្ញប់ស្ញែងជាខ្លាំង ហើយនិយាយគ្នាទៅ
វិញទៅមកថា៖ «តើលោកនេះជានរណាបានជា
ខ្យល់ព្យុះ និងសមុទ្រស្ដាប់បង្គាប់លោកដូច្នេះ?»។

## ព្រះយេស៊ូប្រោសមនុស្សខ្មោចចូលម្នាក់

(ម៉ាថាយ ៨, ២៨-៣៤ លូកា ៨, ២៦-៣៩)

៥ ១ព្រះយេស៊ូ និងពួកសាវ័ក* បានទៅដល់ត្រើយ
ម្ខាង ក្នុងតំបន់កេរ៉ាសា។ ២កាល ព្រះអង្គយាងឡើង
ពីទូកភ្លាម មានបុរសម្នាក់ខ្មោចចូល ចេញពីទីបញ្ចុះ
សព ដើរតម្រង់មករកព្រះអង្គ។ ៣បុរសនេះស្នាក់នៅ
តែតាមទីបញ្ចុះសព គ្មាននរណាអាចចងគាត់បាន
ឡើយ សូម្បីតែយកច្រវាក់មកចង ក៏មិនជាប់ដែរ។ ៤
គេដាក់ខ្នោះជើងនិង យកច្រវាក់ចងគាត់ច្រើនដង
ប៉ុន្តែគាត់នៅតែកាច់បំបាក់ច្រវាក់ និងខ្នោះទាំងនោះ
ជានិច្ច គ្មាននរណាអាចបង្ក្រាបគាត់បានឡើយ។ ៥
គាត់រស់នៅតាមទីបញ្ចុះសព និងតាមភ្នំទាំងយប់ទាំង
ថ្ងៃ ហើយចេះតែស្រែកព្រមទាំងយកថ្ម មកអាររសាច់
ខ្លួនឯងថែមទៀតផង។ ៦កាលគាត់ឃើញព្រះយេស៊ូ

ពីចម្ងាយ ក៏រត់មកក្រាបថ្វាយបង្គំព្រះអង្គ ៧ហើយស្រែកយ៉ាងខ្លាំងថា៖ «ឱព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ? ទូលបង្គំអង្វរព្រះអង្គក្នុងព្រះនាមព្រះជាម្ចាស់ សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំអី!»។ ៨ខ្មោចនិយាយដូច្នេះ ព្រោះព្រះយេស៊ូបានបញ្ជាវាថា៖ «នែ៎ខ្មោចបិសាច ចូរចេញពីអ្នកនេះទៅ!»។ ៩ព្រះយេស៊ូមានព្រះបន្ទូលសួរទៅខ្មោចថា៖ «ឯងឈ្មោះអី?» ខ្មោចទូលឆ្លើយថា៖ «ទូលបង្គំឈ្មោះកងទ័ព ដ្បិតយើងខ្ញុំមានគ្នាច្រើន»។ ១០វាទទូចអង្វរ សូមកុំឲ្យព្រះអង្គបណ្ដេញពួកវាចេញពីស្រុកនោះ។ ១១នៅក្បែរនោះមានជ្រូកមួយហ្វូងធំ កំពុងរកស៊ីនៅតាមចង្កេះភ្នំ។

១២ពួកខ្មោចអង្វរព្រះយេស៊ូថា៖ «សូមបញ្ជូនយើងខ្ញុំឲ្យទៅចូលក្នុងជ្រូកទាំងនោះទៅ!»។ ១៣ព្រះយេស៊ូក៏យល់ព្រម។ ខ្មោចចេញពីបុរសនោះទៅចូលក្នុងជ្រូក ហ្វូងជ្រូកដែលមានចំនួនប្រមាណជាពីរពាន់ក្បាលក៏បោលចុះតាមជំរាលភ្នំ តម្រង់ទៅសមុទ្រលង់ទឹកងាប់អស់។ ១៤ពួកអ្នកថែរក្សាហ្វូង ជ្រូកយករឿងនេះរត់ទៅប្រាប់អ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ មនុស្សម្នាក៏នាំគ្នាមកមើលហេតុការណ៍នោះ។ ១៥គេចូលមករកព្រះយេស៊ូ ឃើញបុរសដែលមានខ្មោចកងទ័ពចូលកាលពីមុន អង្គុយមានសម្លៀកបំពាក់ ហើយដឹងស្មារតី នោះគេក៏នាំគ្នាកោតស្ញប់ស្ញែង។ ១៦អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែករៀបរាប់ប្រាប់គេ អំពីហេតុការណ៍ដែលកើតមានដល់បុរសនោះ និងអំពីហ្វូងជ្រូក។ ១៧គេទូលអង្វរព្រះយេស៊ូ ឲ្យចាកចេញពីស្រុកភូមិរបស់គេ។១៨ពេលព្រះអង្គកំពុងយាងចុះទូក បុរសដែលខ្មោចចូលពីមុន បានអង្វរសុំទៅជាមួយព្រះអង្គ។ ១៩ព្រះយេស៊ូមិនយល់ព្រមទេ ផ្ទុយទៅវិញ ទ្រង់មានព្រះបន្ទូលថា៖ «ចូរអ្នកត្រឡប់ទៅផ្ទះ ទៅនៅជាមួយក្រុមគ្រួសារវិញចុះ ហើយរៀបរាប់ហេតុការណ៍ទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានប្រោសដល់អ្នកដោយព្រះហឫទ័យអាណិតអាសូរ»។

២០បុរសនោះក៏ចេញទៅ ហើយចាប់ផ្ដើមប្រកាសប្រាប់ឲ្យប្រជាជន ក្នុងស្រុកដេកាប៉ូលដឹងអំពីការទាំងអស់ ដែលព្រះយេស៊ូបានប្រោសដល់គាត់។ អស់អ្នកដែលបានឮពាក្យគាត់កោតស្ញប់ស្ញែងក្រៃលែង។

## ព្រះយេស៊ូប្រោសស្ត្រីមានជំងឺធ្លាក់ឈាមឲ្យបានជា និងប្រោសកូនស្រីលោកយ៉ៃរ៉ូសឲ្យរស់ឡើងវិញ

(ម៉ាថាយ ៩, ១៨-២៦ លូកា ៨, ៤០-៥៦)

២១ព្រះយេស៊ូឆ្លងទូកពីត្រើយម្ខាងមកវិញ ព្រះអង្គគង់នៅឆ្នេរសមុទ្រ។ មានបណ្ដាជនច្រើនកុះករមកចោមរោមព្រះអង្គម្ដងទៀត។ ២២ពេលនោះមានអ្នកទទួលខុសត្រូវលើធម្មសាលា*ម្នាក់ ឈ្មោះយ៉ៃរ៉ូសមកដល់។ កាលគាត់ឃើញព្រះយេស៊ូ គាត់ក្រាបទៀបព្រះបាទាព្រះអង្គ ២៣ហើយទទូចអង្វរព្រះអង្គថា៖ «កូនស្រីរបស់ខ្ញុំប្រូបាទឈឺធ្ងន់ ជិតស្លាប់ សូមលោកអាណិតមេត្តាអញ្ជើញទៅដាក់ដៃ*លើនាង ដើម្បីសង្គ្រោះនាងឲ្យមានជីវិត»។ ២៤ព្រះយេស៊ូយាងទៅជាមួយគាត់។ មានបណ្ដាជនជាច្រើនកុះករតាមព្រះអង្គទៅ ទាំងប្រជ្រៀតគ្នាជុំវិញព្រះអង្គ។

២៥នៅពេលនោះ មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ។ ២៦គ្រូពេទ្យជាច្រើនបានព្យាបាលនាង តែនាងឈឺចុកចាប់រឹតតែខ្លាំង។ នាងបានចំណាយទ្រព្យសម្បត្តិទាំងប៉ុន្មាន ដែលនាងមាន តែជំងឺរបស់នាងនៅតែមិនបានធូរស្រាលទេ ផ្ទុយទៅវិញ នាងកាន់តែឈឺខ្លាំងឡើងៗ។ ២៧នាងបានឮគេនិយាយអំពីព្រះយេស៊ូ ក៏ចូលក្នុងចំណោមបណ្ដាជន ពាល់ព្រះពស្ត្ររបស់ព្រះអង្គពីខាងក្រោយ ២៨ដ្បិតនាងនឹកក្នុងចិត្តថា៖ «បើខ្ញុំបានពាល់អាវរបស់

លោក ខ្ញុំមុខជាទទួលការសង្គ្រោះមិនខាន»។ ២៩
រំពេចនោះ ឈាមឈប់ធ្លាក់ភ្លាម ហើយនាងដឹងថា
ខ្លួននាងបានជាសះស្បើយពីរោគា។៣០នៅពេលនោះ
ព្រះយេស៊ូជ្រាបភ្លាមថា មានឫទ្ធានុភាពមួយចេញពី
ព្រះអង្គ ព្រះអង្គបែរទៅរកបណ្ដាជន មានព្រះបន្ទូល
ថា៖ «អ្នកណាពាល់អាវខ្ញុំ?»។ ៣១ពួកសាវ័ក*ទូល
ព្រះអង្គថា៖ «ព្រះគ្រូឃើញស្រាប់ហើយ បណ្ដាជន
ប្រជ្រៀតប៉ះនឹងព្រះគ្រូគ្រប់គ្នា ចុះហេតុដូចម្ដេចបាន
ជាព្រះគ្រូសួរថា អ្នកណាពាល់ព្រះគ្រូដូច្នេះ?»។ ៣២
ព្រះយេស៊ូទតមើលជុំវិញ ដើម្បីឲ្យដឹងថាអ្នកណាបាន
ពាល់ព្រះអង្គ។ ៣៣ស្ត្រីនោះភ័យញ័ររន្ធត់ ព្រោះនាង
ដឹងអំពីហេតុដែលកើតដល់ខ្លួននាង។ នាងមកក្រាប
ទៀបព្រះបាទាព្រះយេស៊ូ ហើយទូលការពិតទាំង
អស់ថ្វាយព្រះអង្គ។ ៣៤ព្រះយេស៊ូមានព្រះបន្ទូល ទៅ
នាងថា៖ «កូនស្រីអើយ! ជំនឿរបស់នាងបានស
ង្គ្រោះនាងហើយ សូមអញ្ជើញទៅឲ្យបានសុខសាន្ត
ហើយសូមឲ្យនាងជាសះស្បើយពីជំងឺចុះ!»។
៣៥កាលព្រះយេស៊ូកំពុងតែ មានព្រះបន្ទូលនៅ
ឡើយ មានគេមកពីផ្ទះលោកយ៉ៃរ៉ូស ជំរាបគាត់ថា៖
«កូនស្រីលោកផុតដង្ហើមទៅហើយ ម្ដេចក៏នៅរំខាន
លោកគ្រូធ្វើអ្វី?»។ ៣៦ព្រះយេស៊ូមិនយកព្រះហឫទ័
យទុកដាក់ នឹងពាក្យរបស់អ្នកទាំងនោះឡើយ តែព្រះ
អង្គមានព្រះបន្ទូលទៅលោកយ៉ៃរ៉ូសថា៖ «កុំខ្លាចអី
គ្រាន់តែជឿប៉ុណ្ណោះបានហើយ»។ ៣៧ព្រះអង្គមិន
អនុញ្ញាត ឲ្យអ្នកណាទៅតាមព្រះអង្គឡើយលើក
លែងតែលោកសិលា លោកយ៉ាកុប និងលោកយ៉ូ
ហាន ជាប្អូនរបស់គាត់។ ៣៨កាលទៅដល់ផ្ទះ លោក
យ៉ៃរ៉ូស ជាអ្នកទទួលខុសត្រូវលើធម្មសាលាព្រះ
យេស៊ូទតឃើញមនុស្សម្នាជ្រួលច្របល់ ព្រមទាំងទ្រ
ហោយំជាខ្លាំងផង។ ៣៩ព្រះអង្គយាងចូលទៅក្នុងផ្ទះ
មានព្រះបន្ទូលទៅគេថា៖ «ហេតុដូចម្ដេចបានជាអ្នក
រាល់គ្នាជ្រួលច្របល់ ហើយទ្រហោយំដូច្នេះ? ក្មេង
នេះមិនស្លាប់ទេ នាងគ្រាន់តែដេកលក់ទេតើ!»។ ៤០
គេនាំគ្នាចំអកដាក់ព្រះអង្គ ព្រះអង្គក៏ដេញគេឲ្យចេញ
ទៅក្រៅទាំងអស់គ្នា រួចទ្រង់នាំតែឪពុកម្ដាយក្មេងនិង
សាវ័កទាំងបីរូប ចូលទៅក្នុងបន្ទប់ដែលក្មេងស្រីនោះ
ដេក។ ៤១ព្រះអង្គចាប់ដៃក្មេងស្រីនោះ ទាំងមានព្រះ
បន្ទូលថា៖ «តាលីថាគូម!» (ប្រែថា "នាងតូចអើយ
ខ្ញុំប្រាប់នាងថាចូរក្រោកឡើង!")។ ៤២ក្មេងស្រីក៏
ក្រោកឡើង ដើរមួយរំពេច ដ្បិតនាងមានអាយុដប់ពីរ
ឆ្នាំហើយ។ គេងឿងឆ្ងល់ពន់ប្រមាណ ៤៣ប៉ុន្តែព្រះ
យេស៊ូហាមប្រាមគេ មិនឲ្យប្រាប់នរណាដឹងរឿងនេះ
ឡើយ។ បន្ទាប់មកព្រះអង្គប្រាប់គេឲ្យយកចំណី
អាហារមកឲ្យក្មេងស្រីនោះបរិភោគ។

## អ្នកភូមិណាសារ៉ែតបដិសេធមិនព្រម ទទួលព្រះយេស៊ូ

(លូកា៤, ១៦-៣០)

៦ ១ព្រះយេស៊ូយាងចេញពីទីនោះ ត្រឡប់ទៅ
ភូមិស្រុករបស់ព្រះអង្គវិញ ពួកសាវ័ក*ក៏ទៅតាមព្រះ
អង្គដែរ។ ២លុះដល់ថ្ងៃសប្ប័ទ* ព្រះអង្គបង្រៀនអ្នក
ស្រុកនៅក្នុងធម្មសាលា*។ មនុស្សជាច្រើនដែលបាន
ស្ដាប់ព្រះអង្គ ងឿងឆ្ងល់ក្រៃលែង។ គេនិយាយគ្នាថា
៖ «តើគាត់ដឹងសេចក្ដីទាំងនេះមកពីណា? ប្រាជ្ញា
ដែលគាត់បានទទួលនេះជាប្រាជ្ញាអ្វីទៅ? ការអស្ចារ្យ
ដែលគាត់បានធ្វើនេះកើតឡើងដោយវិធីណា? ៣តើ
អ្នកនេះមិនមែនជាជាងឈើជាកូននាងម៉ារី ជាបងប្អូន
របស់យ៉ាកុប យ៉ូសេ យូដា និង ស៊ីម៉ូនទេឬអី? ប្អូន
ស្រីរបស់គាត់ទាំងប៉ុន្មាន ក៏រស់នៅក្នុងភូមិនេះជាមួយ
យើងដែរ!»។ ហេតុនេះហើយបានជាគេមិនអាចជឿ
ព្រះអង្គបានឡើយ។ ៤ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ធម្មតាគេមើលងាយព្យាការី*តែក្នុងស្រុក
កំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោក
ប៉ុណ្ណោះ»។ ៥នៅទីនោះ ព្រះអង្គពុំអាចធ្វើការអស្ចារ្យ

អ្វីបានឡើយបានត្រឹមតែដាក់ព្រះហស្ដលើអ្នកជំងឺខ្លះ
ដើម្បីប្រោសគេឲ្យបានជាប៉ុណ្ណោះ។ ៦ព្រះអង្គនឹក
ឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។

## ព្រះយេស៊ូចាត់សាវ័កទាំងដប់ពីររូបឲ្យទៅប្រកាសដំណឹងល្អ

(ម៉ាថាយ ១០, ៥-១៥ លូកា ៩, ១-៦)

ព្រះយេស៊ូយាងទៅភូមិនានា ដែលនៅជុំវិញ
ហើយទ្រង់បង្រៀនអ្នកស្រុក។ ៧ពេលនោះ ព្រះអង្គ
ត្រាស់ហៅសាវ័ក*ទាំងដប់ពីររូបមក រួចទ្រង់ចាត់គេពី
រៗនាក់ឲ្យទៅទាំងប្រទាន ឲ្យគេមានអំណាចដេញ
ខ្មោចផង។ ៨ព្រះអង្គផ្ដែផ្ដាំគេមិនឲ្យយកអ្វីទៅជាមួយ
ក្នុងពេលធ្វើដំណើរឡើយ លើកលែងតែដំបង
ប៉ុណ្ណោះ៖ «កុំយកចំណីអាហារ ថង់យាម ឬយក
ប្រាក់កាសជាប់នឹងខ្លួន ៩ចូរពាក់ស្បែកជើងតែមិនត្រូវ
យកអាវពីរបន្លាស់ ទៅជាមួយឲ្យសោះ»។ ១០ព្រះ
អង្គមានព្រះបន្ទូលថា៖ «បើអ្នករាល់គ្នាចូលផ្ទះណា
ចូរស្នាក់នៅផ្ទះនោះរហូតដល់ពេលអ្នករាល់គ្នាចេញ
ពីស្រុកនោះទៅ។ ១១បើនៅកន្លែងណាគេមិនព្រម
ទទួល មិនព្រមស្ដាប់អ្នករាល់គ្នា ចូរចេញពីកន្លែង
នោះទៅ ហើយរលាស់ធូលីដីចេញពីជើងអ្នករាល់គ្នា
ផង ទុកជាសញ្ញាព្រមានគេ»។

១២ពួកសាវ័កក៏ចេញ ទៅប្រកាសឲ្យមនុស្សម្នា
ប្រែចិត្តគំនិត។ ១៣គេបានដេញអារក្សជាច្រើន ចេញ
ពីមនុស្ស ព្រមទាំងចាក់ប្រេងលើអ្នកជំងឺច្រើននាក់
ដើម្បីប្រោសឲ្យគេបានជាសះស្បើយ។

## ស្ដេចហេរ៉ូដសម្លាប់លោកយ៉ូហានបាទីស្ដ

(ម៉ាថាយ ១៤, ១-១២ លូកា ៩, ៧-៩)

១៤ព្រះបាទហេរ៉ូដបានជ្រាប អំពីហេតុការណ៍
ទាំងអស់នោះ ដ្បិតព្រះកិត្តិនាមរបស់ព្រះយេស៊ូបាន
ល្បីឮខ្ចរខ្ចាយ។ មានគេនិយាយថា៖ «លោកយ៉ូ
ហានបាទីស្ដបានរស់ឡើងវិញ។ ហេតុនេះហើយបាន
ជាលោកមានអំណាចនឹងធ្វើការអស្ចារ្យ យ៉ាងនេះ»។
១៥អ្នកខ្លះថា៖ «លោកជាព្យាការីអេលី» ហើយខ្លះ
ទៀតថា៖ «លោកជាព្យាការី*ម្នាក់ដូចព្យាការីឯទៀ
តៗពីជំនាន់ដើមដែរ»។ ១៦រីឯព្រះបាទហេរ៉ូដវិញ
កាលបានជ្រាបដំណឹងនេះ ទ្រង់មានរាជឱង្ការថា៖ «
អ្នកនេះពិតជាលោកយ៉ូហាន ដែលយើងបានឲ្យគេ
កាត់កមែន ឥឡូវនេះគាត់រស់ឡើងវិញ»។

១៧ព្រះបាទហេរ៉ូដបានបញ្ជា ឲ្យគេចាប់លោក
យ៉ូហានដាក់ច្រវាក់យកទៅឃុំឃាំង ដោយទ្រង់ជឿ
តាមព្រះនាងហេរ៉ូឌីយ៉ាដា ដែលត្រូវជាមហេសីរបស់
ស្ដេចភីលីព ជាអនុជ ហើយព្រះអង្គយកមកធ្វើជាម
ហេសី។ ១៨លោកយ៉ូហានបានបន្ទោសស្ដេចហេរ៉ូដ
ថា៖ «ព្រះករុណាគ្មានសិទ្ធិនឹងយកមហេសីរបស់
អនុជមកធ្វើជាមហេសីទេ»។ ១៩ព្រះនាងហេរ៉ូឌី
យ៉ាដាចងគំនុំ ប៉ងសម្លាប់លោកយ៉ូហាន តែរក
សម្លាប់ពុំកើត ២០ដ្បិតព្រះបាទហេរ៉ូដខ្លាចលោកយ៉ូ
ហាន ព្រោះទ្រង់ជ្រាបថា លោកជាមនុស្សសុចរិត*
និងជាអ្នកដ៏វិសុទ្ធ*។ ដូច្នេះទ្រង់ការពារលោក។
កាលទ្រង់ព្រះសណ្ដាប់ពាក្យលោកយ៉ូហាន ទ្រង់សព្វ
ព្រះហឫទ័យជាខ្លាំង តែទ្រង់រារែកមិនដឹងជាត្រូវគិត
យ៉ាងណា។

២១មានថ្ងៃមួយ ក្នុងឱកាសបុណ្យចម្រើនព្រះ
ជន្មរបស់ព្រះបាទហេរ៉ូដ ព្រះអង្គបានរៀបចំពិធីជប់
លៀង ដោយអញ្ជើញអស់លោកមន្ត្រីមេទ័ព និង
នាម៉ឺនធំៗ ក្នុងស្រុកកាលីឡេមកចូលរួម។ ពេលនោះ
ជាឱកាសល្អ ដល់ព្រះនាងហេរ៉ូឌីយ៉ាដា។ ២២បុត្រី
របស់ព្រះនាងក៏ចូលមករាំ ធ្វើឲ្យស្ដេចហេរ៉ូដនិងភ្ញៀវ
ទាំងអស់ពេញចិត្តណាស់។ ស្ដេចក៏មានរាជឱង្ការទៅ
កាន់នាងថា៖ «បើនាងចង់បានអ្វី ចូរសុំពីយើងចុះ
យើងនឹងឲ្យនាង»។ ២៣រួចស្ដេចស្បថនឹងនាងថា៖ «
អ្វីៗដែលនាងសុំពីយើង យើងនឹងឲ្យនាងទោះបីនគរ
មួយចំហៀងក៏ដោយ»។ ២៤នាងក៏ចេញទៅសួរមាតា

ថា៖ «តើខ្ញុំម្ចាស់ត្រូវសុំអ្វី?»។ មាតាឆ្លើយថា៖ «ត្រូវសុំក្បាលរបស់យ៉ូហានបាទីស្ដ!»។ ២៥នាងក៏ប្រញាប់ត្រឡប់ទៅគាល់ស្ដេចវិញភ្លាម រួចទូលថា៖ «ខ្ញុំម្ចាស់ចង់បានក្បាលរបស់យ៉ូហានបាទីស្ដ ដាក់លើថាសឥឡូវនេះ!»។ ២៦ស្ដេចព្រួយព្រះហឫទ័យក្រៃលែង តែមិនហ៊ានបដិសេធឡើយ ព្រោះទ្រង់បានស្បថ នៅមុខភ្ញៀវទាំងអស់គ្នា។ ២៧ទ្រង់បញ្ជាទាហានម្នាក់ ឲ្យទៅយកក្បាលលោកយ៉ូហានមកភ្លាម។ ២៨ទាហានទៅគុក កាត់កលោកយ៉ូហាន យកក្បាលដាក់លើថាសមួយ មកប្រគល់ឲ្យនាង ហើយនាងយកទៅថ្វាយមាតា។ ២៩កាលពួកសិស្សរបស់លោកយ៉ូហានបានឮដំណឹងនេះ គេនាំគ្នាមកយកសពរបស់លោកទៅបញ្ចុះក្នុងផ្នូរ។

## ព្រះយេស៊ូប្រទាននំប៉័ងឲ្យមនុស្សប្រាំពាន់នាក់បរិភោគ

(ម៉ាថាយ ១៤,១៣-២១ លូកា ៩,១០-១៧ យ៉ូហាន ៦,១-៤)

៣០ពួកគ្រីស្ដទូត* វិលត្រឡប់មកគាល់ព្រះយេស៊ូវិញ រៀបរាប់ទូលព្រះអង្គអំពីកិច្ចការទាំងប៉ុន្មានដែលគេបានធ្វើ និងសេចក្ដីទាំងអស់ដែលគេបានបង្រៀន។

៣១មនុស្សជាច្រើនធ្វើដំណើរទៅមក ធ្វើឲ្យព្រះយេស៊ូនិងពួកសាវ័ក* រកពេលបរិភោគពុំបានសោះ។ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសាវ័កថា៖ «ចូរនាំគ្នាមករកកន្លែងស្ងាត់ដាច់ឡែកពីបណ្ដាជន សម្រាកបន្ដិចសិន»។ ៣២ព្រះយេស៊ូក៏យាងចុះទូកជាមួយពួកសាវ័ក ឆ្ពោះទៅកាន់កន្លែងមួយស្ងាត់ដាច់ឡែក។ ៣៣ប៉ុន្តែមានមនុស្សជាច្រើនបានឃើញព្រះយេស៊ូ និងពួកសាវ័កចេញដំណើរទៅគេក៏ស្គាល់ព្រះអង្គនិងសាវ័ក ហើយនាំគ្នារត់ចេញពីទីក្រុងនានាទៅមុន។

៣៤កាលព្រះយេស៊ូយាងឡើងពីទូកមក ទតឃើញមហាជនច្រើនយ៉ាងនេះ ទ្រង់មានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ព្រោះអ្នកទាំងនោះប្រៀបបីដូចជា ចៀមដែលគ្មានគង្វាលថែទាំ។ ព្រះអង្គក៏បង្រៀនគេ អំពីសេចក្ដីផ្សេងៗជាច្រើន។ ៣៥ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សាវ័កនាំគ្នាចូលមកគាល់ព្រះយេស៊ូ ទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ ថ្ងៃក៏ជិតលិចផង ៣៦សូមប្រាប់អ្នកទាំងនេះឲ្យត្រឡប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះតាមភូមិជិតៗនេះ»។ ៣៧ព្រះយេស៊ូមានព្រះបន្ទូល តបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារ ឲ្យគេបរិភោគទៅ!»។ គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីររយដួង* ទៅទិញម្ហូបអាហារឲ្យគេបរិភោគឬ?»។ ៣៨ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយគេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។ ៣៩ព្រះយេស៊ូបង្គាប់ពួកសាវ័កឲ្យប្រាប់បណ្ដាជនអង្គុយជាក្រុមៗ នៅលើស្មៅខៀវខ្ចី។ ៤០គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ៤១ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំនិងត្រីពីរកន្ទុយនោះ មកកាន់ទ្រង់ងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉័ងប្រទានឲ្យពួកសាវ័ក ដើម្បីឲ្យគេចែកបណ្ដាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឲ្យគេទាំងអស់គ្នាដែរ។ ៤២អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ៤៣ពួកសាវ័ក*ប្រមូលនំប៉័ងនិងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ៤៤ក្នុងចំណោមអ្នកដែលបរិភោគនំប៉័ង មានប្រុសៗចំនួនប្រាំពាន់នាក់។

## ព្រះយេស៊ូយាងលើទឹកសមុទ្រ

(ម៉ាថាយ ១៤, ២២-៣៣ យ៉ូហាន ៦, ១៥-២១)

៤៥រំពេចនោះ ព្រះយេស៊ូបញ្ជាពួកសាវ័ក* ឲ្យចុះទូកឆ្លងទៅត្រើយម្ខាង ឆ្ពោះទៅភូមិបេតសៃដាមុន

ព្រះអង្គ ហើយព្រះអង្គប្រាប់បណ្ដាជនឲ្យត្រឡប់ទៅវិ
ញ។ ៤៦កាលឲ្យបណ្ដាជន ចេញផុតអស់ហើយ ព្រះ
យេស៊ូយាងទៅអធិស្ឋាននៅលើភ្នំ។ ៤៧លុះដល់យប់
ទូកបានទៅដល់កណ្ដាលសមុទ្រ រីឯព្រះយេស៊ូវិញ
ទ្រង់គង់នៅលើគោកតែមួយព្រះអង្គឯង។ ៤៨ព្រះអង្គ
ទតឃើញសាវ័កកំពុងតែអុំទូក យ៉ាងលំបាក ដ្បិតប
ញ្ច្រាសខ្យល់។ ពេលជិតភ្លឺព្រះអង្គយាងលើទឹក ឆ្ពោះ
ទៅរកពួកគេ ហើយធ្វើដូចជាចង់យាងបង្ហួស។ ៤៩
កាលពួកសាវ័កឃើញព្រះអង្គយាងលើទឹកសមុទ្រ
ដូច្នេះ គេស្មានថាខ្មោចលងក៏នាំគ្នាស្រែក ៥០ដ្បិតគេ
បានឃើញព្រះអង្គគ្រប់ៗគ្នា ហើយភ័យរន្ធត់ជាខ្លាំ
ង។ ព្រះយេស៊ូក៏មានព្រះបន្ទូលទៅគេភ្លាមថា៖ «ចូរ
តាំងចិត្តក្លាហានឡើង ខ្ញុំទេតើ[ខ]កុំខ្លាចអី!»។ ៥១
បន្ទាប់មក ព្រះអង្គយាងចូលក្នុង ទូកជាមួយគេ
ហើយខ្យល់ក៏ស្ងប់។ ពួកសាវ័កងឿងឆ្ងល់ពន់ពេក
ណាស់ ៥២ដ្បិតគេពុំទាន់បានយល់អំពីរឿងនំប៉័ង មក
ពីគេមានចិត្តរឹងរូស។

## ព្រះយេស៊ូប្រោស អ្នកជំងឺនៅស្រុកកេនេសារ៉ែត

(ម៉ាថាយ ១៤, ៣៤-៣៦)

៥៣កាលព្រះយេស៊ូនិងពួកសាវ័ក* បានឆ្លងទៅ
ដល់ត្រើយម្ខាងក្នុងស្រុកកេនេសារ៉ែតហើយគេក៏នាំ
គ្នាចតទូក។ ៥៤ព្រះអង្គយាងឡើងលើគោកជាមួយ
សាវ័ក* ពេលនោះមនុស្សម្នាស្គាល់ព្រះអង្គភ្លាម។ ៥៥
គេរត់ទៅគ្រប់កន្លែងក្នុងតំបន់ ហើយនាំគ្នាសែងអ្នក
ជំងឺទៅកន្លែង ដែលគេឮថា ព្រះអង្គគង់នៅ។ ៥៦គ្រប់
កន្លែងដែលព្រះយេស៊ូយាងទៅ ទោះបីនៅក្នុងភូមិ
ក្នុងក្រុង ឬតាមស្រុកស្រែក្ដី គេយកអ្នកជំងឺមកដាក់
នៅតាមទីផ្សារ ទូលអង្វរសុំគ្រាន់តែពាល់ជាយព្រះព
ស្ត្រព្រះអង្គប៉ុណ្ណោះៗ អស់អ្នកដែលពាល់ព្រះអង្គ
បានជាសះស្បើយ[គ]គ្រប់ៗគ្នា។

## ពួកខាងគណៈផារីស៊ី និងទំនៀមទម្លាប់

(ម៉ាថាយ ១៥, ១-៩)

៧ ១មានពួកខាងគណៈផារីស៊ី*និង ធម្មាចារ្យ*ខ្លះនាំគ្នា
មកពីក្រុងយេរូសាឡឹម ទៅជួបព្រះយេស៊ូ។ ២គេ
ឃើញសាវ័ក*របស់ព្រះអង្គខ្លះ បរិភោគអាហារដោយ
ដៃមិនបរិសុទ្ធ* គឺគេពុំបានលាងដៃជាមុន។៣ធម្មតា
ពួកផារីស៊ីនិងជនជាតិយូដាទាំងអស់ តែងតែធ្វើពិធី
លាងដៃ យ៉ាងស្អាតហ្មត់ចត់មុននឹងបរិភោគ តាម
ទំនៀមទម្លាប់របស់ចាស់បុរាណ។ ៤នៅពេលត្រឡប់
មកពីផ្សារវិញ ដរាបណាគេមិនបានធ្វើពិធីលាង
សំអាតខ្លួនជាមុនទេ គេមិនបរិភោគឡើយ។ គេកាន់
ទំនៀមទម្លាប់ផ្សេងៗទៀតជាច្រើនដូចជាពិធីលាង
ពែង លាងថូទឹក លាងឆ្នាំង លាងតុជាដើម។ ៥ពួក
ខាងគណៈផារីស៊ីនិងពួកធម្មាចារ្យទូលសួរព្រះយេស៊ូ
ថា៖ «ហេតុអ្វីបានជាសិស្សរបស់លោកមិនកាន់ តាម
ទំនៀមទម្លាប់ចាស់បុរាណ គឺនាំគ្នាបរិភោគដោយដៃ
មិនបរិសុទ្ធដូច្នេះ?»។ ៦ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ព្យាការី*អេសាយបានថ្លែងទុកថា "អ្នករាល់
គ្នាជាមនុស្សមានពុត"ត្រូវណាស់ ដូចមានចែងថា៖

*ប្រជារាស្ត្រនេះគោរពយើងតែបបូរមាត់*
*ឯចិត្តគេនៅឆ្ងាយពីយើង។*
៧ *គេថ្វាយបង្គំយើង តែឥតបានការអ្វីសោះ*
*ព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្ស*
*ប៉ុណ្ណោះ។*

៨អ្នករាល់គ្នាបោះបង់ចោល វិន័យរបស់ព្រះជា
ម្ចាស់ បែរទៅកាន់តាមទំនៀមទម្លាប់របស់មនុស្ស
វិញ»។ ៩ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «អ្នករាល់
គ្នាប្រសប់បំបាត់វិន័យរបស់ព្រះជាម្ចាស់ចោល បែរ
ទៅកាន់តាមទំនៀមទម្លាប់ របស់អ្នករាល់គ្នាផ្ទាល់វិ
ញ។ ១០លោកម៉ូសេ*បានថ្លែងថា៖ "*ចូរគោរពមាតា
បិតារបស់អ្នក អ្នកណាជេរប្រទេចផ្ដាសាមាតារបស់
ខ្លួនត្រូវមានទោសដល់ជីវិត*[ឃ]" ១១រីឯអ្នករាល់គ្នាវិញ

អ្នករាល់គ្នាបែរជាពោលថា៖ "ប្រសិនបើមនុស្សម្នាក់
និយាយទៅឪពុកម្ដាយថាអ្វីៗ ដែលខ្ញុំត្រូវជូនលោក
ឪពុកអ្នកម្ដាយ បានរាប់ថាគ័របាន់ ស្រេចទៅហើយ"
(ពាក្យនេះប្រែថា ទុកជាតង្វាយថ្វាយព្រះជាម្ចាស់)។
១២អ្នករាល់គ្នាពុំទុកឲ្យ គាត់ជួយឪពុកម្ដាយឡើយ។
១៣អ្នករាល់គ្នាបានបំបាត់ តម្លៃព្រះបន្ទូលរបស់ព្រះជា
ម្ចាស់ ដោយសារទំនៀមទម្លាប់ដែលអ្នករាល់គ្នាបាន
បង្រៀនតៗគ្នា។ អ្នករាល់គ្នាបានេធ្វើការផ្សេងៗជា
ច្រើនស្រដៀងនឹងការទាំងនេះដែរ»។

## មូលហេតុដែលបណ្ដាលឲ្យមនុស្សមិនបរិសុទ្ធ

(ម៉ាថាយ ១៥, ១០-២០)

១៤បន្ទាប់មក ព្រះយេស៊ូត្រាស់ហៅបណ្ដាជន
មកម្ដងទៀត រួចមានព្រះបន្ទូលទៅគេថា៖ «ចូរស្ដាប់
ខ្ញុំទាំងអស់គ្នា ហើយយល់ឲ្យច្បាស់ថា ១៥អ្វីៗពីខាង
ក្រៅ ចូលទៅក្នុងមនុស្ស ពុំអាចធ្វើឲ្យមនុស្សក្លាយ
ទៅជាមិនបរិសុទ្ធ*បានឡើយ ផ្ទុយទៅវិញមានតែអ្វីៗ
ចេញពីមនុស្សប៉ុណ្ណោះ ដែលធ្វើឲ្យមិនបរិសុទ្ធ {១៦
អ្នកណាឮពាក្យនេះហើយ ចូរយកទៅពិចារណា
ចុះ}»។ ១៧កាលព្រះយេស៊ូយាងចេញពីបណ្ដាជន
ចូលទៅក្នុងផ្ទះ ពួកសាវ័ក*នាំគ្នាទូលសួរព្រះអង្គអំពី
ប្រស្នានេះ។ ១៨ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «
អ្នករាល់គ្នាក៏គ្មានប្រាជ្ញាដូចពួកគេដែរឬ? អ្នករាល់គ្នា
ត្រូវយល់ថាអ្វីៗពីខាងក្រៅចូលទៅក្នុងមនុស្ស ពុំអាច
ធ្វើឲ្យគេក្លាយទៅជាមិនបរិសុទ្ធបានឡើយ ១៩ដ្បិត
អ្វីៗទាំងនោះមិនចូលទៅក្នុងចិត្តទេ គឺចូលទៅក្នុង
ពោះ រួចចេញមកធ្លាក់ទៅទីបន្ទោរបង់»។ ព្រះអង្គ
បញ្ជាក់ថា គ្រប់អាហារសុទ្ធតែបរិសុទ្ធទាំងអស់។ ២០
ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «មានតែអ្វីៗចេញពី
មនុស្សប៉ុណ្ណោះដែលធ្វើឲ្យគេមិនបរិសុទ្ធ ២១ដ្បិត
គំនិតអាក្រក់ទាំងប៉ុន្មានសុទ្ធតែចេញមកពីខាងក្នុង
ចិត្តរបស់មនុស្ស គឺគំនិតដែលនាំឲ្យប្រព្រឹត្តកាមគុណ
ថោកទាប លួចប្លន់ កាប់សម្លាប់ ២២ផិតក្បត់លោភ
លន់ចង់បានទ្រព្យគេ កាចសាហាវ បោកប្រាស់គេ
ប្រព្រឹត្តអបាយមុខ ច្រណែនឈ្នានីស អំនួតនិងគំនិត
លេលា។ ២៣ការអាក្រក់ទាំងនេះហើយ ដែលចេញពី
ខាងក្នុងមនុស្សមក ធ្វើឲ្យគេក្លាយទៅជាមិន
បរិសុទ្ធ*»។

## ស្ត្រីសាសន៍ដទៃម្នាក់ជឿព្រះយេស៊ូ

២៤ព្រះយេស៊ូយាងចាកចេញពីទីនោះ ឆ្ពោះទៅ
កាន់តំបន់ជិតក្រុងទីរ៉ូស។ ព្រះអង្គយាងចូលក្នុងផ្ទះ
មួយ ទ្រង់ពុំចង់ឲ្យនរណាដឹងថាទ្រង់គង់នៅទីនោះ
ឡើយ តែលាក់មិនជិត។ ២៥ភ្លាមនោះស្ត្រីម្នាក់ដែល
កូនស្រីមានខ្មោចចូល បានឮគេនិយាយអំពីព្រះ
យេស៊ូ នាងមកក្រាបទៀបព្រះបាទារបស់ព្រះអង្គ។
២៦ស្ត្រីនោះជាសាសន៍ក្រិកមានកំណើត នៅភេនីស៊ី
ក្នុងស្រុកស៊ីរី។ នាងទូលសូមព្រះយេស៊ូដេញខ្មោច
ចេញពីកូននាង។ ២៧ព្រះយេស៊ូមានព្រះបន្ទូលទៅ
នាងថា៖ «ត្រូវទុកឲ្យកូនចៅបរិភោគឆ្អែតជាមុនសិន
មិនគួរយកអាហាររបស់កូនចៅបោះទៅឲ្យកូនឆ្កែស៊ី
ឡើយ»។ ២៨នាងទូលព្រះអង្គថា៖ «ពិតមែនហើយ
លោកម្ចាស់! ប៉ុន្តែ កូនឆ្កែនៅក្រោមតុវាស៊ីកំទេច
អាហារដែលកូនក្មេងធ្វើឲ្យជ្រុះនោះបាន»។ ២៩ពេល
នោះព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ដោយ
នាងនិយាយដូច្នេះ ចូរនាងវិលត្រឡប់ទៅវិញចុះ
ខ្មោចបានចេញពីកូននាងហើយ»។ ៣០ពេលស្ត្រី
នោះមកដល់ផ្ទះ នាងឃើញកូនស្រីដេកនៅលើគ្រែ
ដ្បិតខ្មោចបានចេញពីក្មេងនោះហើយ។

## ព្រះយេស៊ូប្រោសមនុស្សគថ្លង់ម្នាក់ឲ្យបានជា

៣១ព្រះយេស៊ូយាងចេញពីតំបន់ក្រុងទីរ៉ូស កាត់
តាមតំបន់ក្រុងស៊ីដូន និងតំបន់ស្រុកដេកាប៉ូលឆ្ពោះ

ទៅសមុទ្រកាលីឡេវិញ។ ៣២គេនាំបុរសថ្លង់ម្នាក់មក
គាល់ព្រះអង្គ។ ម៉្យាងទៀតបុរសនោះពុំអាចនិយាយ
បានស្រួលដូចធម្មតាផង។ គេទូលអង្វរសូមឲ្យព្រះ
អង្គដាក់ព្រះហស្ដលើគាត់។ ៣៣ព្រះអង្គនាំគាត់ចេញ
ទៅដោយឡែកដាច់ពីបណ្ដាជន ទ្រង់ដាក់ព្រះអង្គុលី
ក្នុងត្រចៀកគាត់ ហើយស្ដោះទឹកព្រះឱស្ឋយកទៅផ្ដិ
តលើអណ្ដាតគាត់ ៣៤រួចព្រះអង្គងើបព្រះភ័ក្ដ្រឡើង
ទតទៅលើមេឃ ដកដង្ហើមធំ ហើយមានព្រះបន្ទូល
ថា «អេផាថា» (ប្រែថា៖ ចូរបើកឡើង)។ ៣៥រំពេច
នោះ ស្រាប់តែត្រចៀករបស់បុរសនោះអាចស្ដាប់ឮ អ
ណ្ដាតរបស់គាត់ក៏គ្រលាស់បាន ហើយគាត់ក៏
និយាយស្ដីបានច្បាស់លាស់។ ៣៦ព្រះយេស៊ូបាន
ហាមប្រាមពួកគេ មិនឲ្យនិយាយហេតុការណ៍នេះ
ប្រាប់នរណាសោះឡើយ។ ប៉ុន្ដែទោះបីព្រះអង្គហាម
ប្រាមយ៉ាងណាក៏ដោយ គេរឹតតែប្រកាសខ្លាំងឡើ
ងៗ។ ៣៧មនុស្សម្នាងឿងឆ្ងល់ពន់ពេកណាស់ហើយ
ពោលថា៖ «គ្រប់កិច្ចការដែលលោកធ្វើសុទ្ធតែល្អ
ទាំងអស់ សូម្បីតែមនុស្សថ្លង់ក៏លោកធ្វើឲ្យឮបាន
មនុស្សគក៏លោកធ្វើឲ្យនិយាយបានដែរ»។

## ព្រះយេស៊ូប្រទាននំប៉័ងឲ្យមនុស្សបួនពាន់នាក់បរិភោគ

(ម៉ាថាយ ១៥, ៣២-៣៩)

៨ ១នៅពេលនោះ បណ្ដាជនយ៉ាងច្រើនកុះករមកប្រជុំ
គ្នាសាជាថ្មីម្ដងទៀត។ ដោយគេគ្មានអ្វីបរិភោគព្រះ
យេស៊ូត្រាស់ហៅពួកសាវ័ក* មកមានព្រះបន្ទូលថា៖
២«ខ្ញុំអាណិតអាសូរបណ្ដាជននេះពន់ពេកណាស់
ដ្បិតគេនៅជាមួយខ្ញុំអស់រយៈពេលបីថ្ងៃមកហើយ
ហើយគ្មានអ្វីបរិភោគសោះ។ ៣ប្រសិនបើខ្ញុំឲ្យគេត្រ
ឡប់ទៅផ្ទះវិញ ទាំងពោះទទេគេមុខជាអស់កម្លាំង
ដួលតាមផ្លូវមិនខាន ព្រោះអ្នកខ្លះបានធ្វើដំណើរមក
ពីស្រុកឆ្ងាយ»។ ៤ពួកសាវ័កទូលព្រះអង្គថា៖ «ទី
នេះស្ងាត់ណាស់ តើរកម្ហូបអាហារឯណាឲ្យគេ
បរិភោគឆ្អែត គ្រប់គ្នាបាន?»។ ៥ព្រះយេស៊ូមានព្រះ
បន្ទូលសួរថា៖ «តើអ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»
។ ពួកគេទូលថា៖ «មានប្រាំពីរដុំ»។ ៦ព្រះអង្គក៏
ប្រាប់បណ្ដាជនឲ្យអង្គុយផ្ទាល់នឹងដី ទ្រង់យកនំប៉័ង
ទាំងប្រាំពីរដុំមកកាន់ អរព្រះគុណព្រះជាម្ចាស់ ហើយ
កាច់ប្រទានឲ្យពួកសាវ័ក* ចែកបណ្ដាជន។ ៧គេមាន
ត្រីតូចៗខ្លះដែរ។ ព្រះយេស៊ូអរព្រះគុណព្រះជាម្ចាស់
រួចប្រាប់ពួកសាវ័កឲ្យចែកត្រីទាំងនោះដល់គេ។ ៨គេ
បានបរិភោគឆ្អែតទាំងអស់គ្នា ហើយប្រមូលនំប៉័ងនិង
ត្រីដែលនៅសល់បានប្រាំពីរជាល។៩នៅពេលនោះ
មានមនុស្សទាំងអស់ប្រមាណជាបួនពាន់នាក់។
បន្ទាប់មក ព្រះយេស៊ូប្រាប់គេឲ្យវិលត្រឡប់ទៅផ្ទះវិ
ញ។ ១០ភ្លាមនោះ ព្រះអង្គយាងចុះទូកជាមួយពួកសា
វ័ក ឆ្ពោះទៅតំបន់ដាល់ម៉ានូថាញ។

## ពួកខាងគណៈផារីស៊ីចង់ឃើញការ អស្ចារ្យ

(ម៉ាថាយ ១៦, ១-៤)

១១ពួកខាងគណៈផារីស៊ី*មកដល់ ហើយនាំគ្នា
ជជែកជាមួយព្រះយេស៊ូ ដើម្បីល្បងលមើលព្រះអង្គ
គេសូមឲ្យព្រះអង្គសម្ដែងទីសម្គាល់ដ៏អស្ចារ្យ អ្វីមួយ
បញ្ជាក់ថា ព្រះអង្គបានទទួលអំណាចពីព្រះជាម្ចា
ស់។ ១២ព្រះយេស៊ូដកដង្ហើមធំ រួចមានព្រះបន្ទូលថា៖
«ហេតុអ្វីបានជាមនុស្សជំនាន់នេះចង់ឃើញទី
សម្គាល់ ដូច្នេះ? ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ថា ព្រះជាម្ចាស់មិនឲ្យគេឃើញទីសម្គាល់ណា
ឡើយ»។ ១៣បន្ទាប់មកព្រះអង្គយាងចាកចេញពីគេ
ចុះទូកឆ្លងទៅត្រើយម្ខាងវិញ។

## ពុតត្បុតរបស់ពួកគណៈផារីស៊ីនិង ពុតត្បុតរបស់ស្ដេចហេរ៉ូដ

(ម៉ាថាយ ១៦, ៥-១២)

១៤ពួកសាវ័កភ្លេចយកនំប៉័ងទៅជាមួយ។ ក្នុង
ទូកគេមាននំប៉័ងតែមួយដុំប៉ុណ្ណោះ។ ១៥ព្រះយេស៊ូ

មានព្រះបន្ទូលដាស់តឿនគេថា៖ «ចូរអ្នករាល់គ្នា
ប្រុងប្រយ័ត្ននឹងមេម្សៅរបស់ពួកផារីស៊ី* ព្រមទាំងមេ
ម្សៅរបស់ស្ដេចហេរ៉ូដឲ្យមែនទែន»។ ១៦ពួកសាវ័ក*
ជជែកគ្នាថា៖ «លោកមានប្រសាសន៍ដូច្នេះមកពី
យើងគ្មាននំបុ័ងទេដឹង!»។ ១៧ព្រះយេស៊ូជ្រាបគំនិត
ពួកគេក៏មានព្រះបន្ទូលថា៖ «ម្ដេចក៏ជជែកគ្នាអំពី
រឿងគ្មាននំបុ័ងដូច្នេះ? តើអ្នករាល់គ្នាពុំទាន់ស្ដាប់បាន
ពុំទាន់យល់សេចក្ដីទេឬ? ឬមួយអ្នករាល់គ្នាមានចិត្ត
រឹងរូស?។ ១៨អ្នករាល់គ្នាមានភ្នែក តែមើលមិនឃើញ
មានត្រចៀកតែស្ដាប់មិនឮឬ!។ តើអ្នករាល់គ្នាចាំឬទេ
១៩កាលខ្ញុំកាច់នំបុ័ងប្រាំដុំចែកឲ្យមនុស្សប្រាំពាន់នាក់
តើអ្នករាល់គ្នាប្រមូលនំបុ័ងដែលសល់បានប៉ុន្មាន
ល្អី?»។ គេទូលព្រះអង្គថា៖ «ដប់ពីរល្អី»។ ២០«ចុះ
កាលខ្ញុំកាច់នំបុ័ងប្រាំពីរដុំចែកឲ្យមនុស្សបួនពាន់នាក់
តើអ្នករាល់គ្នាប្រមូលបានប៉ុន្មានជាល?»។ គេទូល
ថា៖ «ប្រាំពីរជាល»។២១ព្រះយេស៊ូមានព្រះបន្ទូល
ទៅគេថា៖ «អ្នករាល់គ្នានៅតែពុំទាន់យល់ទៀតឬ!»
។

## ព្រះយេស៊ូប្រោស មនុស្សខ្វាក់ម្នាក់ឲ្យបានភ្លឺ

២២ព្រះយេស៊ូនិងពួកសាវ័ក*ធ្វើដំណើរមក ដល់
ភូមិបេតសៃដា។ នៅពេលនោះ មានគេនាំមនុស្ស
ខ្វាក់ម្នាក់មកគាល់ព្រះអង្គ ហើយទូលអង្វរ សូមឲ្យ
ព្រះអង្គពាល់គាត់។ ២៣ព្រះយេស៊ូក៏ដឹកដៃមនុស្ស
ខ្វាក់នោះ នាំចេញទៅខាងក្រៅភូមិ ព្រះអង្គយកទឹក
ព្រះឱស្ឋដាក់លើភ្នែកគាត់ ហើយដាក់ព្រះហស្ដលើ
គាត់ ទាំងមានព្រះបន្ទូលសួរថា៖«តើអ្នកមើលឃើញ
អ្វីខ្លះទេ?» ២៤បុរសនោះបើកភ្នែកឡើងទូលថា៖ «ខ្ញុំ
ឃើញមនុស្សដើរស្រុងៗ មើលទៅដូចជាដើមឈើ»។
២៥ព្រះយេស៊ូក៏ដាក់ព្រះហស្ដលើភ្នែកគាត់ម្ដងទៀត។
បុរសនោះមើលឃើញច្បាស់ទាំងអស់ ភ្នែកគាត់បាន
ជា។ ២៦ព្រះយេស៊ូប្រាប់គាត់ឲ្យវិលត្រឡប់ទៅផ្ទះវិញ
ដោយមានព្រះបន្ទូលថា៖ «កុំចូលទៅក្នុងភូមិឲ្យ
សោះ»។

## លោកសិលាប្រកាសថាព្រះយេស៊ូជាព្រះគ្រីស្ដ

(ម៉ាថាយ ១៦, ១៣-២០ លូកា ៩, ១៨-២១)

២៧ព្រះយេស៊ូចេញទៅតាមភូមិនានា ដែលនៅ
ជិតក្រុងសេសារេភីលីពជាមួយពួកសាវ័ក*។ នៅតាម
ផ្លូវ ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើមនុស្ស
ទាំងឡាយថា ខ្ញុំជានរណា?»។ ២៨ពួកសាវ័កទូល
ឆ្លើយថា៖ «អ្នកខ្លះថាលោកជាលោកយ៉ូហានបាទីស្ដ
អ្នកខ្លះថាលោកជាព្យាការី*អេលី ហើយអ្នកខ្លះទៀត
ថាលោកជាព្យាការីមួយរូប»។ ២៩ព្រះអង្គមានព្រះ
បន្ទូលសួរគេថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នា
ថាខ្ញុំជានរណាដែរ?»។ លោកសិលាទូលព្រះអង្គថា
៖ «លោកជាព្រះគ្រីស្ដ»។ ៣០ព្រះយេស៊ូហាមប្រាម
សាវ័ក* មិនឲ្យនិយាយប្រាប់គេអំពីព្រះអង្គឡើយ។

៣១បន្ទាប់មក ព្រះយេស៊ូក៏ចាប់ផ្ដើមបង្រៀនពួក
សាវ័កថា បុត្រមនុស្ស*ត្រូវរងទុក្ខលំបាកយ៉ាងខ្លាំង។
ពួកព្រឹទ្ធាចារ្យ*ពួកនាយកបូជាចារ្យ*ពួកធម្មាចារ្យ*នឹង
បោះបង់ព្រះអង្គចោល ថែមទាំងធ្វើគុតព្រះអង្គទៀត
ផង តែបីថ្ងៃក្រោយមកព្រះអង្គនឹងមានព្រះជន្មរស់
ឡើងវិញ។ ៣២ព្រះអង្គមានព្រះបន្ទូលបញ្ជាក់ប្រាប់គេ
ដោយឥតលាក់លៀម។ លោកសិលាយាងព្រះអង្គ
ចេញទៅឆ្ងាយពីគេបន្តិច ហើយបន្ទោសព្រះអង្គ។
៣៣ព្រះយេស៊ូងាកទតទៅពួកសាវ័ក*ឯទៀតៗ ហើយ
ទ្រង់មានព្រះបន្ទូលបន្ទោសលោកសិលាវិញថា៖ «
នែ៎! មារសាតាំងថយទៅក្រោយខ្ញុំទៅ ដ្បិតគំនិតអ្នក
មិនមែនជាគំនិតរបស់ព្រះជាម្ចាស់ទេ គឺជាគំនិតរបស់
មនុស្សសុទ្ធសាធ»។

៣៤បន្ទាប់មកព្រះអង្គត្រាស់ហៅបណ្ដាជន និង

សាវ័ករួចមានព្រះបន្ទូលទៅគេថា៖ «បើអ្នកណាចង់
មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលី
ឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ។ ៣៥ដ្បិតអ្នក
ណាចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន
រីឯអ្នកដែលបាត់បង់ជីវិតព្រោះតែខ្ញុំនិង ព្រោះតែ
ដំណឹងល្អ*នឹងបានជីវិតវិញ។ ៣៦បើមនុស្សម្នាក់បាន
លោកីយ៍ទាំងមូល មកធ្វើជាសម្បត្តិរបស់ខ្លួន តែបាត់
បង់ជីវិតនោះ នឹងមានប្រយោជន៍អ្វី? ៣៧តើមនុស្ស
អាចយកអ្វីមកប្ដូរ នឹងជីវិតរបស់ខ្លួនបាន? ៣៨នៅក្នុង
ចំណោមមនុស្សដែលក្បត់ព្រះជាម្ចាស់និងក្នុង
ចំណោមមនុស្សមានបាបនាសម័យនេះ បើអ្នកណា
អៀនខ្មាសមិនហ៊ានទទួលស្គាល់ខ្ញុំ មិនហ៊ានទទួល
ស្គាល់ពាក្យរបស់ខ្ញុំ លុះដល់បុត្រមនុស្សយាងមក
ប្រកបដោយសិរីរុងរឿងរបស់ព្រះបិតាព្រះអង្គនិងទេវ
ទូត*ដ៏វិសុទ្ធ ទ្រង់ក៏នឹងខ្មាសអៀនមិនហ៊ានទទួល
ស្គាល់អ្នកនោះវិញដែរ»។
៩ ១ព្រះអង្គមានព្រះបន្ទូលថា៖ «ប្រាកដមែនខ្ញុំសុំ
ប្រាប់ ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា មនុស្សខ្លះដែលនៅ
ទីនេះនឹងមិនស្លាប់ទេ មុនបានឃើញព្រះរាជ្យរបស់
ព្រះជាម្ចាស់ មកដល់ប្រកបដោយឫទ្ធានុភាព»។

## សិរីរុងរឿងរបស់ព្រះយេស៊ូ

(ម៉ាថាយ ១៧, ១-១៣ លូកា ៩, ២៨-៣៦)

២ប្រាំមួយថ្ងៃក្រោយមក ព្រះយេស៊ូនាំលោក
សិលា លោកយ៉ាកុប និងលោកយ៉ូហានឡើងទៅលើ
ភ្នំ គឺព្រះអង្គនាំតែលោកទាំងបីទៅដាច់ឡែកពីគេ។
ពេលនោះ ព្រះអង្គប្រែជាមានទ្រង់ទ្រាយប្លែកពីមុន
នៅមុខសាវ័ក*ទាំងបីនាក់ ៣គឺព្រះពស្ត្ររបស់ព្រះអង្គ
ត្រឡប់ជាមានពណ៌សភ្លឺត្រចះត្រចង់ ដែលគ្មាន
មនុស្សណានៅលើផែនដីអាចធ្វើឲ្យសយ៉ាងនេះបាន
ឡើយ។ ៤ពេលនោះ សាវ័កទាំងបីនាក់ឃើញព្យា
ការី* អេលីនិងលោកម៉ូសេ*សន្ទនាជាមួយព្រះយេ
ស៊ូ។ ៥លោកសិលាទូលព្រះអង្គថា៖ «ព្រះគ្រូ! យើង
ខ្ញុំបាននៅទីនេះប្រសើរណាស់ យើងខ្ញុំនឹងសង់ជំរកបី
គឺមួយសម្រាប់ព្រះគ្រូ មួយសម្រាប់លោកម៉ូសេ និង
មួយទៀតសម្រាប់លោកអេលី»។ ៦លោកសិលា
មានប្រសាសន៍ដូច្នេះ មកពីលោកពុំដឹងថាចង់
និយាយអំពីអ្វីឡើយ ដ្បិតសាវ័កទាំងបីភ័យខ្លាចយ៉ាង
ខ្លាំង។ ៧ពេលនោះ ស្រាប់តែមានពពក*មកគ្របបាំង
គេទាំងអស់គ្នា មានព្រះសូរសៀងបន្លឺពីក្នុងពពកមក
ថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដា
ប់ព្រះអង្គចុះ!»។ ៨រំពេចនោះ ពួកសាវ័កក្រឡេក
មើលជុំវិញខ្លួន ពុំឃើញនរណាទៀតឡើយ ឃើញតែ
ព្រះយេស៊ូមួយព្រះអង្គប៉ុណ្ណោះ ដែលគង់ជាមួយគេ។
៩ពេលព្រះយេស៊ូយាងចុះពីលើភ្នំ ជាមួយសាវ័ក
ទាំងបី ទ្រង់ហាមប្រាមគេមិនឲ្យនិយាយអំពីហេតុ
ការណ៍ដែលខ្លួនបានឃើញ ប្រាប់នរណាឡើយរហូត
ដល់បុត្រមនុស្សរស់ឡើងវិញ។ ១០អ្នកទាំងបីធ្វើតាម
ព្រះបន្ទូលរបស់ព្រះអង្គ តែសាកសួរគ្នាថា៖ «តើ
"រស់ឡើងវិញ" មានន័យដូចម្ដេច?»។ ១១បន្ទាប់មក
គេទូលសួរព្រះអង្គថា៖ «ហេតុដូចម្ដេចបានជាពួកធ
ម្មាចារ្យចេះតែនិយាយថា ព្យាការីអេលីត្រូវអញ្ជើញ
មកមុន?»។ ១២ព្រះអង្គមានព្រះបន្ទូលតបទៅគេថា៖
«ព្យាការីអេលីអញ្ជើញមកមុនមែន ដើម្បីរៀបចំសព្វ
គ្រប់ទាំងអស់ឡើងវិញ។ ប៉ុន្តែហេតុអ្វីបានជាមាន
ចែងទុកក្នុងគម្ពីរថា បុត្រមនុស្សត្រូវរងទុក្ខលំបាកជា
ច្រើន ព្រមទាំងត្រូវគេមើលងាយផងដូច្នេះ?។ ១៣ខ្ញុំ
សុំប្រាប់អ្នករាល់គ្នាថា ព្យាការីអេលីបានអញ្ជើញមក
រួចហើយ តែពួកគេបានធ្វើបាបលោកសព្វបែបយ៉ាង
តាមអំពើចិត្តរបស់គេ ដូចមានចែងទុកក្នុងគម្ពីរអំពី
លោកស្រាប់»។

## ព្រះយេស៊ូដេញខ្មោចចេញពីក្មេងម្នាក់

(ម៉ាថាយ ១៧, ១៤-២១ លូកា ៩, ៣៧-៤៣)

១៤ព្រះយេស៊ូនិងអ្នកទាំងបី បានមកជួបសាវ័កឯ

ទៀតៗ ទ្រង់ទតឃើញបណ្ដាជនច្រើនកុះករឈរនៅជុំវិញសាវ័កទាំងនោះ ហើយឃើញពួកធម្មាចារ្យ* ជជែកជាមួយគេផង។ ១៥កាលបណ្ដាជនឃើញព្រះយេស៊ូ គេស្រឡាំងកាំងគ្រប់គ្នា ហើយរត់ទៅថ្វាយបង្គំព្រះអង្គ។ ១៦ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើអ្នករាល់គ្នាជជែកជាមួយគេអំពីរឿងអ្វី?»។ ១៧ក្នុងចំណោមបណ្ដាជន មានបុរសម្នាក់ទូលព្រះអង្គថា៖ «លោកគ្រូ! ខ្ញុំប្របាទនាំកូនប្រុសរបស់ខ្ញុំប្របាទមករកលោកគ្រូ ដ្បិតវាមានខ្មោចចូល ធ្វើឲ្យគនិយាយពុំរួច។ ១៨នៅទីណាក៏ដោយពេលខ្មោចចូលម្ដងៗ វាផ្ដួលកូនខ្ញុំប្របាទលើដីឲ្យបែកពពុះមាត់សង្កៀតធ្មេញ ហើយរឹងខ្លួន។ខ្ញុំប្របាទបានសុំសាវ័ករបស់លោកឲ្យដេញខ្មោចនេះដែរ ប៉ុន្តែគេពុំអាចដេញវាចេញបានសោះ»។ ១៩ព្រះយេស៊ូមានព្រះបន្ទូលទៅបណ្ដាជនថា៖ «នែ៎! ពួកមនុស្សពុំព្រមជឿអើយ! តើត្រូវឲ្យខ្ញុំទ្រាំនៅជាមួយអ្នករាល់គ្នាដល់ពេលណាទៀត? ចូរនាំក្មេងនោះមកឲ្យខ្ញុំ»។ ២០គេក៏នាំវាចូលមកជិតព្រះយេស៊ូ។ កាលខ្មោចឃើញព្រះអង្គ វាផ្ដួលក្មេងនោះឲ្យប្រកាច់ប្រកិន ព្រមទាំងននៀលបែកពពុះមាត់។ ២១ព្រះយេស៊ូសួរទៅឪពុកថា៖ «តើវាវេទនាបែបនេះតាំងពីអង្កាល់មក?»។ ឪពុកតបថា៖ «តាំងតែពីតូចម្ល៉េះ។ ២២ខ្មោចធ្វើឲ្យវាដួលលើភ្លើង ឲ្យវាធ្លាក់ក្នុងទឹកជាច្រើនលើកច្រើនសា ចង់ឲ្យវាបាត់បង់ជីវិត។ ប្រសិនបើលោកអាចធ្វើបាន សូមមេត្តាជួយយើងខ្ញុំសូមអាណិតអាសូរយើងខ្ញុំផង»។ ២៣ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ហេតុអ្វីបានជាអ្នកពោលថា "ប្រសិនបើលោកអាចជួយបាន"ដូច្នេះ? ព្រះជាម្ចាស់អាចសម្រេចកិច្ចការសព្វគ្រប់ទាំងអស់ ដល់អ្នកជឿ»។ ២៤ឪពុករបស់ក្មេងបន្លឺសំឡេងឡើងភ្លាមថា៖ «ខ្ញុំប្របាទជឿហើយ! សូមមេត្តាជួយឲ្យខ្ញុំប្របាទដែលជាអ្នកមិនជឿនេះផង!»។ ២៥ពេលនោះព្រះយេស៊ូទតឃើញបណ្ដាជនរត់មក ព្រះអង្គក៏គំរាមខ្មោចដោយបញ្ជាថា៖ «នែ៎ខ្មោចគថ្លង់! យើងសុំប្រាប់ថាចេញពីក្មេងនេះទៅ កុំចូលវាទៀតឲ្យសោះ!»។ ២៦ខ្មោចក៏ស្រែកឡើង ព្រមទាំងធ្វើឲ្យក្មេងនោះប្រកាច់ប្រកិនយ៉ាងខ្លាំង រួចចេញទៅ។ ពេលនោះក្មេងនៅដេកស្ដូកស្ដឹងដូចមនុស្សស្លាប់ ធ្វើឲ្យមនុស្សជាច្រើនស្មានថា វាស្លាប់បាត់ទៅហើយ។ ២៧រីឯព្រះយេស៊ូវិញ ព្រះអង្គចាប់ដៃវាលើកឡើងក្មេងនោះក៏ក្រោកឈរ។

២៨កាលព្រះយេស៊ូយាងចូលទៅក្នុងផ្ទះ ពួកសាវ័ក*ទូលសួរព្រះអង្គដាច់ឡែកពីគេថា៖ «ហេតុអ្វីបានជា យើងខ្ញុំពុំអាចដេញខ្មោចនេះចេញបាន?»។ ២៩ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «គេអាចដេញខ្មោចប្រភេទនេះបាន លុះត្រាតែអធិស្ឋាន*»។

## ព្រះយេស៊ូប្រកាសសាជាថ្មី អំពីព្រះអង្គត្រូវសោយទិវង្គត

(ម៉ាថាយ ១៧, ២២-២៣ លូកា ៩, ៤៣-៤៥)

៣០ព្រះយេស៊ូយាងចាកចេញពីទីនោះ ជាមួយពួកសាវ័ក* កាត់តាមស្រុកកាលីឡេ។ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យនរណាដឹងឡើយ។ ៣១ព្រះអង្គបង្រៀនពួកសាវ័កឲ្យដឹងថា បុត្រមនុស្ស*នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃ របស់មនុស្សលោក គេនឹងធ្វើគុតព្រះអង្គ ប៉ុន្តែ បីថ្ងៃក្រោយពីគេធ្វើគុត ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ។ ៣២ពួកសាវ័កពុំបានយល់ព្រះបន្ទូលនេះឡើយ តែគេមិនហ៊ានទូលសួរព្រះអង្គទេ។

## អ្នកដែលធំជាងគេ

(ម៉ាថាយ ១៨, ១-៥ លូកា ៩, ៤៦-៤៨)

៣៣ព្រះយេស៊ូនិងពួកសាវ័ក* ធ្វើដំណើរមកដល់ក្រុងកាផានុម។ កាលព្រះអង្គគង់នៅក្នុងផ្ទះ ព្រះអង្គមានព្រះបន្ទូលសួរពួកសាវ័កថា៖ «ពេលដើរតាមផ្លូវអ្នករាល់គ្នានិយាយអំពីរឿងអ្វី?»។ ៣៤ពួកសាវ័កនៅស្ងៀម ដ្បិតកាលធ្វើដំណើរតាមផ្លូវ គេបានប្រកែកគ្នា

ចង់ដឹងថា ក្នុងចំណោមពួកគេអ្នកណាធំជាងគេ។ ៣៥
ព្រះយេស៊ូគង់ចុះ ទ្រង់ត្រាស់ហៅសាវ័កទាំងដប់ពីរ
រូបមក ហើយមានព្រះបន្ទូលថា៖ «អ្នកណាចង់ធ្វើមេ
គេ អ្នកនោះត្រូវដាក់ខ្លួនឲ្យតូចជាងគេ ព្រមទាំងបម្រើ
គេទាំងអស់គ្នាផង»។ ៣៦បន្ទាប់មកព្រះអង្គយកក្មេង
ម្នាក់ ឲ្យមកឈរនៅកណ្ដាលពួកសាវ័ក។ ព្រះអង្គឱប
ក្មេងនោះ រួចមានព្រះបន្ទូលទៅកាន់ពួកសាវ័កថា៖
៣៧«អ្នកណាទទួលក្មេងណាម្នាក់ដូចក្មេងនេះក្នុង
នាមខ្ញុំ ក៏ដូចជាបានទទួលខ្ញុំ ហើយអ្នកណាទទួលខ្ញុំ
មិនត្រឹមតែទទួលខ្ញុំប៉ុណ្ណោះទេ គឺទទួលព្រះអង្គដែល
បានចាត់ខ្ញុំឲ្យមកនោះដែរ»។

## អ្នកណាមិនជំទាស់យើង អ្នកនោះជាពួកយើង

(លូកា៩, 8 ៤៩-៥០)

៣៨លោកយ៉ូហានទូលព្រះអង្គថា៖ «ព្រះគ្រូ!
យើងខ្ញុំបានឃើញបុរសម្នាក់ដេញខ្មោច ក្នុងនាមព្រះ
គ្រូ។ យើងខ្ញុំបានឃាត់គេ ព្រោះគេមិនមកតាមយើង
ខ្ញុំទេ»។ ៣៩ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កុំឃាត់
គេអី ពុំដែលមាននរណាអាចធ្វើការអស្ចារ្យក្នុងនាមខ្ញុំ
រួចបែរជានិយាយអាក្រក់អំពីខ្ញុំភ្លាមនោះឡើយ ៤០
ដ្បិតអ្នកណាមិនជំទាស់នឹងយើង អ្នកនោះជាគ្នាយើង
ហើយ។ ៤១ម្យ៉ាងទៀត បើអ្នកណាឲ្យទឹកមួយកែវ
ដល់អ្នករាល់គ្នា ក្នុងនាមអ្នករាល់គ្នាជាសិស្សរបស់
ព្រះគ្រីស្ត* ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នក
នោះនឹងទទួលរង្វាន់ជាមិនខាន»។

## កុំនាំអ្នកដទៃឲ្យប្រព្រឹត្តអំពើបាប

(ម៉ាថាយ ១៨, ៦-៩ លូកា ១៧, ១-២)

៤២អ្នកណានាំអ្នកតូចតាចម្នាក់ ក្នុងបណ្ដាអ្នក
ជឿទាំងនេះឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នកនោះ
ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងកគាត់
ទម្លាក់ទៅក្នុងសមុទ្រ នោះប្រសើរជាជាងទុកឲ្យគាត់
នៅរស់។ ៤៣ប្រសិនបើដៃនាំអ្នកឲ្យប្រព្រឹត្តអំពើបាប
ចូរកាត់ចោលទៅ ព្រោះបើអ្នកចូលទៅក្នុងជីវិតមាន
ដៃតែម្ខាង ប្រសើរជាងមានដៃពីរ ហើយត្រូវធ្លាក់ទៅ
ក្នុងនរក ដែលមានភ្លើងមិនចេះរលត់{ ៤៤ជាកន្លែង
ដែលមានដង្កូវមិនចេះងាប់ មានភ្លើងមិនចេះរលត់}
។ ៤៥ប្រសិនបើ ជើងនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរ
កាត់ចោលទៅ ព្រោះបើអ្នកចូលទៅក្នុងជីវិត មានតែ
ជើងមួយ នោះប្រសើរជាងមានជើងពីរ ហើយត្រូវគេ
បោះទៅក្នុងនរក{៤៦ជាកន្លែងដែលមានដង្កូវមិនចេះ
ងាប់ មានភ្លើងមិនចេះរលត់}។ ៤៧ប្រសិនបើភ្នែកនាំ
អ្នកឲ្យប្រព្រឹត្តអំពើបាប ចូរខ្វេះចេញទៅ ព្រោះបើអ្នក
ចូលទៅក្នុងព្រះរាជ្យ* ព្រះជាម្ចាស់មានតែភ្នែកម្ខាង
នោះប្រសើរជាងមានភ្នែកពីរ ហើយត្រូវគេបោះទៅ
ក្នុងនរក ៤៨ជាកន្លែងដែលមានដង្កូវមិនចេះងាប់ មាន
ភ្លើងមិនចេះរលត់ ៤៩ដ្បិតមនុស្សគ្រប់ៗរូបនឹងមាន
ជាតិប្រៃដោយសារភ្លើង។ ៥០អំបិលជារបស់មួយ
សំខាន់ណាស់ ប៉ុន្តែបើវាបាត់ជាតិប្រៃហើយ តើអ្នក
រាល់គ្នាធ្វើដូចម្ដេច នឹងឲ្យវាប្រៃឡើងវិញបាន? ៥១ចូរ
មានជាតិប្រៃនៅក្នុងខ្លួន ហើយរស់នៅជាមួយគ្នា
ដោយសុខសាន្តទៅ»។

## ព្រះដំបូន្មានអំពីរឿងលែងលះប្ដីប្រពន្ធ

(ម៉ាថាយ ១៩, ១-១២ លូកា ១៦, ១៨)

១០ ១ព្រះយេស៊ូយាងចេញ ពីទីនោះ ឆ្ពោះទៅស្រុក
យូដា និងត្រើយខាងនាយទន្លេយ័រដាន់។ មហាជន
នាំគ្នាទៅរកព្រះអង្គសាជាថ្មី ព្រះអង្គក៏ចាប់ផ្ដើម
បង្រៀនគេ តាមទម្លាប់របស់ព្រះអង្គ។ ២មានពួកខាង
គណៈផារីស៊ី*ចូលមកជិត ក្នុងគោលបំណងល្បងល
មើលព្រះអង្គ។ គេទូលសួរព្រះអង្គថា៖ «តើស្វាមី
មានសិទ្ធិលែងភរិយាបានឬទេ?»។ ៣ព្រះអង្គមាន
ព្រះបន្ទូលថា៖ «តើលោកម៉ូសេបង្គាប់អ្នករាល់គ្នា ឲ្យ
ធ្វើអ្វី?»។ ៤គេទូលតបថា៖«លោកម៉ូសេអនុញ្ញាតឲ្យ

ស្វាមី ធ្វើលិខិតលែងលះប្រពន្ធបាន»។ ៥ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «លោកម៉ូសេចែងវិន័យ*
នេះឲ្យអ្នករាល់គ្នា ព្រោះតែអ្នករាល់គ្នាមានចិត្តរឹងរូ
ស។ ៦ប៉ុន្តែកាលដើមដំបូង នៅពេលដែលព្រះជា
ម្ចាស់ បានបង្កើតពិភពលោក ព្រះអង្គបង្កើតមនុស្ស
មកជាបុរសជាស្ត្រី។ ៧"ហេតុនេះហើយ បានជាបុរស
ត្រូវចាកចេញពីឪពុកម្ដាយ {ទៅរួមរស់ជាមួយភរិយា
របស់ខ្លួន}[ម] ៨ហើយអ្នកទាំងពីរត្រឡប់ទៅជារូប
កាយតែមួយ" គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺ
ជារូបកាយតែមួយវិញ។ ៩ដូច្នេះមនុស្សមិនត្រូវ
បំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំ
នោះឡើយ»។ ១០ពេលទៅដល់ផ្ទះ ពួកសាវ័កទូល
សួរព្រះយេស៊ូអំពីរឿងនេះម្ដងទៀត។ ១១ព្រះអង្គមាន
ព្រះបន្ទូលទៅគេថា៖ «ប្រសិនបើស្វាមីណាលែង
ភរិយា ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត ស្វាមី
នោះបានផិតក្បត់ភរិយារបស់ខ្លួន។ ១២រីឯភរិយាណា
ដែលលែងស្វាមី ហើយទៅរៀបការនឹងបុរសម្នាក់
ទៀត ស្ត្រីនោះក៏បានប្រព្រឹត្តអំពើផិតក្បត់ដែរ»។

## ព្រះយេស៊ូប្រទានពរដល់ក្មេងៗ

(ម៉ាថាយ ១៩, ១៣-១៥ លូកា ១៨, ១៥-១៧)

១៣មានមនុស្សម្នានាំក្មេងតូចៗ មកឲ្យព្រះ
យេស៊ូដាក់ព្រះហស្ដលើពួកវា ប៉ុន្តែពួកសាវ័ក*ស្តី
បន្ទោសអ្នកទាំងនោះ។ ១៤កាលព្រះយេស៊ូឃើញ
ដូច្នោះ ព្រះអង្គទាស់ព្រះហឫទ័យណាស់ ហើយមាន
ព្រះបន្ទូលថា៖ «ទុកឲ្យក្មេងៗមករកខ្ញុំចុះ កុំឃាត់ពួក
វាឡើយ ដ្បិតមានតែ អ្នកមានចិត្តដូចក្មេងៗទាំងនេះ
ប៉ុណ្ណោះ ដែលចូលក្នុងព្រះរាជ្យ*ព្រះជាម្ចាស់បាន។
១៥ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាមិន
ព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ដូចក្មេងតូចមួយទេ
អ្នកនោះមិនអាចចូលក្នុងព្រះរាជ្យព្រះអង្គបាន
ឡើយ»។

១៦បន្ទាប់មក ព្រះអង្គអោបក្មេងទាំងនោះ រួច
ប្រទានពរឲ្យពួកវា ដោយដាក់ព្រះហស្ដពីលើ។

## អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច

(ម៉ាថាយ ១៩, ១៦-៣០ លូកា ១៨, ១៨-៣០)

១៧កាលព្រះយេស៊ូកំពុងចេញដំណើរទៅ មាន
បុរសម្នាក់រត់មកដល់ លុតជង្គង់ចុះនៅមុខព្រះអង្គ
ទូលថា៖ «លោកគ្រូដ៏សប្បុរសអើយ! តើខ្ញុំត្រូវធ្វើអ្វី
ដើម្បីឲ្យបានទទួលជីវិតអស់កល្បជានិច្ច ទុកជាមត៌
ក?»។ ១៨ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ហេតុ
អ្វីបានជាអ្នកថា ខ្ញុំសប្បុរសដូច្នេះ? ក្រៅពីព្រះជា
ម្ចាស់មួយព្រះអង្គ គ្មាននរណាម្នាក់សប្បុរសឡើយ។
១៩អ្នកស្គាល់វិន័យស្រាប់ហើយថា"កុំសម្លាប់មនុស្ស
កុំប្រព្រឹត្តអំពើផិតក្បត់កុំលួចទ្រព្យសម្បត្តិគេ កុំ
និយាយកុហកធ្វើឲ្យគេមានទោសកុំកេងប្រវ័ញ្ចយក
សម្បត្តិនរណាឲ្យសោះ ចូរគោរពមាតាបិតា"ឈ»។
២០បុរសនោះទូលព្រះអង្គថា៖ «លោកគ្រូអើយ! ខ្ញុំ
បានប្រតិបត្តិតាមវិន័យ*ទាំងនេះតាំងពីក្មេងមក»។
២១ព្រះយេស៊ូទតមើលទៅគាត់ ហើយមានព្រះហឫទ័
យស្រឡាញ់គាត់ ទ្រង់មានព្រះបន្ទូលថា៖ «នៅខ្វះ
កិច្ចការមួយទៀតដែលអ្នកមិនទាន់ធ្វើ គឺត្រូវអញ្ជើញ
ទៅលក់អ្វីៗដែលអ្នកមាន រួចចែកឲ្យជនក្រីក្រទៅធ្វើ
ដូច្នេះ ទើបអ្នកមានសម្បត្តិសួគ៌បន្ទាប់មក សឹម
អញ្ជើញមកតាមខ្ញុំ»។ ២២កាលបុរសនោះឮដូច្នេះ
គាត់មានទឹកមុខស្រពោនហើយវិលត្រឡប់ទៅវិញ
ទាំងព្រួយចិត្ត ដ្បិតគាត់មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ
ណាស់។

២៣ព្រះយេស៊ូទតមើលជុំវិញ រួចមានព្រះបន្ទូល
ទៅពួកសាវ័កថា៖ «អ្នកមានមិនងាយចូលទៅក្នុង
ព្រះរាជ្យ*ព្រះជាម្ចាស់បានទេ»។ ២៤ពួកសាវ័កងឿង
ឆ្ងល់នឹងព្រះបន្ទូលរបស់ព្រះអង្គជាខ្លាំង។ ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេទៀតថា៖ «កូនចៅអើយព្រះ

រាជ្យព្រះជាម្ចាស់ពិបាកចូលណាស់! ២៥សត្វអូដ្ឋចូល
តាមប្រហោងម្ជុល ងាយជាងអ្នកមានចូលក្នុងព្រះ
រាជ្យ*ព្រះជាម្ចាស់ទៅទៀត»។ ២៦ពួកសាវ័ករឹតតែ
ឆ្ងល់ថែមទៀត ហើយនិយាយគ្នាថា៖ «បើដូច្នេះតើ
អ្នកណាអាចទទួលការសង្គ្រោះបាន?»។ ២៧ព្រះ
យេស៊ូទតមើលគេ រួចមានព្រះបន្ទូលថា៖ «ការនេះ
មនុស្សធ្វើពុំកើតទេ តែព្រះជាម្ចាស់ធ្វើកើត ដ្បិតព្រះ
អង្គធ្វើគ្រប់ការទាំងអស់បាន»។ ២៨លោកសិលាទូល
ព្រះអង្គថា៖ «ព្រះអង្គទតឃើញស្រាប់ហើយថា
យើងខ្ញុំបានលះបង់ចោលអ្វីៗទាំងអស់ ហើយ យើង
ខ្ញុំបានមកតាមព្រះអង្គ»។ ២៩ព្រះយេស៊ូមានព្រះ
បន្ទូលតបថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ថា អ្នកណាលះបង់ផ្ទះសម្បែង បងប្អូនប្រុសស្រី
ឪពុកម្ដាយ កូន ឬស្រែចំការ ព្រោះតែខ្ញុំ និង ព្រោះតែ
ដំណឹងល្អ* ៣០អ្នកនោះនឹងទទួលក្នុងពេលឥឡូវនេះ
មួយជាមួយរយ គឺផ្ទះសម្បែងបងប្អូនប្រុសស្រី ម្ដាយ
កូន និងស្រែចំការ ព្រមទាំងទទួលការបៀតបៀន
ហើយក៏នឹងមានជីវិតអស់កល្បជានិច្ច នៅលោកខាង
មុខថែមទៀតផង។ ៣១មនុស្សជាច្រើនដែលនៅខាង
មុខ នឹងត្រឡប់ទៅនៅខាងក្រោយ រីឯអ្នកដែលនៅ
ខាងក្រោយ នឹងត្រឡប់ទៅនៅខាងមុខវិញ»។

## ព្រះយេស៊ូប្រកាសជាលើកទីបីអំពីព្រះអង្គចូលទិវង្គត

(ម៉ាថាយ២០, ១៧-១៩ លូកា១៨, ៣១-៣៤)

៣២ព្រះយេស៊ូយាងឡើងទៅ ក្រុងយេរូសាឡឹម
ជាមួយពួកសាវ័ក*។ព្រះអង្គយាងនាំមុខ គេពួកសាវ័
កភ័យខ្លាចជាខ្លាំង រីឯអស់អ្នកដែលដើរតាមក្រោយក៏
ភិតភ័យដែរ។ ព្រះយេស៊ូនាំសាវ័កទាំងដប់ពីររូបមក
ជាមួយព្រះអង្គសាជាថ្មី រួចមានព្រះបន្ទូលអំពីហេតុ
ការណ៍ ដែលនឹងកើតមានដល់ព្រះអង្គ៖ ៣៣«ឥឡូវ
នេះ យើងឡើងទៅក្រុងយេរូសាឡឹមបុត្រមនុស្ស*
នឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់ពួកនាយក
បូជាចារ្យ និងពួកធម្មាចារ្យ។ គេនឹងកាត់ទោស
ប្រហារជីវិតលោក ហើយបញ្ជូនលោកទៅក្នុងក
ណ្ដាប់ដៃ របស់សាសន៍ដទៃ។៣៤ពួកនោះនឹងចំអក
ឲ្យលោក ព្រមទាំងស្ដោះទឹកមាត់ដាក់លោកផង។ គេ
នឹងវាយធ្វើបាបលោក រួចប្រហារជីវិតលោក។ ប៉ុន្តែបី
ថ្ងៃក្រោយមកលោកនឹងរស់ឡើងវិញ»។

## សំណូមពររបស់លោកយ៉ាកុប និង លោកយ៉ូហាន

(ម៉ាថាយ២០, ២០-២៨)

៣៥បន្ទាប់ មកលោកយ៉ាកុប និងលោកយ៉ូហាន
ជាកូនលោកសេបេដេ ចូលមកគាល់ព្រះយេស៊ូទូល
ថា៖ «ព្រះគ្រូ! សូមមេត្តាយល់ព្រមតាមពាក្យសុំ
របស់យើងខ្ញុំផង»។ ៣៦ព្រះយេស៊ូមានព្រះបន្ទូលសួរ
គេថា៖ «តើអ្នកទាំងពីរចង់ឲ្យខ្ញុំធ្វើអ្វី?»។ ៣៧គេទូល
ព្រះអង្គថា៖ «ពេលព្រះគ្រូគ្រងរាជ្យប្រកបដោយសិរី
រុងរឿង សូមប្រទានឲ្យយើងខ្ញុំបានអង្គុយអមព្រះគ្រូ
ផង គឺម្នាក់នៅខាងស្ដាំ ម្នាក់នៅខាងឆ្វេង»។ ៣៨ព្រះ
យេស៊ូមានព្រះបន្ទូលថា៖«អ្នកទាំងពីរមិនដឹងថាខ្លួន
សុំអ្វីឡើយ តើអ្នកអាចទទួលពែងដែលខ្ញុំត្រូវទទួល
នោះបានឬទេ? អ្នកអាចទទួលពិធីជ្រមុជដែលខ្ញុំត្រូវ
ទទួលបានឬទេ?»។ ៣៩គេទូលព្រះអង្គថា៖ «យើង
ខ្ញុំអាចទទួលបាន»។ព្រះយេស៊ូមានព្រះបន្ទូលថា៖
«អ្នកនឹងទទួលពែងដែលខ្ញុំត្រូវទទួល និងទទួលពិធី
ជ្រមុជដែលខ្ញុំត្រូវទទួលបានមែន ៤០ចំណែកឯអង្គុយ
នៅខាងស្ដាំ ឬខាងឆ្វេងខ្ញុំ ខ្ញុំមិនអាចសម្រេចបាន
ឡើយ ព្រោះកន្លែងនោះបម្រុងទុកសម្រាប់តែអ្នក
ដែលព្រះជាម្ចាស់បានសម្រេចឲ្យប៉ុណ្ណោះ»។

៤១កាលសាវ័កដប់រូបទៀតបានឮដូច្នោះ គេ
ទាស់ចិត្តនឹងលោកយ៉ាកុប និងលោកយ៉ូហាន ជាខ្លាំ
ង។ ៤២ព្រះយេស៊ូត្រាស់ហៅសាវ័កទាំងអស់ មក

ហើយមានព្រះបន្ទូលថា៖ «អ្នករាល់គ្នាដឹងស្រាប់ហើយ អ្នកដែលគេចាត់ទុកជាមេគ្រប់គ្រងស្រុកតែងជិះជាន់ប្រជារាស្ត្ររបស់ខ្លួន រីឯអ្នកធំតែងតែប្រើអំណាចខ្លួនលើប្រជារាស្ត្រ។ [៤៣]ក្នុងចំណោមអ្នករាល់គ្នាមិនមែនដូច្នោះទេ។ ផ្ទុយទៅវិញ បើមានម្នាក់ចង់ធ្វើធំជាងគេក្នុងចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នា។ [៤៤]ក្នុងចំណោមអ្នករាល់គ្នា បើមានម្នាក់ចង់ធ្វើមេគេត្រូវធ្វើជាខ្ញុំបម្រើគេគ្រប់គ្នាសិន [៤៥]ដ្បិតបុត្រមនុស្ស*មកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោកឡើយ គឺលោកមកបម្រើគេវិញ ព្រមទាំងបូជាជីវិតដើម្បីលោះមនុស្សទាំងអស់ផង»។

## ព្រះយេស៊ូប្រោសមនុស្សខ្វាក់ម្នាក់ឈ្មោះបារទីមេ ឲ្យបានភ្លឺ

(ម៉ាថាយ ២០, ២៩-៣៤ លូកា ១៨, ៣៥-៤៣)

[៤៦]ព្រះយេស៊ូនិងពួកសាវ័ក ធ្វើដំណើរមកដល់ក្រុងយេរីខូ។ កាលព្រះអង្គយាងចេញពីទីក្រុងជាមួយពួកសាវ័ក និងបណ្ដាជនដ៏ច្រើនកុះករ មានមនុស្សខ្វាក់ម្នាក់ឈ្មោះបារទីមេ ជាកូនរបស់លោកទីមេអង្គុយសុំទាននៅក្បែរផ្លូវ។ [៤៧]កាលគាត់ឮថា ព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត យាងតាមនោះ គាត់ក៏ស្រែកឡើងថា៖ «ឱព្រះយេស៊ូ ជាព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាទូលបង្គំផង»។ [៤៨]មនុស្សជាច្រើនបានគំរាមគាត់ ឲ្យនៅស្ងៀម ប៉ុន្តែគាត់ស្រែករឹតតែខ្លាំងឡើងៗថា៖ «ឱព្រះរាជវង្សព្រះបាទដាវីឌអើយ សូមអាណិតមេត្តាទូលបង្គំផង!»។ [៤៩]ព្រះយេស៊ូក៏ឈប់ហើយមានព្រះបន្ទូលថា៖ «សុំហៅគាត់មក»។ គេហៅមនុស្សខ្វាក់មកដោយពោលថា៖ «កុំអស់សង្ឃឹម ក្រោកឡើងលោកហៅអ្នក»។ [៥០]គាត់ក៏បោះអាវធំចោល ស្ទុះក្រោកឡើងតម្រង់ទៅរកព្រះយេស៊ូ។ [៥១]ព្រះយេស៊ូមានព្រះបន្ទូល សួរគាត់ថា៖ «តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វី?»។ អ្នកខ្វាក់ទូលព្រះអង្គថា៖ «ព្រះគ្រូ! សូមប្រោសភ្នែកទូលបង្គំឲ្យបានភ្លឺផង»។ [៥២]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញទៅចុះ!ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ!»។ រំពេចនោះ គាត់មើលឃើញភ្លាម ហើយដើរតាមផ្លូវជាមួយព្រះយេស៊ូទៅ។

## ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

(មថ ២១, ១-១១ លក ១៩, ២៨-៤០ យហ ១២, ១២-១៩)

១១ [១]ព្រះយេស៊ូយាងមកជាមួយសាវ័ក ជិតដល់ក្រុងយេរូសាឡឹមហើយ។ លុះមកដល់ជិតភូមិបេតផាសេ និងភូមិបេថានី ដែលនៅចង្កេះភ្នំដើមអូលីវព្រះអង្គចាត់សាវ័កពីររូបឲ្យទៅមុន ដោយមានព្រះបន្ទូលថា៖ [២]«ចូរទៅភូមិនៅមុខអ្នករាល់គ្នា ពេលទៅដល់ភ្លាមអ្នកនឹងឃើញកូនលាមួយដែលគេចងទុក ពុំទាន់ដែលមាននរណាជិះនៅឡើយទេ ចូរស្រាយវាដឹកមក។ [៣]ប្រសិនបើមានគេសួរថា "ហេតុអ្វីបានជាអ្នកស្រាយវា?" ចូរឆ្លើយប្រាប់គេថា "ព្រះអម្ចាស់ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជាមិនខាន"»។

[៤]សាវ័កទាំងពីររូបចេញដំណើរទៅ ឃើញកូនលាមួយដែលគេចងទុកនៅមាត់ទ្វារ ខាងក្រៅផ្ទះក្បែរផ្លូវ ហើយក៏ស្រាយវា។ [៥]មានអ្នកខ្លះនៅទីនោះ សួរអ្នកទាំងពីរថា៖ «តើអ្នកធ្វើអ្វីហ្នឹង ហេតុអ្វីបានជាអ្នកស្រាយកូនលានេះ?»។ [៦]សាវ័កទាំងពីរឆ្លើយទៅគេតាមពាក្យដែលព្រះយេស៊ូបានបង្គាប់មក គេក៏ឲ្យដឹកចេញទៅ។ [៧]សាវ័កទាំងពីរដឹកវាយកមកថ្វាយព្រះយេស៊ូ ហើយយកអាវរបស់ខ្លួនក្រាលពីលើខ្នងកូនលា ព្រះអង្គក៏ឡើងគង់លើខ្នងកូនលានោះ។ [៨]មានមនុស្សម្នាជាច្រើន នាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ ហើយខ្លះទៀតយកស្លឹកឈើពីចំការមករាយលើផ្លូវដែរ។ [៩]អស់អ្នកដែលដើរហែហមព្រះយេស៊ូពីមុខ

ពីក្រោយនាំគ្នាស្រែកឡើងថា៖ «ជយោ! សូមព្រះជា
ម្ចាស់ប្រទានពរដល់ព្រះអង្គ ដែលយាងមកក្នុងព្រះ
នាមព្រះអម្ចាស់ ១០សូមព្រះជាម្ចាស់ប្រទានពរដល់
ព្រះរាជ្យ*ដែលកំពុងតែមកដល់ គឺព្រះរាជ្យរបស់
ព្រះបាទដាវីឌ ជាបិតារបស់យើង! ជយោ! ព្រះជា
ម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»។
១១កាល ព្រះយេស៊ូទៅដល់ក្រុងយេរូសាឡឹម
ទ្រង់ក៏យាងចូលក្នុងព្រះវិហារ*។ ក្រោយពីបានទត
មើលសព្វគ្រប់អស់ហើយ ព្រះអង្គយាងទៅភូមិបេថា
នីជាមួយសាវ័កទាំងដប់ពីររូប ដ្បិតល្ងាចណាស់ហើ
យ។

## ដើមឧទុម្ពរត្រូវបណ្ដាសា

(ម៉ាថាយ ២១, ១៨-១៩)

១២នៅថ្ងៃបន្ទាប់ ព្រះអង្គយាងចេញពីភូមិបេថា
នី ពេលនោះ ព្រះអង្គឃ្លាន។ ១៣ព្រះអង្គទតឃើញ
ឧទុម្ពរ*មួយដើមពីចម្ងាយ មានស្លឹកខៀវខ្ចី ទ្រង់ក៏
យាងតម្រង់ទៅ ក្រែងលោមានផ្លែ។ ពេលព្រះអង្គ
យាងទៅជិត ទ្រង់ទតឃើញមានតែស្លឹកប៉ុណ្ណោះ
ដ្បិតពុំទាន់ដល់រដូវឧទុម្ពរផ្លែនៅឡើយទេ។ ១៤ព្រះ
យេស៊ូមានព្រះបន្ទូល ទៅកាន់ដើមឧទុម្ពរនោះថា៖ «
ចាប់ពីពេលនេះតទៅ គ្មាននរណាបរិភោគផ្លែរបស់
ឯងទៀតឡើយ!»។ ពួកសាវ័ក* បានឮព្រះបន្ទូល
របស់ព្រះអង្គ។

## ព្រះយេស៊ូដេញអ្នកលក់ដូរចេញពីព្រះវិហារ

(មថ ២១,១២-១៧ លក ១៩,៤៥-៤៨ យហ ២, ១៣-២២)

១៥ព្រះយេស៊ូយាងមក ដល់ក្រុងយេរូសាឡឹម
ជាមួយពួកសាវ័ក ព្រះអង្គយាងចូលក្នុងព្រះវិហារ
ហើយដេញអ្នកលក់ដូរចេញ។ ព្រះអង្គផ្ដួលតុពួកអ្នក
ប្ដូរប្រាក់ ផ្ដួលកៅអីរបស់អ្នកលក់ព្រាប។ ១៦ព្រះអង្គ
មិនឲ្យនរណាលីសែងអីវ៉ាន់ កាត់ទីធ្លាព្រះវិហារ*ឡើ
យ។ ១៧ព្រះអង្គមានព្រះបន្ទូលប្រៀនប្រដៅគេថា៖
«ក្នុងគម្ពីរមានចែងថា
*ដំណាក់របស់យើងត្រូវធ្វើជាដំណាក់*
*សម្រាប់ឲ្យជាតិសាសន៍ទាំងឡាយអធិស្ឋាន**
*តែអ្នករាល់គ្នាយកធ្វើជាសំបុកចោរទៅវិញ»។*
១៨កាលពួកនាយកបូជាចារ្យ* និងពួកធម្មាចារ្យ*
ដឹងរឿងនេះ គេនាំគ្នារកមធ្យោបាយធ្វើគុតព្រះយេ
ស៊ូ។ ប៉ុន្តែគេខ្លាចព្រះអង្គ ដ្បិតបណ្ដាជនទាំងមូល
ចាប់អារម្មណ៍នឹងសេចក្ដី ដែលព្រះអង្គបង្រៀនណា
ស់។ ១៩លុះដល់ល្ងាច ព្រះយេស៊ូយាងចាកចេញពីទី
ក្រុងជាមួយពួកសាវ័ក។

## ដើមឧទុម្ពរងាប់

(ម៉ាថាយ ២១, ២០-២២)

២០ព្រឹកឡើងពេលធ្វើដំណើរតាមផ្លូវនោះ ពួក
សាវ័កឃើញដើមឧទុម្ពរ*ក្រៀមស្វិត រហូតដល់ឫស។
២១លោកសិលានឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ
ក៏ទូលព្រះអង្គថា៖ «ព្រះគ្រូ! សូមមើល! ដើមឧទុម្ពរ
ដែលព្រះគ្រូបានដាក់បណ្ដាសានោះក្រៀមស្វិតទៅ
ហើយ!»។ ២២ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួក
សាវ័ក*ថា៖ «ចូរមានជំនឿលើព្រះជាម្ចាស់ចុះ!។ ២៣
ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើអ្នកណាម្នាក់
និយាយទៅកាន់ភ្នំនេះថា "ចូរចេញពីទីនេះ ធ្លាក់ក្នុង
សមុទ្រទៅ!" ហើយបើអ្នកនោះជឿជាក់ក្នុងចិត្ត
ដោយឥតសង្ស័យថាពាក្យរបស់ខ្លួននឹងបានសម្រេច
នោះព្រះជាម្ចាស់នឹងប្រទានឲ្យបានសម្រេច តាម
ពាក្យគេមែន។ ២៤ហេតុនេះហើយ បានជាខ្ញុំសុំប្រាប់
អ្នករាល់គ្នាថា អ្វីក៏ដោយឲ្យតែអ្នករាល់គ្នាអធិស្ឋាន*
សុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជា
ម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។ ២៥ម្យ៉ាង
ទៀតពេលឈរអធិស្ឋាន បើអ្នករាល់គ្នាមានទំនាស់អ្វី
នឹងនរណាម្នាក់ ចូរអត់ទោសឲ្យគេទៅ ដើម្បីព្រះបិតា
របស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ*អត់

ទោសឲ្យអ្នករាល់គ្នា។ {២៦ប៉ុន្តែប្រសិនបើអ្នករាល់គ្នាមិនអត់ទោសឲ្យគេទេ ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ* ក៏មិនអត់ទោសឲ្យអ្នករាល់គ្នាដែរ។}

## អំណាចរបស់ព្រះយេស៊ូ

(ម៉ាថាយ២១, ២៣-២៧ លូកា២០, ១-៨)

២៧ព្រះយេស៊ូយាងចូល ទៅក្រុងយេរូសាឡឹមជាមួយពួកសាវ័ក*ម្ដងទៀត។ កាលព្រះអង្គកំពុងតែយាងចុះយាងឡើងក្នុងព្រះវិហារ* ពួកនាយកបូជាចារ្យ និងពួកធម្មាចារ្យនាំគ្នាមកជួបព្រះអង្គ។ ២៨គេទូលសួរព្រះអង្គថា៖ «តើលោកធ្វើការទាំងនេះដោយអាងអំណាចអ្វី? តើនរណាប្រគល់អំណាចឲ្យលោកធ្វើការទាំងនេះ?»។ ២៩ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំសុំសួរអស់លោកនូវសំណួរមួយបើអស់លោកឆ្លើយមកខ្ញុំ ខ្ញុំនឹងប្រាប់អស់លោកវិញថា ខ្ញុំធ្វើការទាំងនេះដោយអាងលើអំណាចអ្វី។ ៣០សូមឆ្លើយប្រាប់ខ្ញុំមើល៍ តើនរណាចាត់លោកយ៉ូហានឲ្យមកធ្វើពិធីជ្រមុជទឹក*? ព្រះជាម្ចាស់ឬមនុស្ស?»។ ៣១គេពិគ្រោះគ្នាថា៖ «បើយើងឆ្លើយថា ព្រះជាម្ចាស់ចាត់លោកយ៉ូហានឲ្យមក គាត់មុខជាសួរយើងថា ហេតុអ្វីបានជាអ្នករាល់គ្នាមិនជឿលោកយ៉ូហាន? ៣២ផ្ទុយទៅវិញបើយើងឆ្លើយថាមនុស្សចាត់លោកឲ្យមក,,,» (ពួកគេខ្លាចប្រជាជនព្រោះមនុស្សគ្រប់ៗគ្នា ចាត់ទុកលោកយ៉ូហានជាព្យាការីពិតប្រាកដមែន)។ ៣៣ដូច្នេះគេឆ្លើយទៅព្រះយេស៊ូថា៖ «យើងមិនដឹងទេ!»។ព្រះយេស៊ូមានព្រះបន្ទូលទៅគេវិញថា៖ «រីឯខ្ញុំវិញ ខ្ញុំក៏មិនប្រាប់អស់លោកថា ខ្ញុំធ្វើការទាំងនេះដោយអាងលើអំណាចអ្វីដែរ»។

## ប្រស្នាអំពីអ្នកថែរក្សាចំការទំពាំងបាយជូរ

(ម៉ាថាយ២១, ៣៣-៤៦ លូកា២០, ៩-១៩)

១២ ១បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅគេជាប្រស្នាថា៖ «មានបុរសម្នាក់ដាំទំពាំងបាយជូរមួយចំការ។ គាត់បានធ្វើរបងព័ទ្ធជុំវិញ គាត់រៀបចំកន្លែងមួយដើម្បីបញ្ជាន់ផ្លែទំពាំងបាយជូរ ព្រមទាំងសង់ខ្ទមមួយផង។ បន្ទាប់មក គាត់ប្រវាស់ឲ្យពួកកសិករមើលថែទាំ រួចចេញដំណើរពីស្រុកនោះទៅ។ ២លុះដល់ទំពាំងបាយជូរទុំ គាត់ក៏ចាត់អ្នកបម្រើម្នាក់ឲ្យមកទទួលផល ដែលជាចំណែករបស់គាត់ពីពួកអ្នកថែចំការ។

៣គេនាំគ្នាចាប់អ្នកបម្រើនោះវាយដំ ហើយបណ្ដេញឲ្យត្រឡប់ទៅវិញដៃទទេ។ ៤ម្ចាស់ចំការក៏ចាត់អ្នកបម្រើម្នាក់ទៀតឲ្យមក ប៉ុន្តែពួកអ្នកថែចំការនាំគ្នាវាយក្បាលអ្នកបម្រើនោះ ហើយជេរស្ដីទៀតផង។ ៥ម្ចាស់ចំការចាត់អ្នកបម្រើម្នាក់ផ្សេងទៀតឲ្យមក។ អ្នកថែចំការបានសម្លាប់អ្នកបម្រើនោះ។ បន្ទាប់មកអ្នកបម្រើផ្សេងទៀតជាច្រើនរូបក៏រងគ្រោះដូច្នោះដែរ ខ្លះត្រូវគេវាយដំ ខ្លះត្រូវគេសម្លាប់។ ៦ម្ចាស់ចំការមានបុត្រដ៏ជាទីស្រឡាញ់តែមួយគត់ គាត់ចាត់បុត្រនោះឲ្យមកក្រោយគេបង្អស់ ដោយយល់ថា ៧"គេមុខជាគោរពកោតខ្លាចកូនប្រុសខ្ញុំមិនខាន"។ ប៉ុន្តែពួកកសិករថែចំការទាំងនោះពិគ្រោះគ្នាថា "អ្នកនេះជាអ្នកទទួលកេរមត៌កពីម្ចាស់ចំការទៅថ្ងៃក្រោយ យើងនាំគ្នាសម្លាប់វាទៅចំការនេះនឹងធ្លាក់មកជាសម្បត្តិរបស់យើង"។ ៨គេក៏ចាប់កូនប្រុសម្ចាស់ចំការ យកមកសម្លាប់ រួចបោះទៅក្រៅចំការទំពាំងបាយជូរ។ ៩តើម្ចាស់ចំការធ្វើយ៉ាងដូចម្ដេច? គាត់មុខជាមកសម្លាប់អ្នកថែរក្សាចំការទាំងនោះមិនខាន រួចប្រគល់ចំការទំពាំងបាយជូរ ទៅឲ្យអ្នកផ្សេងទៀត។ ១០អ្នករាល់គ្នាពិតជាធ្លាប់អានអត្ថបទគម្ពីរដែលមានចែងថា៖

*"ថ្មដែលពួកជាងសង់ផ្ទះបោះចោល*
*បានត្រឡប់មកជាគ្រឹះដ៏សំខាន់បំផុត។*
១១ *ព្រះអម្ចាស់បានសំរេចការអស្ចារ្យនេះ*

*យើងបានឃើញហើយស្ងើចសរសើរផង"ន»។*
១២ពួកមេដឹកនាំសាសន៍យូដាយល់ថា ព្រះអង្គ
មានព្រះបន្ទូលជាពាក្យប្រស្នានេះ សំដៅលើពួកគេ
គេក៏នាំគ្នារកមធ្យោបាយចាប់ព្រះអង្គ ប៉ុន្តែគេខ្លាចប
ណ្ដាជន ដូច្នេះគេក៏ចាកចេញពីព្រះយេស៊ូទៅ។

## អំពីពន្ធដារ

(ម៉ាថាយ២២, ១៥-២២ លូកា២០, ២០-២៦)

១៣គេចាត់ពួកខាងគណៈផារីស៊ី* និងពួកខាង
ស្ដេចហេរ៉ូដខ្លះ ឲ្យទៅជិតព្រះយេស៊ូចាំចាប់កំហុស
នៅពេលព្រះអង្គមានព្រះបន្ទូល។ ១៤គេនាំគ្នាមក
ទូលព្រះអង្គថា៖ «លោកគ្រូ! យើងខ្ញុំដឹងថាលោក
មានប្រសាសន៍សុទ្ធតែពិតទាំងអស់ លោកគ្រូពុំ
យោគយល់ ហើយក៏ពុំរើសមុខនរណាឡើយគឺលោក
គ្រូប្រៀនប្រដៅអំពីរបៀបរស់នៅ ដែលគាប់ព្រះហឫ
ទ័យព្រះជាម្ចាស់ តាមសេចក្ដីពិត។ តើវិន័យ*របស់
យើងអនុញ្ញាតឲ្យបង់ ពន្ធដារថ្វាយព្រះចៅអធិរាជរ៉ូមាំ
ងឬទេ? តើយើងត្រូវបង់ឬមិនត្រូវបង់?»។ ១៥ព្រះ
យេស៊ូឈ្វេងយល់ពុតត្បុតរបស់គេ ទ្រង់មានព្រះ
បន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់
កំហុសខ្ញុំដូច្នេះ? សុំយកប្រាក់មួយកាក់មកឲ្យខ្ញុំមើល
មើល៍»។ ១៦គេក៏យកប្រាក់មួយកាក់មកថ្វាយព្រះ
យេស៊ូ ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើលើ
កាក់នេះ មានរូបនរណាឈ្មោះនរណា?»។ គេឆ្លើយ
ថា៖ «រូបនិងឈ្មោះព្រះចៅអធិរាជ!»។ ១៧ព្រះ
យេស៊ូក៏មានព្រះបន្ទូលទៅគេថា៖ «អ្វីៗដែលជា
របស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញ
ទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅ
ព្រះជាម្ចាស់វិញដែរ»។ គេងឿងឆ្ងល់នឹងព្រះយេស៊ូ
យ៉ាងខ្លាំង។

## អំពីមនុស្សស្លាប់នឹងរស់ឡើងវិញ

(ម៉ាថាយ២២, ២៣-៣៣ លូកា២០, ២៧-៤០)

១៨មានពួកខាងគណៈសាឌូស៊ី* ចូលមកគាល់
ព្រះអង្គ។ ពួកសាឌូស៊ីមិនជឿថាមនុស្សស្លាប់នឹងរស់
ឡើងវិញទេ។ គេទូលសួរព្រះយេស៊ូថា៖ ១៩«លោក
គ្រូ! លោកម៉ូសេ*បានចែងច្បាប់ទុកឲ្យយើងថា "បើ
បុរសណាមានប្រពន្ធ ហើយស្លាប់ចោលប្រពន្ធទៅ
តែគ្មានកូនសោះត្រូវឲ្យប្អូនប្រុសរបស់បុរសនោះរៀប
ការនឹងបងថ្លៃ ដើម្បីបន្តពូជឲ្យបងប្រុសរបស់ខ្លួន"។
២០ឧបមាថាមានបងប្អូនប្រុសៗប្រាំពីរនាក់។ បុរស
បងបង្អស់បានរៀបការ ហើយស្លាប់ទៅតែគ្មានកូន
សោះ។ ២១ប្អូនបន្ទាប់រៀបការនឹងបងថ្លៃមេម៉ាយ រួច
ស្លាប់ទៅទាំងឥតមានកូន រីឯប្អូនទីបីក៏ដូច្នោះដែរ។
២២បងប្អូនទាំងប្រាំពីរនាក់សុទ្ធតែគ្មានកូនដូចគ្នា។
នៅទីបំផុតនាងក៏ស្លាប់ទៅដែរ។ ២៣លុះដល់ពេល
មនុស្សស្លាប់នឹងរស់ឡើងវិញ តើនាងត្រូវបានទៅជា
ប្រពន្ធរបស់អ្នកណាបើប្រាំពីរនាក់សុទ្ធ តែយកនាង
ធ្វើជាប្រពន្ធដូច្នេះ?»។ ២៤ព្រះយេស៊ូមានព្រះបន្ទូល
តបទៅគេថា៖ «អ្នករាល់គ្នាយល់ខុសហើយ ដ្បិតអ្នក
រាល់គ្នាមិនស្គាល់គម្ពីរ ហើយមិនស្គាល់ឫទ្ធានុភាព
របស់ព្រះជាម្ចាស់ផង។ ២៥ពេលមនុស្សស្លាប់មាន
ជីវិតរស់ឡើងវិញ គេមិនរៀបការប្ដីប្រពន្ធទៀតឡើយ
គឺគេនឹងបានដូចទេវទូត*នៅស្ថានបរមសុខ*។ ២៦
លោកម៉ូសេ*បានចែងអំពីមនុស្សស្លាប់ នឹងរស់ឡើង
វិញ នៅក្នុងអត្ថបទស្ដីអំពីគុម្ពបន្លា តើអ្នករាល់គ្នាធ្លាប់
អានឬទេ?។ ព្រះជាម្ចាស់មានព្រះបន្ទូលមកលោក
ថា "យើងជាព្រះរបស់អប្រាហាំជាព្រះរបស់អ៊ីសាក
និងជាព្រះរបស់យ៉ាកុប"។ ២៧ព្រះជាម្ចាស់មិនមែនជា
ព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះរបស់មនុស្សដែល
មានជីវិត។ អ្នករាល់គ្នាយល់ខុសទាំងស្រុងហើយ!»
។

## វិន័យសំខាន់ជាងគេ

(ម៉ាថាយ២២, ៣៤-៤០លូកា១០, ២៥-២៦)

២៨មានធម្មាចារ្យ*ម្នាក់ បានឮពួកគេជជែក

ជាមួយព្រះយេស៊ូ ហើយឃើញថាព្រះអង្គមានព្រះ
បន្ទូលឆ្លើយត្រឹមត្រូវ គាត់ក៏ចូលទៅជិតទូលព្រះអង្គ
ថា៖ «ក្នុងបណ្ដាវិន័យ*ទាំងអស់ តើវិន័យណា
សំខាន់ជាងគេ?»។ ២៩ព្រះយេស៊ូមានព្រះបន្ទូល
ឆ្លើយថា៖ «នេះជាវិន័យទីមួយ៖ "អ៊ីស្រាអែលអើយ
ចូរស្ដាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយ
ព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។ ៣០ត្រូវ
ស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត
គំនិត អស់ពីស្មារតី អស់ពីប្រាជ្ញានិងអស់ពីកម្លាំង
កាយ"។ ៣១រីឯវិន័យទីពីរមានចែងថា "ត្រូវស្រឡាញ់
បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯង"។
គ្មានវិន័យណា សំខាន់ជាងវិន័យទាំងពីរនេះទេ»។
៣២ធម្មាចារ្យនោះទូលព្រះអង្គថា៖ «លោកគ្រូលោក
មានប្រសាសន៍ត្រូវណាស់ ហើយពិតផង។ មានព្រះ
ជាម្ចាស់តែមួយព្រះអង្គគត់ ក្រៅពីព្រះអង្គគ្មានព្រះ
ឯណាទៀតឡើយ។ ៣៣បើយើងស្រឡាញ់ព្រះអង្គ
អស់ពីចិត្តគំនិត អស់ពីបញ្ញា និងអស់ពីកម្លាំងកាយ
ហើយបើយើងស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូច
ស្រឡាញ់ខ្លួនឯងនោះ ប្រសើរជាងថ្វាយតង្វាយដុត
និងថ្វាយយញ្ញបូជាទៅទៀត»។ ៣៤កាលព្រះយេស៊ូ
ឮគាត់ឆ្លើយដោយប្រាជ្ញាវាងវៃដូច្នេះ ព្រះអង្គមានព្រះ
បន្ទូលថា៖ «អ្នកនៅមិនឆ្ងាយពីព្រះរាជ្យរបស់ព្រះជា
ម្ចាស់ទេ»។ បន្ទាប់មកគ្មាននរណាហ៊ានដេញដោល
សួរព្រះអង្គទៀតឡើយ។

## ព្រះគ្រិស្ដជាព្រះ អម្ចាស់លើស្ដេចដាវីឌ

(ម៉ាថាយ ២២, ៤១-៤៦ លូកា ២០, ៤១-៤៤)

៣៥ព្រះយេស៊ូបង្រៀនមនុស្សម្នា នៅក្នុងព្រះ
វិហារ*ដោយមានព្រះបន្ទូលថា៖ «ហេតុដូចម្ដេចបាន
ជាពួកធម្មាចារ្យនិយាយថា ព្រះគ្រិស្ដជាព្រះរាជវង្ស
របស់ព្រះបាទដាវីឌដូច្នេះ?។ ៣៦ព្រះវិញ្ញាណរបស់
ព្រះជាម្ចាស់បានបំភ្លឺព្រះបាទដាវីឌឲ្យមានរាជឱង្ការ
ថា៖

*"ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់*
*ព្រះអម្ចាស់របស់ខ្ញុំថា សូមគង់ខាងស្ដាំយើង*
*ទំរាំដល់យើងបង្ក្រាបខ្មាំងសត្រូវរបស់ព្រះអង្គ*
*មកដាក់ក្រោមព្រះបាទារបស់ព្រះអង្គ"*[ម]។

៣៧បើព្រះបាទដាវីឌផ្ទាល់ ហៅព្រះគ្រិស្ដ*ថា
"ព្រះអម្ចាស់"ដូច្នេះ តើឲ្យព្រះគ្រិស្ដត្រូវជាព្រះរាជវង្ស
របស់ព្រះអង្គដូចម្ដេចកើត?»។

## ព្រះយេស៊ូប្រាប់បណ្ដាជនឲ្យប្រយ័ត្ននឹងពួកធម្មាចារ្យ

(ម៉ាថាយ ២៣, ១-៣៦ លូកា ២០, ៤៥-៤៧)

បណ្ដាជនជាច្រើនចូលចិត្តស្ដាប់ព្រះបន្ទូល
របស់ព្រះយេស៊ូណាស់។ ៣៨ព្រះអង្គមានព្រះបន្ទូល
បង្រៀនគេថា៖ «ចូរប្រយ័ត្ននឹងពួកធម្មាចារ្យ*ឲ្យមែន
ទែន អ្នកទាំងនោះចូលចិត្តពាក់អាវវែង ដើរចុះដើរ
ឡើង ហើយចូលចិត្តឲ្យគេអោនកាយគោរពនៅតាម
ផ្សារ ៣៩ព្រមទាំងរើសកន្លែងអង្គុយមុខគេក្នុងធម្ម
សាលា* និងចូលចិត្តកន្លែងកិត្តិយសនៅពេលជប់
លៀង។ ៤០គេតែងនាំគ្នាឆបោកយកទ្រព្យសម្បត្តិ
របស់ស្ត្រីមេម៉ាយ ដោយធ្វើឫកជាសូត្រធម៌យ៉ាងយូ
រៗ អ្នកទាំងនេះនឹងត្រូវទទួលទោសយ៉ាងធ្ងន់បំផុតជា
មិនខាន»។

## តង្វាយរបស់ស្ត្រីមេម៉ាយ

(លូកា ២១, ១-៤)

៤១ព្រះយេស៊ូគង់នៅមុខហិបតង្វាយ ព្រះអង្គ
ទតមើលរបៀបដែលបណ្ដាជនយកប្រាក់ មកដាក់
ក្នុងហិបនោះ។ អ្នកមានច្រើននាក់ដាក់ប្រាក់ជាច្រើ
ន។ ៤២មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយក
ប្រាក់ពីរសេនជាចំនួនដ៏តិចតួចបំផុត ដាក់ក្នុងហិប
តង្វាយនោះដែរ។ ៤៣ព្រះយេស៊ូត្រាស់ហៅពួកសាវ័
ក*មក ហើយមានព្រះបន្ទូលទៅគេថា៖«ខ្ញុំសុំប្រាប់

ឲ្យអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះ
បានដាក់ប្រាក់ក្នុងហិប ច្រើនជាងគេទាំងអស់ ៤៤
ដ្បិតពួកអ្នកទាំងនោះយកប្រាក់សំណល់របស់ខ្លួនមក
ដាក់។ រីឯស្ត្រីមេម៉ាយនេះវិញទោះបីនាងក្រីក្រយ៉ាង
ណាក៏ដោយ ក៏នាងបានយកប្រាក់ដែលនាងត្រូវការ
ជាចាំបាច់មកដាក់ដែរ គឺប្រាក់ទាំងប៉ុន្មានដែលនាង
មានសម្រាប់ចិញ្ចឹមជីវិត»។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីការបំផ្លាញព្រះវិហារ*

(ម៉ាថាយ ២៤, ១-២ លូកា ២១, ៥-៦)

១៣ ១ពេលព្រះយេស៊ូយាងចេញ ពីព្រះវិហារ*ទៅ
មានសាវ័ក*ម្នាក់ទូលព្រះអង្គថា៖ «ព្រះគ្រូ សូមមើល
ថ្មនុំះស្អាតណាស់! វិមានទាំងនេះល្អវិសេសវិសាល
បំផុត»។ ២ព្រះយេស៊ូមានព្រះបន្ទូល ទៅសាវ័កនោះ
វិញថា៖«ថ្ងៃក្រោយវិមានដ៏ស្កឹមស្កៃ ដែលអ្នកឃើញ
នេះនឹងត្រូវរលំបាក់បែកអស់ លែងមានថ្មត្រួតពីលើថ្ម
ទៀតហើយ»។

## ហេតុការណ៍នៅគ្រាចុងក្រោយ

(ម៉ាថាយ ២៤, ៣-១៤ លូកា ២១, ៧-១៩)

៣ព្រះអង្គគង់នៅលើភ្នំដើមអូលីវ ទល់មុខព្រះ
វិហារ*។ លោកសិលា លោកយ៉ាកុប លោកយ៉ូហាន
និងលោកអន់ទ្រេ ទូលសួរព្រះអង្គដាច់ឡែកពីគេថា៖
៤«សូមព្រះគ្រូប្រាប់ឲ្យយើងខ្ញុំដឹងផង ហេតុ
ការណ៍ទាំងនេះនឹងកើតឡើងនៅពេលណា? តើមាន
អ្វីជាសម្គាល់ ឲ្យយើងខ្ញុំដឹងថាព្រឹត្តិការណ៍ទាំងនេះ
នឹងដល់ទីបញ្ចប់?»។ ៥ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ចូរប្រុងប្រយ័ត្នកុំបណ្ដោយនរណាមក
បញ្ឆោតអ្នករាល់គ្នា ឲ្យវង្វេងបានឡើយ ៦ដ្បិតនឹង
មានមនុស្សជាច្រើនយកឈ្មោះខ្ញុំមកប្រើ ដោយ
ពោលថា"ខ្ញុំនេះហើយជាព្រះគ្រីស្ត*!"។ គេនឹងនាំ
មនុស្សជាច្រើនឲ្យវង្វេង។ ៧កាលណាអ្នករាល់គ្នាឮ
គេនិយាយអំពីសង្គ្រាមនិងឮដំណឹងថា មានសង្គ្រាម
ផ្ទុះឡើងមិនត្រូវជ្រួលច្របល់ឡើយ ដ្បិតហេតុការណ៍
ទាំងនេះត្រូវតែកើតឡើង ប៉ុន្តែមិនទាន់ដល់អវសាន
កាលនៃពិភពលោកនៅឡើយទេ។ ៨ប្រជាជាតិមួយ
នឹងធ្វើសង្គ្រាម តទល់នឹងប្រជាជាតិមួយទៀត
ប្រទេសមួយតទល់នឹងប្រទេសមួយទៀត។ នៅ
កន្លែងខ្លះនឹងមានរញ្ជួយផែនដី ព្រមទាំងមានកើតទុរ្ភិ
ក្សផង។ ហេតុការណ៍ទាំងនេះប្រៀបបាននឹងការឈឺ
ចាប់ដើមដំបូងរបស់ស្ត្រី ដែលហៀបនឹងសំរាលកូន។
៩ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នខ្លួនឲ្យមែនទែនដ្បិតគេនឹង
បញ្ជូនអ្នករាល់គ្នា ទៅកន្លែងកាត់ទោសគេនឹងយក
រំពាត់វាយអ្នករាល់គ្នា នៅក្នុងធម្មសាលា* គេនឹងនាំ
អ្នករាល់គ្នាទៅឲ្យទេសាភិបាល និងឲ្យស្ដេចកាត់
ទោស ព្រោះតែអ្នករាល់គ្នាតាមខ្ញុំ។ ប៉ុន្តែជាឱកាស
សម្រាប់អ្នករាល់គ្នា ផ្ដល់សក្ខីភាពឲ្យគេដឹងឮ។ ១០
ត្រូវប្រកាសដំណឹងល្អ*ឲ្យមនុស្សគ្រប់ជាតិគ្រប់
សាសន៍បានឮជាមុនសិន។ ១១ពេលគេចាប់អ្នករាល់
គ្នាបញ្ជូនទៅកាត់ទោស កុំភ័យបារម្ភជាមុននឹងរក
ពាក្យ ដែលអ្នករាល់គ្នាត្រូវនិយាយនោះឡើយ ត្រូវ
និយាយតាមតែព្រះជាម្ចាស់ប្រទានឲ្យអ្នករាល់គ្នា
និយាយនៅពេលនោះ ដ្បិតមិនមែនអ្នករាល់គ្នាទេ
ដែលនិយាយ គឺព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទេតើ
ដែលនឹងមានព្រះបន្ទូល។ ១២បងប្អូននឹងចាប់បញ្ជូន
គ្នាទៅឲ្យគេសម្លាប់ ឪពុកនឹងចាប់បញ្ជូនកូនទៅឲ្យគេ
សម្លាប់ ហើយកូនៗលើកគ្នាប្រឆាំងនឹងឪពុកម្ដាយ
ព្រមទាំងបញ្ជូនទៅឲ្យគេសម្លាប់ទៀតផង។ ១៣
មនុស្សគ្រប់រូបនឹងស្អប់អ្នករាល់គ្នា ព្រោះតែឈ្មោះ
ខ្ញុំ។ ប៉ុន្តែអ្នកណាស៊ូទ្រាំរហូតដល់ទីបញ្ចប់ ព្រះជា
ម្ចាស់នឹងសង្គ្រោះអ្នកនោះ»។

## គ្រាមានទុក្ខលំបាកវេទនា

(ម៉ាថាយ ២៤, ១៥-២៨ លូកា ២១, ២០-២៤)

១៤«ពេលណាអ្នករាល់គ្នាឃើញជនចង្រៃ ដ៏គួរ
ឲ្យស្អប់ខ្ពើមរ ឈរនៅកន្លែងដែលមិនត្រូវឈរ-សូម
ឲ្យអ្នកអានយល់ពាក្យនេះចុះ- ពេលនោះអស់អ្នក
ដែលរស់ក្នុងស្រុកយូដា ត្រូវនាំគ្នារត់ទៅជ្រកនៅតាម
ភ្នំ។ ១៥រីឯអ្នកនៅលើដំបូលផ្ទះ មិនត្រូវចុះមកយក
របស់អ្វីដែលនៅក្នុងផ្ទះឡើយ ១៦ហើយអ្នកដែលនៅ
ឯចំការ ក៏មិនត្រូវវិលទៅផ្ទះយកអាវធំរបស់ខ្លួនដែរ។
១៧គ្រានោះស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅកូនមុខជា
វេទនាពុំខាន។ ១៨ចូរទូលអង្វរព្រះជាម្ចាស់ សូមកុំឲ្យ
ហេតុការណ៍ទាំងនេះកើតឡើង នៅរដូវត្រជាក់ឡើយ
១៩ដ្បិតពេលនោះជាពេលមានទុក្ខវេទនាយ៉ាងខ្លាំង
តាំងពីដើមកំណើតពិភពលោកមកគឺចាប់ពីពេល
ដែលព្រះជាម្ចាស់បង្កើតអ្វីៗទាំងអស់មកទល់សព្វថ្ងៃ
ហើយទោះជាទៅថ្ងៃមុខទៀតក៏ពុំដែលមានទុក្ខ
លំបាកខ្លាំងយ៉ាងនេះដែរ។ ២០ប្រសិនបើព្រះអម្ចាស់
មិនបន្ថយចំនួនថ្ងៃទាំងនោះទេ មុខជាគ្មាននរណា
ម្នាក់បានរួចជីវិតឡើយ ប៉ុន្តែព្រះអង្គបន្ថយចំនួនថ្ងៃ
ទាំងនោះ ដោយយោគយល់ដល់ពួកអ្នកដែលព្រះ
អង្គបានជ្រើសរើស។ ២១ប្រសិនបើមានគេប្រាប់អ្នក
រាល់គ្នាថា "ព្រះគ្រីស្ត*គង់នៅទីនេះឬនៅទីនោះ "កុំ
ជឿគេឡើយ ២២ដ្បិតនឹងមានមនុស្សក្លែងខ្លួនធ្វើជា
ព្រះគ្រីស្ត ព្រមទាំងមានព្យាការីក្លែងក្លាយនាំគ្នាស
ម្ដែងទីសម្គាល់ដ៏អស្ចារ្យនិងឫទ្ធិបដិហារិយ៍ផ្សេងៗ
ដើម្បីបញ្ឆោតមនុស្ស រហូតដល់ទៅនាំពួកអ្នកដែល
ព្រះអង្គជ្រើសរើស ឲ្យវង្វេងថែមទៀតផង ប្រសិនបើ
គេអាចធ្វើបាន។ ២៣ចូរប្រុងប្រយ័ត្ន ដ្បិតខ្ញុំនិយាយ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងជាមុនសព្វគ្រប់ហើយ»។

## បុត្រមនុស្សនឹងយាងមកវិញ

(ម៉ាថាយ២៤,២៩-៤៤ លូកា២១, ២៥-៣៣)

២៤«លុះទុក្ខលំបាកនេះកន្លងផុតទៅ នៅគ្រា
នោះ ព្រះអាទិត្យនឹងបាត់រស្មីព្រះច័ន្ទលែងមានពន្លឺ
ទៀតហើយ ២៥រីឯផ្កាយទាំងឡាយនឹងធ្លាក់ចុះពីលើ
មេឃ អំណាចនានានៅលើមេឃនឹងត្រូវកក្រើករំពើ
ក។ ២៦ពេលនោះគេនឹងឃើញបុត្រមនុស្ស*យាងមក
ក្នុងពពក ប្រកបដោយឫទ្ធានុភាពដ៏ខ្លាំងក្លានិងដោយ
សិរីរុងរឿង។ ២៧លោកនឹងចាត់ពួកទេវទូត*របស់
លោកឲ្យទៅទិសទាំងបួន ចាប់តាំងពីជើងមេឃម្ខាង
ទៅជើងមេឃម្ខាងទៀត ដើម្បីប្រមូលពួកអ្នកដែល
ព្រះជាម្ចាស់បានជ្រើសរើស»។

២៨«ចូរអ្នករាល់គ្នាយកពាក្យប្រស្នា ស្ដីអំពីដើម
ឧទុម្ពរ*ទៅរិះគិតចុះ។ កាលណាមែករបស់វាមាន
ស្លឹកលាស់ខៀវខ្ចី អ្នករាល់គ្នាដឹងថារដូវប្រាំងជិតមក
ដល់ហើយ។ ២៩ដូច្នេះ កាលណាអ្នករាល់គ្នាឃើញ
ព្រឹត្តិការណ៍ទាំងនោះកើតឡើង ត្រូវដឹងថាបុត្រ
មនុស្ស*ក៏ជិតមកដល់ហើយដែរ គឺលោកមកជិត
បង្កើយហើយ។ ៣០ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ថា ហេតុការណ៍ទាំងនោះនឹងកើតឡើងនៅពេល
ដែលមនុស្សជំនាន់នេះ មានជីវិតនៅឡើយ។ ៣១ផ្ទៃ
មេឃនិងផែនដីនឹងរលាយបាត់ទៅ តែពាក្យដែលខ្ញុំ
និយាយមិនរលាយបាត់ទេ។

៣២រីឯថ្ងៃកំណត់និងពេលវេលា គ្មាននរណាដឹង
ឡើយ ទោះបីទេវទូត*នៅស្ថានបរមសុខ* ឬព្រះ
បុត្រាក៏ពុំជ្រាបដែរ មានតែព្រះបិតាប៉ុណ្ណោះដែលជ្រា
ប។ ៣៣អ្នករាល់គ្នាមិនដឹងថា ពេលណាជាពេល
កំណត់ទេ ដូច្នេះចូរប្រុងប្រយ័ត្ន ប្រុងស្មារតីឲ្យមែន
ទែន ៣៤ដ្បិតពេលកំណត់នោះ ប្រៀបបាននឹងបុរស
ម្នាក់ដែលចេញដំណើរពីផ្ទះទៅ គាត់ទុកឲ្យពួកអ្នក
បម្រើមើលខុសត្រូវក្នុងផ្ទះ ដោយចែកមុខងារឲ្យរៀ
ងៗខ្លួន ព្រមទាំងបង្គាប់ឲ្យអ្នកយាមផ្ទះប្រុងស្មារតីផង
។ ៣៥អ្នករាល់គ្នាក៏ត្រូវប្រុងស្មារតីដូច្នោះដែរ ដ្បិតអ្នក
រាល់គ្នាពុំដឹងថាម្ចាស់ផ្ទះនឹងវិលមកវិញ នៅពេលណា
ឡើយ មិនដឹងជាយប់ពាក់កណ្ដាលអធ្រាត្រ ពេល
មាន់រងាវឬពេលព្រលឹមទេ ៣៦ក្រែងលោកត្រឡប់មក
វិញ ដោយមិនបានឲ្យដំណឹងមុន ហើយឃើញអ្នក
រាល់គ្នាកំពុងតែដេកលក់។ ៣៧ពាក្យដែលខ្ញុំនិយាយ

ប្រាប់អ្នករាល់គ្នានេះ ខ្ញុំក៏ចង់និយាយប្រាប់អ្នកឯទៀ
តៗគ្រប់គ្នាដែរ គឺថា ចូរប្រុងស្មារតី!»។

## ការឃុបឃិតចាប់ព្រះយេស៊ូ

(ម៉ាថាយ ២៦,១-៥ លូកា ២២,១-២ យ៉ូហាន ១១,៤៥-៥៣)

១៤ [១]នៅពីរថ្ងៃមុនបុណ្យចម្លង* និងបុណ្យនំបុ័ងឥត
មេ* ក្រុមនាយកបូជាចារ្យ*និងពួកធម្មាចារ្យ*នាំគ្នារក
មធ្យោបាយ ដើម្បីចាប់ព្រះយេស៊ូ ដោយកលល្បិច
យកទៅធ្វើគុត។ [២]ប៉ុន្តែគេនិយាយគ្នាថា៖ «កុំចាប់
ក្នុងពេលបុណ្យនេះឡើយក្រែងកើតចលាចលក្នុង
ចំណោមប្រជាជន»។

## ស្ត្រីម្នាក់ចាក់ប្រេ ងលើសិរសាព្រះយេស៊ូ

(ម៉ាថាយ ២៦, ៦-១៣ យ៉ូហាន ១២, ១-៨)

[៣]ព្រះយេស៊ូគង់នៅភូមិបេថានី ក្នុងផ្ទះបុរស
ម្នាក់ឈ្មោះស៊ីម៉ូនជាមនុស្សឃ្លង់។ ពេលព្រះអង្គ
កំពុងសោយព្រះស្ងោយ មានស្ត្រីម្នាក់ចូលមកទាំង
កាន់ដបថ្មកែវផង។ នៅក្នុងដបនោះមានប្រេងទេព្វិរូ
សុទ្ធដ៏មានតម្លៃលើសលប់។ នាងបំបែកដបថ្មកែវ
ហើយចាក់ប្រេងក្រអូប លើព្រះសិរសារបស់ព្រះយេ
ស៊ូ។ [៤]មានអ្នកខ្លះនៅទីនោះ ទាស់ចិត្តយ៉ាងខ្លាំងគេ
និយាយគ្នាថា៖ «ម្ដេចក៏ខ្ជះខ្ជាយប្រេងក្រអូបដូច្នេះ! [៥]
បើយកប្រេងនេះទៅលក់ មុខជាបានប្រាក់ជាងបីរយ
ដួង* ហើយចែកទានដល់ជនក្រីក្រវិញ»។ អ្នកទាំង
នោះខឹងនឹងនាងណាស់។ [៦]ព្រះយេស៊ូមានព្រះ
បន្ទូលថា៖ «ទុកឲ្យនាងធ្វើតាមចិត្តនាងទៅ!ហេតុអ្វី
បានជារករឿងនាង! នាងបានធ្វើអំពើដ៏ល្អចំពោះខ្ញុំ។
[៧]អ្នករាល់គ្នាមានអ្នកក្រីក្រនៅជាមួយ រហូតអ្នករាល់
គ្នាអាចធ្វើទានដល់គេ តាមតែចិត្តអ្នករាល់គ្នាចង់ រីឯ
ខ្ញុំវិញ ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ។ [៨]ស្ត្រី
នេះបានធ្វើតាមសមត្ថភាពរបស់នាង គឺនាងលាប
ប្រេងក្រអូបលើរូបកាយខ្ញុំ ទុកជាមុនសម្រាប់យកទៅ
បញ្ចុះក្នុងផ្នូរ។ [៩]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
នៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល កាលណា
គេប្រកាសដំណឹងល្អ* គេក៏នឹងតំណាលអំពីកិច្ចការ
ដែលនាងបានធ្វើនេះដែរ ដើម្បីរំលឹកអំពីនាង។

## យូដាអ៊ីស្ការីយ៉ុតក្បត់ព្រះយេស៊ូ

(ម៉ាថាយ ២៦, ១៤-១៦ លូកា ២២, ៣-៦)

[១០]យូដាអ៊ីស្ការីយ៉ុតជាសាវ័ក*ម្នាក់ ក្នុងក្រុមដប់
ពីររូប បានទៅជួបពួកនាយកបូជាចារ្យ* ដើម្បីគិតគូរ
នាំគេទៅចាប់ព្រះយេស៊ូ។ [១១]កាលអ្នកទាំងនោះស្ដា
ប់ពាក្យយូដានិយាយ គេសប្បាយចិត្តណាស់ ហើយ
សន្យាថានឹងឲ្យប្រាក់គាត់។ យូដាក៏រកឱកាសល្អ
ដើម្បីនាំគេទៅចាប់ព្រះអង្គ។

## ព្រះយេស៊ូធ្វើពិធីបុណ្យចម្លងជាមួយពួកសាវ័ក

(ម៉ាថាយ ២៦,១៧-២៥ លូកា ២២, ៧-១៤; ២១-២៣
យ៉ូហាន ១៣, ២១-៣០)

[១២]នៅថ្ងៃដំបូងនៃពិធីបុណ្យនំបុ័ងឥតមេ* ជាថ្ងៃ
ដែលគេត្រូវសម្លាប់កូនចៀមធ្វើយញ្ញបូជា* សម្រាប់
បុណ្យចម្លង* ពួកសាវ័ក*ទូលសួរព្រះយេស៊ូថា៖ «តើ
ព្រះគ្រូចង់ឲ្យយើងខ្ញុំរៀបចំពិធីជប់លៀងជូនក្នុង
ឱកាសបុណ្យចម្លង* នៅកន្លែងណា?»។ [១៣]ព្រះអង្គ
ចាត់សាវ័ក*ពីររូបឲ្យទៅ ដោយមានព្រះបន្ទូលថា៖ «
ចូរអ្នកទៅទីក្រុង អ្នកនឹងជួបបុរសម្នាក់លីក្អមទឹក។
ចូរដើរតាមគាត់ទៅ [១៤]គាត់ចូលផ្ទះណាអ្នកត្រូវ
និយាយទៅម្ចាស់ផ្ទះនោះថា លោកគ្រូមាន
ប្រសាសន៍ថា "បន្ទប់ដែលខ្ញុំនឹងត្រូវជប់លៀងជាមួយ
ពួកសិស្សក្នុងពេលបុណ្យចម្លង* នៅឯណា?"។ [១៥]
ម្ចាស់ផ្ទះនឹងបង្ហាញបន្ទប់មួយយ៉ាងធំនៅជាន់ខាងលើ
ដែលមានប្រដាប់ប្រដាសព្វគ្រប់រៀបចំជាស្រេច ចូរ
រៀបចំម្ហូបអាហារសម្រាប់យើងនៅក្នុងបន្ទប់នោះ
ចុះ»។ [១៦]សាវ័ក*ទាំងពីរក៏ចេញទៅ លុះដល់ទីក្រុង
គេបានឃើញដូចព្រះយេស៊ូមានព្រះបន្ទូលប្រាប់មែន

គេក៏រៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង។
១៧លុះដល់ល្ងាច ព្រះអង្គយាងមកដល់ជាមួយសាវ័ក
ទាំងដប់ពីររូប។ ១៨នៅពេលព្រះយេស៊ូរួមតុសោយ
ព្រះស្ងោយជាមួយពួកសាវ័ក ព្រះអង្គមានព្រះបន្ទូល
ថា៖ «ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា ក្នុង
ចំណោមអ្នករាល់គ្នាដែលបរិភោគជាមួយខ្ញុំ មានម្នាក់
នឹងនាំគេមកចាប់ខ្ញុំ»។ ១៩ពួកសាវ័កព្រួយចិត្តក្រៃ
លែង គេទូលសួរព្រះអង្គបន្តបន្ទាប់គ្នាថា៖ «តើទូល
បង្គំឬ?»។ ២០ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «គឺ
ម្នាក់ក្នុងចំណោមអ្នកទាំងដប់ពីរ ដែលកំពុងជ្រលក់នំ
ប៉័ងក្នុងចានជាមួយខ្ញុំនេះហើយ។ ២១បុត្រមនុស្ស*
ត្រូវតែស្លាប់ដូចមានចែងទុកក្នុងគម្ពីរអំពីលោកស្រាប់
ហើយ។ ប៉ុន្តែអ្នកដែលនាំគេមកចាប់បុត្រមនុស្ស នឹង
ត្រូវវេទនាជាមិនខាន។ ចំពោះអ្នកនោះ បើមិនបាន
កើតមកទេ ទើបប្រសើរជាង»។

## ពិធីជប់លៀងចុងក្រោយបំផុត

(មថ២៦,២៦-៣០ លក២២, ១៥-២០ ១ករ១១,២៣-២៥)

២២នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ង
មកកាន់ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយ
កាច់ប្រទានឲ្យគេ ទាំងមានព្រះបន្ទូលថា៖ «សុំពិសា
ចុះ នេះជារូបកាយរបស់ខ្ញុំ»។ ២៣បន្ទាប់មក ព្រះអង្គ
យកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទាន
ឲ្យពួកសាវ័ក* ពួកសាវ័កក៏បរិភោគទាំងអស់គ្នា។ ២៤
ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «នេះជាលោហិត
របស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវបង្ហូរ
សម្រាប់មនុស្សទាំងអស់។ ២៥ខ្ញុំសុំប្រាប់ឲ្យអ្នករាល់
គ្នាដឹងច្បាស់ថា ខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរ
ទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំង
បាយជូរថ្មី នៅក្នុងព្រះរាជ្យព្រះជាម្ចាស់»។ ២៦
ក្រោយពីបានច្រៀងទំនុកតម្កើង រួចហើយ ព្រះយេស៊ូ
យាងឆ្ពោះទៅភ្នំដើមអូលីវជាមួយពួកសាវ័ក។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីលោកសិលា បដិសេធមិនទទួលស្គាល់ព្រះអង្គ

(មថ២៦,៣១-៣៥ លក២២,៣១-៣៤ យហ១៣,៣៦-៣៨)

២៧ព្រះយេស៊ូមានព្រះបន្ទូល ទៅពួកសាវ័ក*ថា
៖ «អ្នកទាំងអស់គ្នានឹងបោះបង់ខ្ញុំចោល ដ្បិតមាន
ចែងទុកមកថា "យើងនឹងវាយសម្លាប់គង្វាល ហើយ
ចៀមនឹងត្រូវខ្ចាត់ខ្ចាយ"។ ២៨ក៏ប៉ុន្តែក្រោយពេលខ្ញុំ
មានជីវិតរស់ឡើងវិញ ខ្ញុំនឹងទៅស្រុកកាលីឡេមុន
អ្នករាល់គ្នា»។ ២៩លោកសិលាទូលព្រះអង្គថា៖ «
ទោះបីអ្នកឯទៀតៗបោះបង់ព្រះអង្គចោលក៏ដោយ ក៏
ទូលបង្គំមិនបោះបង់ចោលព្រះអង្គជាដាច់ខាត»។
៣០ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសុំប្រាប់
ឲ្យអ្នកដឹងច្បាស់ថា នៅយប់នេះឯង មុនមាន់រងាវពីរ
ដង អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ»។ ៣១
ប៉ុន្តែលោកសិលាប្រកែក រឹតតែខ្លាំងឡើងថា៖ «
ទោះបីទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏
ទូលបង្គំមិនបដិសេធថាមិនស្គាល់ព្រះអង្គជាដាច់
ខាត»។ សាវ័កឯទៀតៗក៏ទូលព្រះអង្គដូចលោក
សិលាដែរ។

## ព្រះយេស៊ូអធិស្ឋាននៅក្នុងសួនកេតសេម៉ានី

(ម៉ាថាយ២៦, ៣៦-៤៦ លូកា២២, ៣៩-៤៦)

៣២ព្រះអង្គយាងទៅដល់កន្លែងមួយ ឈ្មោះកេត
សេម៉ានីជាមួយពួកសាវ័ក*។ ព្រះអង្គមានព្រះបន្ទូល
ថា៖ «ចូរអ្នករាល់គ្នាអង្គុយនៅទីនេះ ហើយ ចាំខ្ញុំ
អធិស្ឋាន*សិន»។

៣៣ព្រះអង្គនាំលោកសិលា លោកយ៉ាកុប និង
លោកយ៉ូហានទៅជាមួយ។ ពេលនោះ ព្រះអង្គចាប់
ផ្ដើមភ័យតក់ស្លុត ព្រមទាំងចុកចាប់អន្ទះសាពន់ប្រមា
ណ។ ៣៤ព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា
៖ «ខ្ញុំព្រួយចិត្តយ៉ាងខ្លាំង ស្ទើរតែស្លាប់ អ្នករាល់គ្នា

នៅទីនេះសិនហើយ ចូរប្រុងស្មារតី»។
៣៥ព្រះអង្គយាងទៅមុខបន្តិច ក្រាបចុះដល់ដី
ទូលអង្វរសូមឲ្យទុក្ខលំបាកនេះ[គ] ចេញឆ្ងាយពីព្រះ
អង្គទៅ បើសិនជាអាចកន្លងផុតទៅបាន។ ៣៦ព្រះអង្គ
ទូលថា៖ «អ័ប្បា ឱព្រះបិតាអើយ! ព្រះអង្គអាចសំរេ
ចគ្រប់កិច្ចការទាំងអស់បាន សូមដកយកពែងនៃទុក្ខ
លំបាកនេះ ចេញឲ្យឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែសូមកុំ
តាមបំណងចិត្តទូលបង្គំឡើយ គឺសូមឲ្យបានសម្រេច
តាមព្រះហឫទ័យព្រះអង្គវិញ»។ ៣៧ព្រះអង្គយាងទៅ
រកពួកសាវ័ក ឃើញគេកំពុងតែដេកលក់ ព្រះអង្គមាន
ព្រះបន្ទូលទៅលោកសិលាថា៖ «ស៊ីម៉ូនអើយ ម្ដេចក៏
អ្នកដេកលក់ដូច្នេះ? អ្នកនៅស៊ូទ្រាំប្រុងស្មារតី សូម្បី
តែមួយម៉ោងក៏មិនបានដែរឬ? ៣៨ចូរប្រុងស្មារតី
ហើយអធិស្ឋាន កុំឲ្យចាញ់ការល្បួង វិញ្ញាណរបស់
មនុស្សប្រុងប្រៀបជាស្រេចមែន ប៉ុន្តែខ្លួនគេនៅ
ខ្សោយទេ!»។
៣៩ព្រះអង្គយាងចេញ ទៅឆ្ងាយពីគេសាជាថ្មី
ហើយទូលអង្វរដោយប្រើពាក្យដដែល។ ៤០ព្រះអង្គ
វិលត្រឡប់មករកពួកសាវ័កម្ដងទៀត ឃើញគេដេក
លក់ ដ្បិតគេងងុយពេក បើកភ្នែកមិនរួច មិនដឹងទូល
ព្រះអង្គដូចម្ដេច។ ៤១ព្រះយេស៊ូវិលមករកគេ ជាលើក
ទីបី មានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នានៅតែ
ដេកលក់ អ្នករាល់គ្នាសម្រាកដល់អង្កាល់ទៀត?
ប៉ុណ្ណឹងល្មមហើយ! ឥឡូវនេះ ពេលកំណត់មកដល់
ហើយ បុត្រមនុស្សត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃ
របស់មនុស្សបាប។ ៤២ចូរក្រោកឡើង យើងនាំគ្នាទៅ
ដ្បិតអ្នកដែលនាំគេមកចាប់ខ្ញុំ ជិតមកដល់ហើយ!»។

## គេចាប់ព្រះយេស៊ូ

(ម៉ាថាយ២៦, ៤៧-៥៦ លូកា២២, ៤៧-៥៣
យ៉ូហាន១៨, ៣-១២)

៤៣ព្រះអង្គកំពុងតែ មានព្រះបន្ទូលនៅឡើយ
ស្រាប់តែយូដាជាសាវ័កម្នាក់ ក្នុងចំណោមសាវ័កទាំង
ដប់ពីររូបមកដល់ ដោយមានបណ្ដាជនមួយក្រុម
កាន់ដាវ កាន់ដំបង មកជាមួយផង។ ពួកនាយកបូជា
ចារ្យ* ពួកធម្មាចារ្យ*និងពួកព្រឹទ្ធាចារ្យ* បានចាត់អ្នក
ទាំងនោះឲ្យមក។ ៤៤យូដាដែលនាំគេមកចាប់ព្រះ
យេស៊ូ បានសន្មតជាមួយអ្នកទាំងនោះនូវសញ្ញាមួយ
ថា៖ «ខ្ញុំថើបអ្នកណា គឺអ្នកនោះហើយ សុំចាប់គាត់
នាំយកទៅ ដោយប្រយ័ត្នប្រយែងឲ្យមែនទែន»។ ៤៥
កាលមកដល់ភ្លាមយូដាដើរតម្រង់មករកព្រះយេស៊ូ
ពោលថា៖ «លោកគ្រូ!» រួចគាត់ថើបព្រះអង្គ ៤៦ពួក
គេនាំគ្នាចាប់ព្រះយេស៊ូ។ ៤៧មានម្នាក់ដែលនៅទី
នោះ ហូតដាវកាប់អ្នកបម្រើរបស់មហាបូជាចារ្យដាច់
ស្លឹកត្រចៀកម្ខាង។ ៤៨ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ខ្ញុំជាចោរប្លន់ឬបានជាអស់លោកកាន់ដាវ
កាន់ដំបង មកចាប់ខ្ញុំដូច្នេះ?។ ៤៩ជារៀងរាល់ថ្ងៃ ខ្ញុំ
នៅក្នុងព្រះវិហារ* ជាមួយអស់លោក ទាំងបង្រៀន
ផង តែអស់លោកពុំបានចាប់ខ្ញុំទេ។ ការណ៍ទាំងនេះ
កើតឡើង ដើម្បីឲ្យបានស្របតាមសេចក្ដីដែលមាន
ចែងទុកក្នុងគម្ពីរ»។ ៥០ពេលនោះ ពួកសាវ័កបោះ
បង់ព្រះយេស៊ូចោល ហើយរត់បាត់អស់ទៅ។
៥១មានកំឡោះម្នាក់ ដែលបានទៅតាមព្រះអង្គ
មានតែសំពត់មួយផ្ទាំង បិទបាំងកាយប៉ុណ្ណោះ គេ
បានចាប់គាត់ដែរ ៥២តែគាត់ចោលសំពត់រត់ទៅខ្លួនទ
ទេ។

## ព្រះយេស៊ូនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់

(ម៉ាថាយ២៦, ៥៧-៦៨ លូកា២២, ៥៤-៥៥, ៦៣-៧១យ៉ូ
ហាន១៨, ១៣-១៤, ១៩-២)

៥៣គេបណ្ដើរព្រះយេស៊ូ នាំយកទៅដល់
ដំណាក់របស់លោកមហាបូជាចារ្យ*។ ពួកនាយក
បូជាចារ្យ ពួកព្រឹទ្ធាចារ្យ* និងពួកធម្មាចារ្យ* មកជួបជុំ
ទាំងអស់គ្នានៅទីនោះ។ ៥៤លោកសិលាដើរតាមព្រះ
អង្គពីចម្ងាយ រហូតដល់ខាងក្នុងទីធ្លាដំណាក់មហា
បូជាចារ្យ ហើយអង្គុយអាំងភ្លើងជាមួយកងរក្សាព្រះ

វិហារ*។ ៥៥ពួកនាយកបូជាចារ្យ និងក្រុមប្រឹក្សាជាន់
ខ្ពស់*ទាំងមូល នាំគ្នារកពាក្យចោទប្រកាន់ព្រះយេស៊ូ
ដើម្បីកាត់ទោសប្រហារជីវិតព្រះអង្គ តែរកមិនបាន
សោះ។ ៥៦មនុស្សជាច្រើនបានប្រឌិតរឿងក្លែងក្លាយ
ចោទប្រកាន់ព្រះអង្គ ប៉ុន្តែពាក្យចោទទាំងនោះមិន
ស្របគ្នាឡើយ។ ៥៧មានអ្នកខ្លះក្រោកឈរឡើង
ពោលរឿងក្លែងក្លាយ ចោទប្រកាន់ព្រះអង្គថា៖ ៥៨«
យើងបានឮអ្នកនេះពោលថា "ខ្ញុំនឹងរុះព្រះវិហារដែល
សង់ឡើងដោយដៃមនុស្សចោល ហើយក្នុងរវាងបីថ្ងៃ
ខ្ញុំនឹងសង់ព្រះវិហារមួយផ្សេងទៀតដែលមិនមែនសង់
ដោយដៃមនុស្សទេ"»។ ៥៩ប៉ុន្តែ ទោះបីក្នុងរឿងនេះ
ក៏ដោយ ក៏ពាក្យរបស់គេនៅតែពុំស្របគ្នាដដែល។
៦០ពេលនោះលោកមហាបូជាចារ្យក្រោកឈរឡើង
នៅមុខក្រុមប្រឹក្សាជាន់ខ្ពស់សួរព្រះយេស៊ូថា៖ «ម្ដេច
ក៏អ្នកមិនឆ្លើយនឹងពាក្យចោទប្រកាន់របស់លោកទាំង
នេះ?» ៦១ព្រះយេស៊ូនៅស្ងៀម ពុំឆ្លើយតបទាល់តែ
សោះ។ លោកមហាបូជាចារ្យ សួរព្រះអង្គម្ដងទៀត
ថា៖ «តើអ្នកពិតជាព្រះគ្រិស្ត ជាព្រះបុត្រារបស់ព្រះ
ដែលយើងសរសើរតម្កើងមែនឬ?»។ ៦២ព្រះយេស៊ូ
មានព្រះបន្ទូលឆ្លើយថា៖ «មែន គឺខ្ញុំហ្នឹងហើយ។
អស់លោកនឹងឃើញបុត្រមនុស្ស* គង់នៅខាងស្ដាំ
ព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមកជាមួយ
ពពក* នៅលើមេឃ»[ង]។ ៦៣លោកមហាបូជាចារ្យ
ឮដូច្នេះ ក៏ហែកអាវរបស់លោក ហើយមាន
ប្រសាសន៍ថា៖ «យើងមិនបាច់រកសាក្សីឯណាទៀត
ទេ ៦៤អស់លោកឮជននេះពោលពាក្យប្រមាថព្រះជា
ម្ចាស់ស្រាប់ហើយ តើអស់លោកគិតដូចម្ដេច?»។
គេបានសំរេចចិត្តទាំងអស់គ្នាកាត់ទោសប្រហារជីវិត
ព្រះយេស៊ូ។ ៦៥អ្នកខ្លះនាំគ្នាស្ដោះទឹកមាត់ដាក់ព្រះ
អង្គ គេគ្របព្រះភ័ក្ត្រព្រះអង្គ វាយតប់ព្រះអង្គ ហើយ
សួរថា៖ «ទាយមើល៍!»។ កងរក្សាព្រះវិហារយកព្រះ
យេស៊ូមកទះកំផ្លៀង។

## លោកសិលាបដិសេធថាមិនស្គាល់ព្រះយេស៊ូ

(ម៉ាថាយ២៦, ៦៩-៧៥ លូកា២២, ៥៦-៦២យ៉ូហាន១៨, ១៥-១៨, ២៥-២៧)

៦៦ពេលលោកសិលានៅក្នុងទីធ្លា មានស្ត្រីបម្រើ
ម្នាក់របស់លោកមហាបូជាចារ្យមកដល់។ ៦៧នាង
ឃើញលោកសិលាកំពុងអាំងភ្លើង ក៏សំឡឹងមើលមុខ
គាត់ឲ្យបានច្បាស់ រួចពោលថា៖ «អ្នកឯងក៏ជាបក្ស
ពួករបស់យេស៊ូ ជាអ្នកភូមិណាសារ៉ែតដែរ!»។ ៦៨
ប៉ុន្តែលោកប្រកែកឡើងថា៖ «ខ្ញុំមិនដឹងទេ ខ្ញុំមិន
យល់ថា នាងចង់និយាយអំពីរឿងអ្វីឡើយ»។ លោក
សិលាក៏ចេញពីទីនោះ ឆ្ពោះទៅខ្លោងទ្វារខាងក្រៅ
ពេលនោះមាន់រងាវឡើង។ ៦៩ស្ត្រីបម្រើឃើញលោក
សិលា ក៏ប្រាប់អស់អ្នកដែលនៅទីនោះម្ដងទៀតថា៖
«អ្នកនេះជាបក្សពួកគេដែរ»។ ៧០លោកសិលា
ប្រកែកសាជាថ្មី។ បន្តិចក្រោយមកអស់អ្នកដែលនៅ
ទីនោះ និយាយទៅលោកសិលាទៀតថា៖ «អ្នកឯង
ប្រាកដជាបក្សពួកអ្នកទាំងនោះមែន ព្រោះអ្នកឯងជា
អ្នកស្រុកកាលីឡេដូចគ្នា»។ ៧១លោកសិលាក៏
និយាយឡើងថា៖ «បើខ្ញុំកុហក សូមឲ្យព្រះជាម្ចាស់
ដាក់ទោសខ្ញុំចុះ ខ្ញុំសុំស្បថថា ខ្ញុំមិនដែលស្គាល់អ្នក
នោះទាល់តែសោះ»។
៧២ភ្លាមនោះមាន់រងាវឡើងជាលើកទីពីរ លោក
សិលាក៏នឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ ដែល
ថា "មុនមាន់រងាវពីរដង អ្នកនឹងបដិសេធបីដងថាមិន
ស្គាល់ខ្ញុំ" គាត់ក៏ទ្រហោយំ។

## ព្រះយេស៊ូនៅមុខលោកពីឡាត

(ម៉ាថាយ២៧,១-២,១១-១៤ លូកា២៣,១-៥ យ៉ូហាន១៨,២៨-៣៨)

១៥១លុះព្រលឹមឡើង ពួកនាយកបូជាចារ្យ*ប្រជុំគ្នា
ជាមួយពួកព្រឹទ្ធាចារ្យ* ពួកធម្មាចារ្យ* និងក្រុមប្រឹក្សា

ជាន់ខ្ពស់*ទាំងមូល។ គេបានចងព្រះយេស៊ូ ហើយ
បញ្ជូនព្រះអង្គទៅលោកពីឡាត។ ២លោកពីឡាតសួរ
ព្រះអង្គថា៖ «តើអ្នកជាស្តេចយូដាមែនឬ?»។ ព្រះ
យេស៊ូមានព្រះបន្ទូលតបថា៖ «លោកទេតើ ដែល
មានប្រសាសន៍ដូច្នេះ!»។ ៣ពួកនាយកបូជាចារ្យបាន
យករឿងជាច្រើន មកចោទប្រកាន់ព្រះយេស៊ូ។ ៤
លោកពីឡាតសួរព្រះអង្គម្តងទៀតថា៖ «ហេតុដូច
ម្តេចបានជា អ្នកមិនឆ្លើយអ្វីសោះដូច្នេះ? អ្នកមិនឮ
ពាក្យទាំងប៉ុន្មាន ដែលគេចោទប្រកាន់អ្នកទេឬ?»។
៥ព្រះយេស៊ូពុំបានឆ្លើយតបទៀតឡើយ ជាហេតុនាំ
ឲ្យលោកពីឡាតងឿងឆ្ងល់ជាខ្លាំង។

## លោកពីឡាតកាត់ទោសប្រហារជីវិតព្រះយេស៊ូ

(ម៉ាថាយ២៧,១៥-២៦ លូកា២៣,១៣-២៥
យ៉ូហាន១៨,៣៩-១៩,១៦)

៦ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង លោក
ពីឡាតតែងលែងអ្នកទោសម្នាក់ តាមពាក្យសុំរបស់ប
ណ្តាជន។ ៧មានបុរសម្នាក់ឈ្មោះបារ៉ាបាសជាប់ឃុំ
ឃាំងជាមួយពួកបះបោរ ដែលសម្លាប់មនុស្សម្នាក់នៅ
ពេលកើតចលាចល។ ៨បណ្តាជននាំគ្នាឡើងទៅជួប
លោកពីឡាត សុំឲ្យលោកដោះលែងអ្នកទោសម្នាក់
តាមទម្លាប់ដែលលោកធ្លាប់អនុគ្រោះដល់គេ។ ៩
លោកពីឡាតមានប្រសាសន៍សួរថា៖ «តើអ្នករាល់
គ្នាចង់ឲ្យ ខ្ញុំដោះលែងស្តេចយូដាឬ?»។ ១០លោក
មានប្រសាសន៍ដូច្នេះ មកពីលោកជ្រាបថាពួក
នាយកបូជាចារ្យបញ្ជូនព្រះយេស៊ូ មកលោក ព្រោះ
ពួកគេមានចិត្តច្រណែន។

១១ពួកនាយកបូជាចារ្យ* នាំគ្នាបញ្ចុះបញ្ចូលប
ណ្តាជន សុំឲ្យលោកពីឡាតដោះលែងបារ៉ាបាសវិ
ញ។ ១២លោកពីឡាតមានប្រសាសន៍ទៅគេម្តងទៀត
ថា៖ «បើដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំធ្វើអ្វីដល់អ្នក
ដែលអ្នករាល់គ្នាហៅថា ស្តេចយូដានេះ?»។ ១៣គេ
ស្រែកឡើងថា៖ «ឆ្កាងទៅ!»។ ១៤លោកពីឡាតសួរ
ថា៖ «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី?»។
ប៉ុន្តែ គេនាំគ្នាស្រែកកាន់តែខ្លាំងឡើងៗថា៖ «ឆ្កាង
ទៅ!»។ ១៥លោកពីឡាតចង់បំពេញចិត្តបណ្តាជនក៏
ដោះលែងបារ៉ាបាស។ បន្ទាប់ពីបញ្ជាឲ្យគេវាយព្រះ
យេស៊ូ នឹងរំពាត់ រួចហើយលោកប្រគល់ទៅឲ្យគេឆ្កា
ង។

## ទាហានមើលងាយ និង ធ្វើបាបព្រះយេស៊ូ

(ម៉ាថាយ២៧, ២៧-៣១ យ៉ូហាន១៩, ២-៣)

១៦ពួកទាហានបណ្តើរព្រះយេស៊ូ ទៅក្នុងទីធ្លា
បន្ទាយ ហើយហៅកងទាហានទាំងមូលមក។ ១៧គេ
យកអាវពណ៌ក្រហមទុំមកពាក់ឲ្យព្រះអង្គ រួចយក
បន្លាមកក្រងធ្វើភួងបំពាក់ជាមកុដលើព្រះសិរសាព្រះ
អង្គ។ ១៨គេក៏នាំគ្នាសំពះព្រះអង្គទាំងពោលថា៖ «
សូមគោរពថ្វាយបង្គំស្តេចយូដា!»។ ១៩គេយកផ្តៅ
វាយព្រះសិរសាព្រះអង្គ គេស្តោះទឹកមាត់ដាក់ព្រះអង្គ
ព្រមទាំងលុតជង្គង់ថ្វាយបង្គំព្រះអង្គថែមទៀតផង។
២០ក្រោយពីបានប្រមាថមើលងាយព្រះអង្គ រួចហើយ
ពួកគេដោះអាវពណ៌ក្រហមចេញយកព្រះពស្ត្ររបស់
ព្រះអង្គ មកពាក់ថ្វាយព្រះអង្គវិញ ហើយបណ្តើរយក
ទៅឆ្កាង។

## គេឆ្កាងព្រះយេស៊ូ

(មថ២៧,៣២-៤៤លក២៣,២៦-៤៣យហ១៩,១៧-២៧)

២១ពេលនោះ មានបុរសម្នាក់ជាអ្នកស្រុកគីរ៉ែន
ត្រឡប់មកពីចំការ គេចាប់បង្ខំគាត់ឲ្យលីឈើឆ្កាង
របស់ព្រះយេស៊ូ។ អ្នកនោះឈ្មោះស៊ីម៉ូនជាឪពុក
របស់អឡិចសង់ និងរូភូស។ ២២គេបណ្តើរព្រះយេស៊ូ
មកដល់កន្លែងមួយឈ្មោះ"កុលកូថា" ដែលប្រែថា "ភ្នំ
លលាដ៍ក្បាល"។ ២៣គេយកស្រាទំពាំងបាយជូរ
លាយជាមួយគ្រឿងញាណម៉្យាង មកថ្វាយព្រះអង្គ

សោយ ប៉ុន្តែព្រះអង្គពុំបានសោយទេ។ ២៤គេក៏ឆ្កាង
ព្រះអង្គ ហើយយកសម្លៀកបំពាក់របស់ព្រះអង្គមក
ចាប់ឆ្នោតចែកគ្នា។ ២៥គេឆ្កាងព្រះអង្គនៅម៉ោង
ប្រាំបួនព្រឹក។ ២៦គេសរសេរប្រកាសអំពីហេតុដែល
គេធ្វើទោសព្រះអង្គថា «ស្ដេចជនជាតិយូដា»។ ២៧
គេក៏បានឆ្កាងចោរព្រៃពីរនាក់ជាមួយព្រះយេស៊ូដែរ
ម្នាក់នៅខាងស្ដាំព្រះអង្គ ម្នាក់ទៀតនៅខាងឆ្វេងព្រះ
អង្គ។ ២៨ហេតុការណ៍នេះកើតឡើងស្របតាមសេចក្ដី
ដែលមានចែងទុកក្នុងគម្ពីរថា «ព្រះអង្គត្រូវគេរាប់
បញ្ចូលជាមួយមនុស្សអាក្រក់»[ច]។ {២៩មនុស្សម្នាដើរ
កាត់តាមនោះ ប្រមាថមើលងាយព្រះអង្គ ទាំងគ្រវី
ក្បាលដាក់ព្រះអង្គ និងពោលថា៖ «នែ៎អ្នករុះព្រះ
វិហារ* ហើយសង់ឡើងវិញតែបីថ្ងៃអើយ ៣០សង្គ្រោះ
ខ្លួនឯងទៅអញ្ជើញចុះពីឈើឆ្កាងមក!»។៣១រីឯពួក
នាយកបូជាចារ្យ និងធម្មាចារ្យ*ក៏និយាយគ្នាចំអកឲ្យ
ព្រះអង្គដូចគេដែរ ពួកគេពោលថា៖ «គាត់បានស
ង្គ្រោះអ្នកឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯងបាន
ទេ!។ ៣២សូមព្រះគ្រីស្ដជាស្ដេចអ៊ីស្រាអែលអញ្ជើញ
ចុះពីឈើឆ្កាងឥឡូវនេះមក ដើម្បីឲ្យយើងឃើញនិង
ជឿផង!»។ អ្នកដែលជាប់ឆ្កាងជាមួយព្រះយេស៊ូ ក៏
ជេរប្រមាថព្រះអង្គដែរ។

## ព្រះយេស៊ូសោយទិវង្គត

(មថ២៧,៤៥-៥៦ លក២៣,៤៤-៤៩ យហ១៩,២៨-៣០)

៣៣នៅពេលថ្ងៃត្រង់ ស្រាប់តែផែនដីទាំងមូល
ងងឹតសូន្យ រហូតដល់ម៉ោងបីរសៀល។ ៣៤នៅវេលា
ម៉ោងបីរសៀល ព្រះយេស៊ូស្រែកអង្វរខ្លាំងៗថា៖ «
អេឡូយ អេឡូយ ឡាម៉ាសាបាច់ថានី?» ពាក្យនេះ
ប្រែថា «ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយហេតុ
អ្វីបានជា ព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?»។
៣៥អ្នកខ្លះឈរនៅទីនោះបានឮព្រះបន្ទូលរបស់ព្រះ
អង្គ ក៏ពោលថា៖ «ឃើញទេ! គាត់ហៅលោកអេ
លី!»។ ៣៦មានម្នាក់រត់ទៅយកសារាយស្ងួតជ្រលក់
ទឹកខ្មេះជោក រុំជាប់នៅចុងត្រែងមួយដើមហុចថ្វាយ
ព្រះអង្គសោយទាំងពោលថា៖ «ចាំមើលមើល៍ តើ
លោកអេលីមកយកគាត់ចុះពីឈើឆ្កាងឬទេ?»។
៣៧រីឯព្រះយេស៊ូវិញ ទ្រង់បន្លឺព្រះសូរសៀង
យ៉ាងខ្លាំង រួចរលត់វិញ្ញាណទៅ ៣៨វាំងននៅក្នុងព្រះ
វិហារ*រហែកជាពីរ តាំងពីលើរហូតដល់ក្រោម។៣៩
នាយទាហានរ៉ូម៉ាំង ដែលឈរនៅខាងមុខព្រះយេស៊ូ
ឃើញព្រះអង្គរលត់វិញ្ញាណរបៀបនេះក៏ពោលឡើង
ថា៖ «បុរសនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់
មែន!»។

៤០មានស្ត្រីៗខ្លះទៀត មើលពីចម្ងាយក្នុង
ចំណោមស្ត្រីទាំងនោះ មាននាងម៉ារីជាអ្នកស្រុកម៉ាដា
ឡានាងម៉ារីជាម្ដាយរបស់យ៉ាកុបតូច និងយ៉ូសេ ព្រម
ទាំងនាងសាឡូមេផង។ ៤១ស្ត្រីទាំងនោះមកជាមួយ
ហើយបម្រើព្រះអង្គតាំងពីព្រះអង្គនៅស្រុកកាលីឡេ
ម៉្លេះ។ មានស្ត្រីឯទៀតៗជាច្រើនបានឡើងមកក្រុង
យេរូសាឡឹមជាមួយព្រះអង្គដែរ។

## ការបញ្ចុះព្រះសពព្រះយេស៊ូ

(មថ២៧, ៥៧-៦១ លក២៣,៥០-៥៦ យហ១៩,៣៨-៤២)

៤២ថ្ងៃនោះ ជាថ្ងៃដែលគេរៀបចំបុណ្យចម្លង* គឺ
មួយថ្ងៃមុនថ្ងៃសប្ប័ទ*។ លុះដល់ល្ងាច ៤៣លោកយ៉ូ
សែប ជាអ្នកស្រុកអារីម៉ាថេ មកដល់លោកជា
សមាជិក ដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងក្រុមប្រឹក្សាជាន់
ខ្ពស់* ហើយលោកក៏រង់ចាំព្រះរាជ្យ*របស់ព្រះជា
ម្ចាស់ដែរ។ លោកមានចិត្តក្លាហានហ៊ានទៅជួប
លោកពីឡាត សុំយកព្រះសពព្រះយេស៊ូ។ ៤៤លោក
ពីឡាតនឹកឆ្ងល់ណាស់ ដោយឮថាព្រះយេស៊ូសោយ
ទិវង្គតយ៉ាងឆាប់ដូច្នេះ។ លោកហៅនាយទាហានមក
សួរឲ្យដឹងថាព្រះយេស៊ូសោយទិវង្គតយូរហើយឬ។
៤៥បន្ទាប់ពីបានទទួលសេចក្ដីរាយការណ៍ពីនាយ
ទាហាន រួចហើយលោកក៏អនុញ្ញាតឲ្យគេប្រគល់ព្រះ

សពទៅលោកយ៉ូសែប។
៤៦លោកយ៉ូសែបទិញក្រណាត់ជាឌឹប លោក
យកព្រះសពព្រះយេស៊ូ ចុះពីឈើឆ្កាង ហើយរុំនឹងក្រ
ណាត់រួចដាក់ក្នុងរូងថ្មមួយដែលគេដាប់ធ្វើជាផ្នូរ។
បន្ទាប់មក លោកប្រមៀលថ្មមួយដុំបិទមាត់ផ្នូរ។ ៤៧
នាងម៉ារីជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីជាម្ដាយយ៉ូ
សេ នាំគ្នាមើលកន្លែងដែលគេបញ្ចុះព្រះសពព្រះអ
ង្គ។

## ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

(ម៉ាថាយ២៨,១-៨ លូកា២៤,១-១២ យ៉ូហាន២០,១-១០)

១៦ ១លុះផុតថ្ងៃសប្ប័ទ*ហើយ នាងម៉ារីជាអ្នក
ស្រុកម៉ាដាឡា នាងម៉ារីជាម្ដាយយ៉ាកុប និងនាងសា
ឡូមេបានទិញគ្រឿងក្រអូប យកទៅអប់ព្រះសពព្រះ
យេស៊ូ។ ២ព្រលឹមឡើងថ្ងៃអាទិត្យនាងនាំគ្នាធ្វើ
ដំណើរ ទៅកាន់ផ្នូរនៅពេលថ្ងៃរះ។ ៣ពួកនាង
និយាយគ្នាថា៖ «តើបាននរណាជួយប្រមៀលថ្ម
ចេញពីមាត់ផ្នូរឲ្យយើង?»។ ៤ពេលស្ត្រីទាំងនោះ
ងើបមុខឡើង ក៏ឃើញថ្មបានរមៀលចេញរួចស្រេច
ទៅហើយ ថ្មនោះមានទំហំធំណាស់។ ៥នាងចូលទៅ
ក្នុងផ្នូរ ឃើញកំឡោះម្នាក់អង្គុយខាងស្ដាំ មានសម្លៀ
កបំពាក់ពណ៌ស ពួកនាងភ័យស្រឡាំងកាំង។ ៦អ្នក
នោះពោលមកកាន់នាងថា៖ «កុំភ័យស្រឡាំងកាំង
ធ្វើអ្វី! នាងនាំគ្នាមករកព្រះយេស៊ូ ជាអ្នកភូមិណាសា
រ៉ែតដែលគេបានឆ្កាង ព្រះជាម្ចាស់បានប្រោសព្រះ
អង្គឲ្យមានព្រះជន្ម រស់ឡើងវិញហើយទ្រង់មិននៅទី
នេះទេ មើលចុះទីនេះហើយដែលគេបានដាក់ព្រះ
សពព្រះអង្គ។ ៧ចូរនាងទៅប្រាប់សាវ័ករបស់ព្រះអង្គ
ព្រមទាំងលោកសិលាផងថា "ព្រះអង្គយាងទៅស្រុក
កាលីឡេមុនអ្នករាល់គ្នា។ នៅទីនោះអ្នករាល់គ្នានឹង
ឃើញព្រះអង្គ ដូចទ្រង់មានព្រះបន្ទូលទុកស្រាប់"»។
៨ស្ត្រីទាំងនោះក៏ចាកចេញពីផ្នូរ ហើយរត់ទៅទាំងញ័រ
រន្ធត់ ស្លុតស្មារតី។ នាងពុំបាននិយាយរឿងនេះប្រាប់
អ្នកណាសោះ ព្រោះនាងភ័យខ្លាំងពេក។

## ព្រះយេស៊ូបង្ហាញព្រះអង្គឲ្យសាវ័កឃើញ

{៩ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នៅព្រឹក
ថ្ងៃអាទិត្យ មុនដំបូងព្រះអង្គបានបង្ហាញខ្លួនឲ្យនាងម៉ា
រីជាអ្នកស្រុកម៉ាដាឡាឃើញ គឺនាងម៉ារីនេះហើយ
ដែលព្រះអង្គបានដេញខ្មោចប្រាំពីរ ចេញពីនាង។ ១០
នាងបានយកដំណឹងនេះ ទៅប្រាប់អស់អ្នកដែលនៅ
ជាមួយព្រះយេស៊ូកាលពីមុន។ អ្នកទាំងនោះកំពុង
កាន់ទុក្ខ ព្រមទាំងយំសោកទៀតផង។ ១១ពេលគេ
ឮថា ព្រះអង្គមានព្រះជន្មវិញហើយ ឮថានាងបាន
ឃើញព្រះអង្គ គេមិនជឿនាងឡើយ។
១២បន្ទាប់មក ព្រះយេស៊ូបានបង្ហាញព្រះអង្គឲ្យ
សាវ័ក*ពីរនាក់ឃើញ តាមទ្រង់ទ្រាយមួយផ្សេងទៀត
ក្នុងពេលអ្នកទាំងពីរកំពុងធ្វើដំណើរទៅស្រុកស្រែ។
១៣អ្នកទាំងពីរក៏នាំដំណឹងមកប្រាប់សាវ័ក*ឯទៀតៗ
ដែរ តែពួកគេមិនព្រមជឿដដែល។
១៤នៅទីបំផុត ព្រះយេស៊ូក៏បង្ហាញខ្លួនឲ្យសាវ័ក
ទាំងដប់មួយរូបឃើញ នៅពេលដែលគេកំពុងបរិភោ
គ។ ព្រះអង្គបន្ទោសគេ ព្រោះគេគ្មានជំនឿ ហើយ
មានចិត្តរឹងរូស ពុំព្រមជឿអស់អ្នកដែលបានឃើញ
ព្រះអង្គមានព្រះជន្មរស់ឡើងវិញ។
១៥ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ចូរនាំគ្នា
ទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាស
ដំណឹងល្អ*ដល់មនុស្សលោកទាំងអស់ចុះ។ ១៦អ្នក
ណាជឿ ហើយទទួលពិធីជ្រមុជទឹក* ព្រះជាម្ចាស់នឹង
សង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿនឹងត្រូវទទួល
ទោស។ ១៧អស់អ្នកដែលជឿនឹងធ្វើទីសម្គាល់ទាំង
នេះ គឺគេនឹងដេញខ្មោចក្នុងនាមខ្ញុំ គេនិយាយភាសា
ថ្មី។ ១៨ប្រសិនបើគេកាន់ពស់ ឬផឹកអ្វីដែលមានជាតិ
ពុល ក៏គេពុំមានគ្រោះថ្នាក់អ្វីដែរ។ ប្រសិនបើគេដាក់
ដៃលើអ្នកជំងឺ អ្នកជំងឺនឹងបានជាសះស្បើយ»។
១៩កាលព្រះអម្ចាស់យេស៊ូមានព្រះបន្ទូល ទាំង

នេះរួចហើយ ព្រះជាម្ចាស់លើកព្រះអង្គឡើងទៅស្ថានបរមសុខ*ឲ្យគង់នៅខាងស្ដាំព្រះអង្គ។ [20]ពួកសាវ័កនាំគ្នាចេញទៅប្រកាសដំណឹងល្អ នៅគ្រប់ទីកន្លែង។ ព្រះអម្ចាស់ធ្វើការរួមជាមួយគេទាំងបញ្ជាក់ព្រះបន្ទូល ដោយសម្ដែងទីសម្គាល់ផ្សេងៗជាប់ជាមួយផង។}

ក, សេរីភាព(និក្ខមនំ)២៣, ២០; ម៉ាឡាគី៣,១; អេសាយ ៤០,៣។• ខ, ដូចពាក្យវាំងនននរហែកជាពីរនៅម៉ាកូស១៥,៣៨ ដែរ។

គ, ឃ្លាដើមៈ«ប្រសិនបើលោកចង់»។• ឃ, ក្នុងឯកសារខ្លះមានសរសេរថា«ព្រះយេស៊ូទ្រង់ព្រះពិរោធ»។

ង, សូមអានអេសាយ៦,៩-១០។

ច,ឬ«គឺខ្ញុំនេះហើយ»:ចង់សម្ដែងអំពីឋានៈរបស់ព្រះយេស៊ូជាព្រះជាម្ចាស់។ពាក្យ«ខ្ញុំនេះ»ឬ«យើងនេះ»ជាព្រះនាមដែលព្រះជាម្ចាស់សម្ដែងឲ្យលោកម៉ូសេស្គាល់នៅលើភ្នំស៊ីណៃ-សេរីភាព(និក្ខមនំ) ៣,១៤-។• ឆ, ពាក្យដើម«សង្គ្រោះ»។

ជ, អេសាយ២៩,១៣។• ឈ, សេរីភាព(និក្ខមនំ)២០,១២, ២១,១៧។

ញ, ឈ្មោះស្រុកមួយដែលគេពុំដឹងថាស្ថិតទៅត្រង់កន្លែងណាទេ។

ដ, ឃ្លាដើមៈអ្នកណាចង់នៅខាងមុខអ្នកត្រូវដាក់ខ្លួននៅខាងក្រោយបង្អស់(ដូចនៅម៉ាកូស១០,៣១ដែរ)

ឋ, ឯកសារដើមខ្លះគ្មានឃ្លាទៅរួមរស់ជាមួយភរិយារបស់ខ្លួនទេ។• ឌ, កំណើតពិភពលោក(លោកុប្បត្តិ)១,២៧និង២,២៤។

ឍ, សេរីភាព(និក្ខមនំ)២០,១២-១៧ ទុតិយកថា៥,១៦-២០; រ៉ូម ១៣,៩។

ណ, ក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់«ពែង» ជានិមិត្តរូបនៃទុក្ខលំបាក(ទំនុកតម្កើង៧៥,៩;អេសាយ៥១,១៧-២២;យេរេមី២៥,១៥។ល។)ព្រះយេស៊ូប្រើពាក្យពែងនេះសំដៅទៅលើទុក្ខលំបាករបស់ព្រះអង្គនៅលើឈើឆ្កាង(សូមអានម៉ាកូស១៤,៣៦ដែរ)។

ត, «ជយោ»ពាក្យដើម«ហូសាណា»ជាពាក្យជយឃោសន៍ដែលមានន័យថា:«សូមមេត្តាជួយផង!»។• ថ,ទំនុកតម្កើង១១៨, ២៥-២៦។• ទ, អេសាយ៥៦,៧។• ធ, យេរេមី៧,១១។

ន, ទំនុកតម្កើង១១៨,២២-២៣។

ប, សូមអានទុតិយកថា២៥, ៥-៦។• ផ, សូមអានសេរីភាព(និក្ខមនំ)៣,៦។• ព, សូមអានទុតិយកថា៦,៤-៥។•ភ, សូមអានលេវីវិន័យ១៩, ១៨។

ម, ទំនុកតម្កើង១១០,១។

យ, អេសាយ១៩,២។ • រ, ដានីអែល៩,២៧;១២,១១(សូម

អានសេចក្ដីពន្យល់នៅម៉ាថាយ២៤,១៥)។

ល, ដានីអែល១២,១។• វ, អេសាយ១៣,១០។• ស, អេសាយ៣៤,៤។• ហ, ដានីអែល៧,១៣។

ឡ, ពាក្យដើម«បញ្ជូនខ្ញុំ»។• អ, ធម្មតាយើងប្រែពាក្យនេះថាប្រព្រឹត្តអំពើបាបឬឃ្លាតចាកជំនឿ ដោយមិនយល់គំរោងការរបស់ព្រះជាម្ចាស់។• ក, សាការី១៣,៧។

ខ, «ប្រុងស្មារតី»មានន័យពីរយ៉ាងៈន័យម្យ៉ាងមិនដេកលក់គឺនៅភ្ញាក់និងន័យម្យ៉ាងទៀតនៅប្រុងប្រៀបខ្លួនរង់ចាំព្រះជាម្ចាស់។• គ, ពាក្យដើមៈ«ពេលកំណត់នេះ»។ •ឃ,ពាក្យដើម«ពែង»
(សូមអានសេចក្ដីពន្យល់ម៉ាកូស១០,៣៨)។

ង, ទំនុកតម្កើង១១០,១; ដានីអែល៧,១៣។

ច, អេសាយ៥៣,១២។ក្នុងឯកសារខ្លះជាភាសាក្រិកគ្មានឃ្លានៅក្នុង៩២៨នេះទេ។

ឆ, ទំនុកតម្កើង២២,២។

ជ, ថ្ងៃទីមួយក្នុងសប្ដាហ៍នោះ។• ឈ, ឯកសារដើមខ្លះ គ្មានអត្ថបទពី៩៩ដល់៩២០នេះទេ។